ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណាន
# ថ្នាក់ដំបូង នៅខេត្តកំពង់ឆ្នាំង

## Status of Implementation of the First Reading Package in Kampong Chhnang Province

**អ៊ុង សុផល**

**UNG SOPHAL**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

ជំនាន់ទី៨

ឯកទេស ៖ គ្រប់គ្រងអប់រំ

**ឆ្នាំសិក្សា ២០១៩-២០២១**

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណាន ថ្នាក់ដំបូង នៅខេត្តកំពង់ឆ្នាំង

# Status of Implementation of the First Reading Package in Kampong Chhnang Province

អ៊ុង សុផល

UNG SOPHAL

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

ជំនាន់ទី៨

ឯកទេស ៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២១

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institude of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណាន

# ថ្នាក់ដំបូង នៅខេត្តកំពង់ឆ្នាំង

## Status of Implementation of the First Reading Package in Kampong Chhnang Province

អ៊ុង សុផល

UNG SOPHAL

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

ជំនាន់ទី៨

ឯកទេស ៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២១

សាស្ត្រាចារ្យដឹកនាំបង្គោល ៖ លោកបណ្ឌិត នួន វីរ៉ា

សាស្ត្រាចារ្យដឹកនាំរង ៖ លោក ចាប រតនា

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទ សូមប្រកាសអះអាងថា និក្ខេបបទដែលមានចំណងជើងថា «**ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងនៅខេត្តកំពង់ឆ្នាំង**» សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនេះ គឺជាស្នាដៃសិក្សាស្រាវជ្រាវ របស់ខ្ញុំបាទពិតប្រាកដមែន។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយ។ បន្ថែមលើនេះទៀត រាល់សេចក្តីដកស្រង់ និងខ្លឹមសារផ្សេងៗ ដែលបានយកមកប្រើប្រាស់នៅក្នុងអត្ថបទនេះ សុទ្ធតែបានចុះបញ្ជី ក្នុងឯកសារយោងទាំងអស់។

និក្ខេបបទសិក្សាស្រាវជ្រាវខាងលើ ពិតជាត្រូវបានសិក្សា និងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ..............................ខែ................ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

កំពង់ឆ្នាំង ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២១

**ហត្ថលេខា**

**អ៊ុង សុផល**

# **លិខិតបញ្ជាក់**

លោកបណ្ឌិត **នួន វីរ៉ា** ជាសាស្ត្រាចារ្យដឹកនាំបង្គោល

លោក **ចាប រតនា** ជាសាស្ត្រាចារ្យដឹកនាំរង

## **សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **អ៊ុង សុផល** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ ដែលមានចំណងជើងថា «**ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងក្នុងខេត្តកំពង់ឆ្នាំង**» ពិតប្រាកដមែន។

ថ្ងៃ............................ខែ............. ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញថ្ងៃទី...........ខែ............. ឆ្នាំ២០២១

.................................... ....................................

| | |
|---|---|
| លោកបណ្ឌិត **នួន វីរ៉ា** | លោក **ចាប រតនា** |
| នាយករង | អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ |
| វិទ្យាស្ថានជាតិអប់រំ | វិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខៈ** ៧២០៥ **អយក.** [illegible]

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៤-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វី៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកស្រី | ប៊ិន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | សំអោ អង្គារតន៍ | អគ្គ.គផក | សមាជិក |
| ១១-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | សមាជិក |
| ១២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | កាង ស៊ីងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោក | ប៉ូ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

| | | | |
|---|---|---|---|
| ២២-លោកស្រី | ខែក សំណាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោកស្រី | នូ ចន្នី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥-លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៦-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៧-លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៩-ល.ស | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៨-លោក | ជាង ចាន់ណាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣០-លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។/

ថ្ងៃ ពុធ ៦កើត ខែ កត្ដិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទ អ៊ុង សុផល ជានិស្សិតថ្នាក់បិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ នៃវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា ២០១៩-២០២១ ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានបញ្ចប់ការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ។ ជាមួយលទ្ធផលដ៏ត្រចះត្រចង់នេះ ខ្ញុំបាទក៏មិនភ្លេចផងដែរចំពោះការជួយជ្រោមជ្រែង គាំទ្រ និងយកចិត្តទុកដាក់ពីសំណាក់មជ្ឈដ្ឋានជាច្រើន។

ជាបឋម ខ្ញុំបាទសូមគោរពថ្លែងអំណរគុណដ៏ស្មោះអស់ពីដួងចិត្ត ចំពោះលោកឪពុក អ្នកម្តាយ ទាំងសងខាង ដែលជាទីគោរព ស្រឡាញ់ ដ៏ខ្ពង់ខ្ពស់ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូន ផ្តល់ការទូន្មានប្រៀនប្រដៅឲ្យកូនប្រព្រឹត្តតែអំពើល្អ និងបញ្ជូនកូនទៅសិក្សាតាំងពីថ្នាក់ មត្តេយ្យសិក្សារហូតដល់កូនបានក្លាយជាគ្រូបង្រៀនម្នាក់ ហើយបានជួយដល់សង្គមជាតិក្នុងការបណ្តុះបណ្តាលនូវធនធានមនុស្ស។

ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ចំពោះឯកឧត្តមបណ្ឌិត សៀង សុវណ្ណា នាយកវិទ្យាស្ថានជាតិអប់រំ ឯកឧត្តម លោកនាយករង លោកស្រីនាយិការង លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ជាគ្រូឧទ្ទេសគ្រប់មុខវិជ្ជាទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ និងថ្នាក់ដឹកនាំនៃនាយកដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានចំណាយពេលវេលាដ៏មានតម្លៃ យកចិត្តទុកដាក់ ក្នុងការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ បង្ហាត់បង្រៀនដល់ខ្ញុំបាទ ក៏ដូចជានិស្សិតទាំងអស់ដោយមិនគិតពីភាពនឿយហត់។

ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណជាអនេក ចំពោះលោកបណ្ឌិត នូវ វីរ៉ា នាយករងនៃវិទ្យាស្ថានជាតិអប់រំ ដែលជាសាស្ត្រាចារ្យដឹកនាំ និងលោក ចាប រតនា អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការនៃវិទ្យាស្ថានជាតិអប់រំ ជាសាស្ត្រាចារ្យដឹកនាំរង ដែលបានជួយផ្តល់ជាគំនិតយោបល់ដ៏មាន

តម្លៃក្នុងការណែនាំ និងជួយពិនិត្យកែលម្អរាល់កំហុសឆ្គង ក៏ដូចជាចំណុចខ្វះខាតនៅក្នុងនិក្ខេបបទនេះ។

បន្ថែមលើនេះផងដែរនោះ ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណជាពន្លឺកដល់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ ដែលបានបង្ហាត់បង្រៀន ផ្តល់ចំណេះដឹងដល់រូបខ្ញុំបាទ តាំងពីកម្រិតមត្តេយ្យសិក្សារហូតដល់កម្រិតឧត្តមសិក្សា នាពេលនេះ។

ម្យ៉ាងទៀត ក៏សូមគោរពថ្លែងអំណរគុណដល់លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃស្រុកទាំងបី(រលាប្អៀរ កំពង់ត្រឡាច សាមគ្គីមានជ័យ) លោកនាយក លោកស្រីនាយិកានៃសាលាបឋមសិក្សាទាំង២០ក្នុងស្រុកទាំងបី លោកគ្រូ អ្នកគ្រូ ជាប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូបន្ទុកថ្នាក់ទី២ទាំងអស់ ដែលបានចូលរួមចំណែកផ្តល់នូវព័ត៌មានដល់រូបខ្ញុំបាទ ធ្វើឱ្យខ្ញុំបាទបានបញ្ចប់នូវការសរសេរនិក្ខេបបទនេះប្រកបដោយជោគជ័យ។

ក្នុងនោះក៏មិនភ្លេចថ្លែងអំណរគុណផងដែរ ដល់ភរិយា និងកូនៗជាទីស្រឡាញ់ ដែលតែងតែផ្តល់នូវសេចក្តីស្រឡាញ់ ភាពរីករាយ កម្លាំងចិត្ត ដល់ស្វាមី និងឪពុក ដើម្បីមកបន្តការសិក្សាបរិញ្ញាបត្រជាន់ខ្ពស់នេះ។

ជាចុងក្រោយក៏សូមថ្លែងអំណរគុណដល់មិត្តភក្តិរួមរួមជំនាន់ទី៨ ទាំងអស់ដែលបានចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានទាំងឡាយ ធ្វើឱ្យខ្ញុំបាទមានទឹកចិត្តតស៊ូ និងពុះពាររាល់ការលំបាក និងឧបសគ្គទាំងឡាយ ដើម្បីសម្រេចគោលដៅ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យ លោក លោកស្រី លោកគ្រូ អ្នកគ្រូ អ្នកមានគុណទាំងសងខាង ភរិយា កូនៗ អ៊ំ មាមីង បងៗ ក្មួយៗ និងមិត្តភក្តិទាំងអស់ ដែលបានចូលរួមចំណែកជួយគាំទ្រ ទាំងផ្នែកស្មារតី ចំណេះដឹង ឯកសារ និងបទពិសោធន៍ ដល់រូបខ្ញុំក្នុងការសិក្សា និងសរសេរបញ្ចប់និក្ខេបបទនេះ ជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# មាតិកា

សេចក្តីប្រកាសអះអាងរបស់បេក្ខជន ........ i
លិខិតបញ្ជាក់ ........ ii
លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ ........ iii
សេចក្តីថ្លែងអំណរគុណ ........ v
មាតិកា ........ vii
បញ្ជីក្រាប ........ xii
មូលន័យសង្ខេប ........ 1
Abstract ........ 4
ជំពូក១ ៖ សេចក្តីផ្តើម ........ 6
១.១. សាវតារ ........ 6
១.២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 15
១.៣.គោលបំណង និងសារៈសំខាន់នៃការស្រាវជ្រាវ ........ 16
១.៤.សំណួរស្រាវជ្រាវ ........ 17
១.៥.ដែនកំណត់ និងវិសាលភាព ........ 17
១.៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 18
ជំពូក២ ........ 20
រំឭកទ្រឹស្តី ........ 20
២.១.ប្រវត្តិនៃអំណាន ........ 20
២.១.១.និយមន័យនៃអំណាន ........ 20
២.១.២. ដើមកំណើតនៃអំណាន ........ 22
២.១.៣. ប្រភេទនៃអំណាន ........ 22
២.១.៤. ប្រភេទអ្នកអាន ........ 23
២.១.៥. ភាពចាំបាច់ក្នុងការអានសៀវភៅ ........ 24
២.១.៦. ការចាប់ផ្តើម និងការបញ្ចប់ទៅនៃអំណាន ........ 26

២.១.៧. ប្រទេសដែលឱ្យតម្លៃលើអំណាន ....................................................................26
២.១.៨. កម្រិតចូលចិត្តអានរបស់ប្រជាជនកម្ពុជា....................................................................27
២.១.៩. ប្រភេទសៀវភៅគួរជ្រើសរើសដើម្បីអាន....................................................................28
២.២. កម្មវិធីកញ្ចប់អំណានដំបូង ....................................................................29
២.៣.គោលការណ៍ក្នុងលំនាំ នៃការបង្រៀន និងរៀន កញ្ចប់អំណានថ្នាក់ទី២....................................................................33
២.៣.១.បំណិនទាំង៤ នៃការរៀនភាសា....................................................................33
២.៣.២.សមាសភាគទាំង៥ នៃអំណាន និងសំណេរ ....................................................................33
២.៣.៣.សកម្មភាពគោលក្នុងលំនាំបង្រៀន ....................................................................36
២.៣.៤.គោលការណ៍បង្រៀនតាមរបៀប«ខ្ញុំធ្វើ យើងធ្វើអ្នកធ្វើ»....................................................................36
**ជំពូក៣** ....................................................................38
**វិធីសាស្ត្រនៃការស្រាវជ្រាវ**....................................................................38
៣.១. ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ ....................................................................38
៣.២. ទីកន្លែងសិក្សាស្រាវជ្រាវ ....................................................................38
៣.៣. ការជ្រើសរើសសំណាក ....................................................................39
៣.៤. ឧបករណ៍ស្រាវជ្រាវ ....................................................................40
៣.៥. កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ ....................................................................41
៣.៥.១. កម្រងសំណួរសម្រាប់ប្រធានការិយាល័យអយក.នៃរដ្ឋបាលស្រុក ....................................................................41
៣.៥.២. កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង(នាយក/នាយិកា)....................................................................42
៣.៥.៣. កម្រងសំណួរសម្រាប់ប្រធានក្រុមបច្ចេកទេស....................................................................43
៣.៥.៤. កម្រងសំណួរសម្រាប់សម្ភាសលោកគ្រូ អ្នកគ្រូ ....................................................................43
៣.៦. ដំណើរការប្រមូលទិន្នន័យ ....................................................................44
៣.៧. ការវិភាគទិន្នន័យ ....................................................................45
៣.៨. ក្រមសីលធម៌នៃការស្រាវជ្រាវ ....................................................................45
**ជំពូក៤** ....................................................................47
លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា....................................................................47

៤.១. ឧបករណ៍វិភាគទិន្នន័យ......47

៤.២. ដំណាក់កាលនៃការវិភាគទិន្នន័យ......47

៤.៣. លទ្ធផលនៃការសិក្សាស្រាវជ្រាវ......48

៤.៣.១. ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ និងកម្រិតវប្បធម៌......48

៤.៣.២. ការវិភាគទិន្នន័យលើកម្រងសំណួរប្រធានការិយាល័យអយក.ស្រុក......50

៤.៣.៣. ការវិភាគទិន្នន័យលើកម្រងសំណួរនាយក/នាយិកាសាលារៀន......55

៤.៣.៤. ការវិភាគទិន្នន័យលើកម្រងសំណួរប្រធានក្រុមបច្ចេកទេស......71

៤.៣.៥. ការវិភាគទិន្នន័យលើកម្រងសំណួរសម្រាប់គ្រូបង្រៀនថ្នាក់ទី២......88

៤.៤ ការពិភាក្សា......109

**ជំពូក៥**......111

**សេចក្តីសន្និដ្ឋាន និងសំណូមពរ**......111

៥.១. សេចក្តីសន្និដ្ឋាន......111

៥.២. សំណូមពរ......113

៥.៣. អនុសាសន៍សម្រាប់អ្នកសិក្សាបន្ត......113

**ឯកសារយោង**......114

**ឧបសម្ព័ន្ធ**......116

**លិខិតឧទ្ទេសនាម និងឯកសារពាក់ព័ន្ធ**......116

ឧបសម្ព័ន្ធទី១៖ លិខិតអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យរបស់ក្រសួងអប់រំ យុវជន និងកីឡា......116

ឧបសម្ព័ន្ធទី២៖ លិខិតឧទ្ទេសនាមគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងសម្រាប់និស្សិត......117

ឧបសម្ព័ន្ធទី៣៖ លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគ......120

ឧបសម្ព័ន្ធទី៤៖ លិខិតឧទ្ទេសនាមគណៈកម្មការការពារនិក្ខេបបទ......121

ឧបសម្ព័ន្ធទី៥៖ លិខិតបង្គាប់ការគណៈកម្មការការពារនិក្ខេបបទបញ្ចប់......123

ឧបសម្ព័ន្ធទី៦៖ លិខិតឧទ្ទេសនាមគណៈកម្មការរៀបចំ......125

ឧបសម្ព័ន្ធទី៧៖ កម្រងសំណួរចុះប្រមូលទិន្នន័យ......126

ឧបសម្ព័ន្ធទី៨៖ រូបភាពសៀវភៅឯកសារយោង......138

# បញ្ជីតារាង

**តារាងទី១ ៖** ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ ....................................................48

**តារាងទី២ ៖** កម្រិតវប្បធម៌ ថ្នាក់ដឹកនាំការិយាល័យអយក. ស្រុក នាយក/នាយិកា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ....................................................49

**តារាងទី៣៖** បង្ហាញពីបទពិសោធការងារអ្នកចូលរួមផ្តល់សម្ភាសន៍ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក ក្នុងដំណែងជាប្រធានការិយាល័យ៖ ....................................................50

**តារាងទី៤៖** បង្ហាញពីអំពីរយៈពេលបំពេញការងារក្នុងវិស័យអប់រំរបស់ប្រធានការិយាល័យអប់រំ យុវជន និង កីឡា នៃរដ្ឋបាលស្រុក៖ ....................................................50

**តារាងទី៥៖** បង្ហាញពីកម្រិតអាយុរបស់នាយក/នាយិកា ....................................................56

**តារាងទី៦៖** បង្ហាញពីរយៈពេលបំពេញការងារក្នុងវិស័យអប់រំរបស់នាយក/នាយិកា ....................................................56

**តារាងទី៧៖** បង្ហាញពីរយៈពេលបំពេញតួនាទីជាគណៈគ្រប់គ្រងសាលា ....................................................57

**តារាងទី៨៖** បង្ហាញពីកម្រិតសញ្ញាបត្ររបស់គណៈគ្រប់គ្រងសាលា ....................................................58

**តារាងទី៩៖** បង្ហាញពីកម្រិតវិជ្ជាជីវៈរបស់គណៈគ្រប់គ្រងសាលា ....................................................59

**តារាងទី១០៖** បង្ហាញពីអាយុរបស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស . 71

**តារាងទី១១៖** បង្ហាញពីកម្រិតវប្បធម៌របស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យរបស់ប្រធានក្រុម បច្ចេកទេស ....................................................73

**តារាងទី១២៖** បង្ហាញពីកម្រិតវិជ្ជាជីវៈរបស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យរបស់ប្រធានក្រុម បច្ចេកទេស ....................................................73

**តារាងទី១៣៖** បង្ហាញពីរយៈពេលបំពេញការងារក្នុងវិស័យអប់រំ របស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យ របស់ប្រធានក្រុមបច្ចេកទេស ....................................................74

**តារាងទី១៤៖** បង្ហាញពីរយៈពេលបំពេញតួនាទីជាប្រធានក្រុមបច្ចេកទេស ....................................................75

**តារាងទី១៥៖** បង្ហាញពីអាយុរបស់គ្រូបង្រៀនថ្នាក់ទី២ តាមទិន្នន័យរបស់គ្រូបន្ទុកថ្នាក់ទី២ ....................................................89

**តារាងទី១៦៖** បង្ហាញពីកម្រិតវប្បធម៌របស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យរបស់ប្រធានក្រុម បច្ចេកទេស ....................................................90

**តារាងទី១៧៖** បង្ហាញពីកម្រិតវិជ្ជាជីវៈរបស់លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ តាមទិន្នន័យរបស់លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ ....................................................91

**តារាងទី១៨៖** បង្ហាញពីរយៈពេលបំពេញការងារក្នុងវិស័យអប់រំ របស់លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ តាមទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២......91

# បញ្ជីក្រាប

**ក្រាបទី១៖** បង្ហាញពីកម្រិតវិជ្ជាជីវៈរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក.... 51

**ក្រាបទី២៖** បង្ហាញពីភេទអ្នកចូលរួមផ្ដល់ទិន្នន័យ របស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក ........ 51

**ក្រាបទី៣៖** បង្ហាញពីការចុះអធិការកិច្ច របស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក52

**ក្រាបទី៤៖** បង្ហាញពីការអនុវត្តកម្មវិធីកញ្ចប់អំណាននៅតាមសាលាគោលដៅ នៃស្រុកទាំង២ ............52

តាមការផ្ដល់ទិន្នន័យរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក ......................52

**ក្រាបទី៥៖** បង្ហាញពីការងាររដ្ឋបាល(កិច្ចតែងការ)របស់លោកគ្រូ អ្នកគ្រូ នៅតាមសាលាគោលដៅ នៃស្រុកទាំង២ តាមការផ្ដល់ទិន្នន័យរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក............53

**ក្រាបទី៦៖** បង្ហាញពីការចូលរួមសិក្ខាសាលាស្ដីពីកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក ........54

**ក្រាបទី៧៖** បង្ហាញពីថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់សាលារៀនគោលដៅតាមទិន្នន័យរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក ........54

**ក្រាបទី៨៖** បង្ហាញពីគំនិតយល់ឃើញពីសារៈប្រយោជន៍នៃកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់សាលារៀនគោលដៅ តាមទិន្នន័យរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក ........55

**ក្រាបទី៩៖** បង្ហាញពីភេទរបស់គណៈគ្រប់គ្រង........55

**ក្រាបទី១០៖** បង្ហាញពីចំនួនថ្នាក់ទី២ តាមសាលានីមួយៗ នៃសាលាសំណាកទាំង១៦ ........60

**ក្រាបទី១១៖** បង្ហាញពីចំនួនវេនសិក្សា តាមសាលានីមួយៗ នៃសាលាសំណាកទាំង១៦........60

**ក្រាបទី១២៖** បង្ហាញពីផែនការអធិការកិច្ចតាមសាលាសំណាក ដែលផ្ដល់ទិន្នន័យដោយនាយក/នាយិកាសាលា........61

**ក្រាបទី១៣៖** បង្ហាញពីចំនួនសាលា និងភាគរយនៃការអនុវត្តផែនការ ចុះធ្វើអធិការកិច្ចថ្នាក់រៀន តាមការផ្ដល់ទិន្នន័យរបស់នាយក/នាយិកាសាលា........61

**ក្រាបទី១៤៖** បង្ហាញពីរយៈពេលដែលបានអនុវត្តកម្មវិធីកញ្ចប់អំណាននៅសាលារៀនសំណាក ..........64

**ក្រាបទី១៥៖** បង្ហាញពីការចូលរួមសិក្ខាសាលាកម្មវិធីកញ្ចប់អំណានរបស់នាយក/នាយិកា ........65

**ក្រាបទី១៦៖** បង្ហាញពីថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់សាលារៀនសំណាកតាមទិន្នន័យរបស់នាយក/នាយិកា ........65

**ក្រាបទី១៧៖** បង្ហាញពីការអនុវត្តតាមលំនាំវិធីបង្រៀននៃកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់លោកគ្រូ អ្នកគ្រូ តាមទិន្នន័យរបស់នាយក/នាយិកា ....... 66

**ក្រាបទី១៨៖** បង្ហាញគំនិតយល់ឃើញពីសារៈប្រយោជន៍ នៃកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង តាមទិន្នន័យរបស់នាយក/នាយិកា ....... 67

**ក្រាបទី១៩៖** បង្ហាញពីលទ្ធផលសិក្សារបស់សិស្សជាប់ លើផ្នែកអំណាន តាមទិន្នន័យរបស់នាយក/នាយិកា ....... 68

**ក្រាបទី២០៖** បង្ហាញពីការតែងកិច្ចបង្រៀនរបស់គ្រូ តាមទិន្នន័យរបស់នាយក/នាយិកា ....... 69

**ក្រាបទី២១៖** បង្ហាញពីការប្រជុំក្រុមបច្ចេកទេសនៅតាមសាលានីមួយៗ តាមទិន្នន័យរបស់នាយក/នាយិកា ....... 70

**ក្រាបទី២២៖** បង្ហាញពីភេទរបស់ប្រធានក្រុមបច្ចេកទេសសាលាសំណាកទាំង២០ តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស ....... 71

**ក្រាបទី២៣៖** បង្ហាញពីការចុះធ្វើអធិការកិច្ចថ្នាក់រៀនរបស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស ....... 76

**ក្រាបទី២៤៖** បង្ហាញពីការតែងកិច្ចរបស់គ្រូនៅតាមសាលាសំណាកទាំង២០ តាមការផ្តល់ទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស ....... 79

**ក្រាបទី២៥៖** បង្ហាញពីការប្រជុំក្រុមបច្ចេកទេសនៅតាមសាលានីមួយៗ តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស ....... 80

**ក្រាបទី២៦៖** បង្ហាញពីរយៈពេលនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងនៅសាលាសំណាកទាំង២០ តាមការផ្តល់ទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស ....... 81

**ក្រាបទី២៧៖** បង្ហាញពីការចូលរួមសិក្ខាសាលាកម្មវិធីកញ្ចប់អំណានរបស់ប្រធានក្រុមបច្ចេកទេស តាមការផ្តល់ទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស ....... 82

**ក្រាបទី២៨៖** បង្ហាញពីថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់សាលារៀនសំណាកទាំង២០ តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស ....... 82

**ក្រាបទី២៩៖** បង្ហាញគំនិតយល់ឃើញពីសារៈប្រយោជន៍ នៃកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស ....... 84

**ក្រាបទី៣០៖** បង្ហាញពីភេទរបស់លោកគ្រូ អ្នកគ្រូសាលាសំណាកទាំង២០ តាមទិន្នន័យរបស់គ្រូបង្រៀន88

**ក្រាបទី៣១៖** បង្ហាញពីការចុះធ្វើអធិការកិច្ចថ្នាក់រៀនរបស់នាយក/នាយិកា តាមទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២ ....93

**ក្រាបទី៣២៖** បង្ហាញពីការចុះធ្វើអធិការកិច្ចថ្នាក់រៀនរបស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២ ....96

**ក្រាបទី៣៣៖** បង្ហាញពីការតែងកិច្ចរបស់គ្រូនៅតាមសាលាសំណាកទាំង២០ តាមការផ្តល់ទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២ផ្ទាល់....97

**ក្រាបទី៣៤៖** បង្ហាញពីការប្រជុំក្រុមបច្ចេកទេសនៅតាមសាលានីមួយៗ តាមទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២....98

**ក្រាបទី៣៥៖** បង្ហាញពីរយៈពេលនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងនៅសាលាសំណាកទាំង២០ តាមការផ្តល់ទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២ ....99

**ក្រាបទី៣៦៖** បង្ហាញពីការចូលរួមសិក្ខាសាលាកម្មវិធីកញ្ចប់អំណានរបស់លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ តាមការផ្តល់ទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២ ....100

**ក្រាបទី៣៧៖** បង្ហាញពីថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់សាលារៀនសំណាកទាំង២០ តាមទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២ .... 101

**ក្រាបទី៣៨៖** បង្ហាញពីការអនុវត្តលំនាំបង្រៀនក្នុងកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង តាមទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២ ....102

**ក្រាបទី៣៩៖** បង្ហាញគំនិតយល់ឃើញពីសារៈប្រយោជន៍ នៃកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង តាមទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២....103

# មូលន័យសង្ខេប

ប្រទេសនីមួយៗ អាចអភិវឌ្ឍ ឬរីកចម្រើន មានសុខសន្តិភាពទៅបាន អាស្រ័យដោយសារកត្តាធនធានមនុស្ស។ កាលបើយើងនិយាយដល់កត្តាធនធានមនុស្ស គឺយើងត្រូវគិតដល់ប្រភព និងមូលដ្ឋានគ្រឹះនៃការបណ្តុះធនធានមនុស្ស នោះគឺការអប់រំ។ ការអប់រំ ឬការទូន្មានប្រៀនប្រដៅ ជាកត្តាគួបផ្សំជាមួយនឹងការបង្ហាត់បង្រៀន ដែលនាំឱ្យទទួលបាននូវមនុស្សដែលមានចំណេះដឹង បំណិន និងឥរិយាបថល្អប្រ-ពៃ។ ចំណេះដឹងរបស់មនុស្សកើតឡើងតាមរយៈសមត្ថភាពធំៗទាំងបួនគឺការអាន ការស្តាប់ ការនិយាយ និងការសរសេរ ហើយក្នុងចំណោមសមត្ថភាពធំៗទាំងបួន ការអានគឺត្រូវបានចាត់ទុកជាមូលដ្ឋានគ្រឹះដំបូង និងសំខាន់ជាងគេ គ្រប់ភាសាទាំងអស់ក្នុងសកលលោក ។ កត្តានេះដោយសារមនុស្សដែលត្រូវបានគេចាត់ទុកថាមានចំណេះដឹងទៅបាន គឺអាស្រ័យដោយគេចេះអានអក្សរ បន្ទាប់មកមានការចេះសរសេរអក្សរជាដើម ។

ជាមួយគ្នានេះដែរក្រសួងអប់រំយុវជន និងកីឡាក៏បាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអនុវត្តគោលនយោបាយកំណែទម្រង់ ដោយផ្តោតលើសសរស្តម្ភទាំងប្រាំក្នុងការលើកកម្ពស់វិស័យអប់រំឱ្យកាន់តែប្រសើរឡើង និងដើម្បីធានាបាននូវគុណភាពអប់រំ ស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៥-២០៣០។ ក្នុងនោះ យើងសង្កេតឃើញថា ការអប់រំនៅកម្រិតបឋមសិក្សា ពិសេសការសិក្សាថ្នាក់ដំបូង ក្រសួង និងអង្គការដៃគូពាក់ព័ន្ធនានាបានចូលរួមបង្កើតកម្មវិធីអំណានដំបូងដើម្បីជួយលោកគ្រូអ្នកគ្រូ លើវិធីសាស្ត្របង្រៀនអំណាន និងការអានរបស់សិស្សានុសិស្សឲ្យទទួលបានគុណភាព ហើយកម្មវិធីនេះបានដាក់ឲ្យអនុវត្តសាកល្បងនៅខេត្តសៀមរាប និងខេត្តកំពង់ធំដោយទទួលបានប្រសិទ្ធភាពខ្ពស់គឺ ៦៨% ដែលទិន្នន័យសិស្សចេះអាន (តេស្ត អ៊ីហ្គ្រា ឆ្នាំ២០១៧-២០១៨)។ ដោយមើលឃើញលទ្ធផលល្អដូច្នេះ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយកប្រធានបទស្តីអំពី « ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងនៅខេត្តកំពង់ឆ្នាំង» មកធ្វើការស្រាវជ្រាវផងដែរ ។

ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងដោយជ្រើសយក ការិយាល័យអប់រំនៃរដ្ឋបាលស្រុកចំនួន០៣ និងសាលាបឋមសិក្សាចំនួន២០ នៅក្នុងខេត្តកំពង់ឆ្នាំង។ ការសិក្សាស្រាវជ្រាវនេះផ្តោតលើស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង នៅកម្រិតថ្នាក់ទី២ ដោយសិក្សាលើចំណុចពីរសំខាន់ៗគឺ ទស្សនៈយល់ឃើញរបស់ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូលើកម្មវិធីកញ្ចប់អំណាន និងលទ្ធផលសិក្សារបស់សិស្សក្រោយពីបានអនុវត្តកម្មវិធីកញ្ចប់អំណានហើយ។ ក្នុងនោះដែរក៏មានការសាកសួរពីរយៈពេលនៃការអនុវត្តកម្មវិធីកញ្ចប់អំណាន ការចូលរួមសិក្ខាសាលាកម្មវិធីកញ្ចប់អំណាន ថវិកាដំណើរការកម្មវិធីកញ្ចប់អំណាន ការចូលរួមប្រជុំបច្ចេកទេសចែករំលែកបទពិសោធគ្នា ការអនុវត្តការបង្រៀនតាមលំនាំនៃកម្មវិធីកញ្ចប់អំណាន សារៈសំខាន់នៃកម្មវិធីកញ្ចប់អំណាន ជាដើម។

ការសិក្សាស្រាវជ្រាវបានប្រើប្រាស់ឧបករណ៍កម្រងសំណួរ ដើម្បីធ្វើការប្រមូលទិន្នន័យ ពីសំណាកដោយជ្រើសយកថ្នាក់ដឹកនាំការិយាល័យចំនួន០៣រូប នាយក/នាយិកាសាលាចំនួន ២០រូប ប្រធានក្រុមបច្ចេកទេសចំនួន២០នាក់ គ្រូបង្រៀនថ្នាក់ទី២ចំនួន៣១នាក់ ដើម្បីបំពេញកម្រងសំណួរ។ ទិន្នន័យដែលប្រមូលបាន អ្នកសិក្សាស្រាវជ្រាវបានយកមកវិភាគតាមកម្មវិធី MS Excel ដោយបង្ហាញជាតារាងស្ថិតិ និងដ្យាក្រាម ចំពោះកម្មវិធី MS Word រៀបរាប់ពីយោបល់ផ្ទាល់បែបសំណួរគុណវិស័យទៅលើភាគសំណាក។

ការសិក្សាស្រាវជ្រាវ នេះបានរកឃើញថា ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងនៅខេត្តកំពង់ឆ្នាំងមានចំណុចល្អច្រើនដូចជា ១)ថ្នាក់ដឹកនាំការិយាល័យ នាយក/នាយិកាសាលា ប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ស្ទើរតែទាំងអស់សុទ្ធតែធ្លាប់ចូលរួមសិក្ខាសាលាកម្មវិធីកញ្ចប់អំណាន ២) គ្រូបង្រៀនទាំងអស់សុទ្ធតែបង្រៀនតាមលំនាំលំហូរនៃកម្មវិធីកញ្ចប់អំណាន ៣) ក្នុងចំណោមសាលាទាំង២០ មានសាលា៦០%បានបន្ថែមថវិកាសម្រាប់ដំណើរការកម្មវិធី ពីលើការឧបត្ថម្ភរបស់គម្រោង ៤) គ្រប់ភាគីសំណាកទាំងអស់សុទ្ធតែឱ្យតម្លៃលើកម្មវិធីកញ្ចប់អំណាន ៥)លទ្ធផលសិក្សាសិស្សមានភាពរីកចម្រើនដែលសាលាមួយចំនួនជាប់រហូតដល់៨០%។ ប៉ុន្តែនៅមានបញ្ហាប្រឈមតិចតួចគឺគ្រូមួយចំនួន

តូចដែលបង្រៀនថ្នាក់ទី២ពុំធ្លាប់បានចូលរួមសិក្ខាសាលា ដោយសារពួកគាត់ទើបចូលមកបង្រៀននៅឆ្នាំសិក្សានេះ។

សរុបសេចក្ដីមក ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងក្នុងខេត្តកំពង់ឆ្នាំង គឺប្រព្រឹត្តទៅបានល្អ ដោយផ្អែកតាមលទ្ធផល និងចម្លើយនៃការសិក្សាស្រាវជ្រាវដូចបានរៀបរាប់ជូនខាងលើ ។

# Abstract

Each country can develop or grow peacefully due to human resources. When we talk about human resources, we have to think about the source and foundation of human resource training, that is education. Education or counseling is a combination of training that leads to the acquisition of knowledge, skills and good manners. Human knowledge arises through the four great abilities of reading, listening, speaking, and writing, and of the four great abilities, reading is considered the first and foremost foundation of all languages in the universe. This is because people who are considered to be literate depend on being able to read and then write.

At the same time, the Ministry of Education, Youth and Sports has been paying close attention to the implementation of the reform policy based on the five pillars to improve the education sector and to ensure the quality of education. Inline with the Sustainable Development Goals 2015-2030. In that, we observed that education at the primary level, especially primary education, the Ministry and the relevant partner organizations have participated in creating the first reading program to help teachers on teaching methods of reading and reading of students to get quality and this program Tested in Siem Reap and Kampong Thom with a high efficiency of 68% of the student literacy data (EGRA test 2017-2018). Seeing the good results, the researchers chose the topic of "Status of Implementation of the First Grade Reading Package in Kampong Chhnang Province" for research.

The study was conducted by selecting 3 district administration education offices and 20 primary schools in Kampong Chhnang province. This study focuses on the status of the implementation of the first grade reading package at the second grade level by studying two main points: the perceptions of the management, the management, the teachers on the reading package and the students' learning outcomes after implementation of the reading package has been implemented. In addition, there are inquiries about the duration of the implementation of the reading package program, participation in workshops, reading package program, budget, travel program reading program, participation in technical meetings, sharing experiences, the implementation of package program patterns, Reading importance of reading package programs and so on.

The study used questionnaire equipment to collect data from the sample by selecting 3 office leaders, 20 principals / principals, 20 technical team leaders and 31 secondary school teachers to complete the questionnaire. The data collected by the researchers were analyzed in MS Excel, showing a statistical table and MS Word diagram describing the direct comments, qualitative questions on the sample.

This study found that the situation of the implementation of the first grade reading package program still has many good points, such as 1) Office leaders, principals / school principals, technical team leaders, teachers, second grade teachers almost all Participate in reading package workshops 2) All teachers teach according to the flow of reading package program 3) Out of 20 schools, 60% of the schools have increased the budget for running the program on the project sponsorship 4) All sample parties All value reading package programs. 5) Student achievement has improved, with some schools sticking to 80%. But there are still a few challenges: a small number of second grade teachers have never attended the workshop because they have just come to teach this school year.

In conclusion, the status of the implementation of the first reading package in Kampong Chhnang is good, based on the results and answers of the research as described above.

# ជំពូក១ ៖ សេចក្តីផ្តើម

## ១.១. សាវតារ

នៅក្នុងសកលលោកយើងនេះ ប្រទេសនីមួយៗ អាចអភិវឌ្ឍ ឬរីកចម្រើន មានសុខសន្តិភាពទៅបាន អាស្រ័យដោយសារកត្តាធនធានមនុស្ស។ កាលបើយើងនិយាយដល់កត្តាធនធានមនុស្ស គឺយើងត្រូវគិតដល់ប្រភព និងមូលដ្ឋានគ្រឹះនៃការបណ្តុះធនធានមនុស្ស នោះគឺការអប់រំ។ការអប់រំ ឬការទូន្មានប្រៀនប្រដៅ ជាកត្តាគួបផ្សំជាមួយនឹងការបង្ហាត់បង្រៀន ដែលនាំឱ្យទទួលបាននូវមនុស្សដែលមានចំណេះដឹង បំណិន និងឥរិយាបថល្អប្រពៃ។ ចំណេះដឹងរបស់មនុស្សកើតឡើងតាមរយៈសមត្ថភាពធំៗទាំងបួនគឺ ការអាន ការស្តាប់ ការនិយាយ និងការសរសេរ ហើយក្នុងចំណោមសមត្ថភាពធំៗទាំងបួន ការអានត្រូវបានចាត់ទុកជាមូលដ្ឋានគ្រឹះដំបូង និងសំខាន់ជាងគេ គ្រប់ភាសាទាំងអស់ក្នុងសកលលោក។ កត្តានេះដោយសារមនុស្សដែលត្រូវបានគេចាត់ទុកថាមានចំណេះដឹងទៅបានគឺអាស្រ័យដោយគេចេះអានអក្សរ បន្ទាប់មកមានការចេះសរសេរអក្សរជាដើម។

ជាការពិត ការបណ្តុះចំណេះដឹងតាមរយៈការអាននេះ គឺមិនត្រឹមតែធ្វើឡើងក្នុងពេលចូលដល់វ័យសិក្សានោះឡើយ គឺត្រូវគិតចាប់តាំងពីទារកដែលបានមកចាប់បដិសន្ធិនៅក្នុងផ្ទៃរបស់មាតាមកម្ល៉េះ (https://hellokrupet.com)។ មាតាគ្រប់រូបត្រូវធ្វើខ្លួនឲ្យរីករាយដើម្បីកូនក្នុងផ្ទៃរីករាយតាមដែរ។ ក្នុងនោះការអានសៀវភៅ និងការស្តាប់តន្ត្រីនៅពេលកំពុងមានផ្ទៃពោះ បានរួមចំណែកយ៉ាងសំខាន់ជួយឲ្យកូនកាន់តែមានអារម្មណ៍ល្អ។ អ្នកជំនាញជាច្រើនតែងជំរុញឲ្យមាតាគិត ក្រៅពីរបបអាហារសុខភាព ស្ត្រីមានផ្ទៃពោះគួរទទួលយកភាពរីករាយផ្នែកផ្លូវអារម្មណ៍ពីការស្តាប់តន្ត្រី ឬអានសៀវភៅដែលវាអាចជួយឲ្យអារម្មណ៍សប្បាយភ្លេចអស់ទុក្ខកង្វល់ ថែមទាំងផ្តល់ផលល្អដល់ទារកនៅក្នុងផ្ទៃ។ ចំពោះការអានសៀវភៅវិញ មិនត្រឹមតែអាចជួយឲ្យចិត្តស្ងប់ល្អ ថែមទាំងបង្កើនចំណេះដឹងកាន់តែច្រើន ពេលមានកូនអាចថែទាំបានល្អ និងពេលកូនកាន់តែធំទៅ យើងមានគ្រឹះក្នុងការអប់រំណែនាំពួកគេឲ្យក្លាយជាមនុស្សល្អ (https://hellokrupet.com)។ បើទោះបីជាទារកក្នុងផ្ទៃមិនអាចយល់ពីពាក្យសម្តីដែល

យើងកំពុងនិយាយក៏ពិតមែន ប៉ុន្តែការអានសៀវភៅនឹងធ្វើឲ្យកូនទទួលឥទ្ធិពលពីសំឡេង។ និយាយឲ្យស្រួលស្តាប់ ទារកនឹងចងចាំសំឡេងរបស់យើង ហើយគ្រឹះភាសារបស់កូន គឺអភិវឌ្ឍតាំងពីនៅក្នុងស្បូនមក គេអាចស្តាប់ឮសំឡេង និងចងចាំបានល្អ។ ហេតុនេះហើយម្តាយគ្រប់រូបគួរតែអានសៀវភៅដែលល្អៗ ឬជាប្រភេទរឿងនិទានផ្សេងៗទៅឲ្យកូនក្នុងផ្ទៃស្តាប់។ ប៉ុន្តែវេជ្ជបណ្ឌិតតំណាងគ្រូពេទ្យវះកាត់រោគស្ត្រីអាស៊ីប៉ាស៊ីហ្វិកប្រចាំនៅកម្ពុជារូបនោះ បានបញ្ជាក់ថា បើទោះជាការអានសៀវភៅពេលពពោះជាពិសេសចាប់ពីត្រីមាសទី២ ទៅសំខាន់ក៏ពិតមែន តែកូនពេលដល់វ័យសិក្សាត្រូវតែទទួលបានការអប់រំនៅសាលា ព្រោះថាទីនោះគឺជាកន្លែងផ្តល់ចំណេះ សីលធម៌ សុជីវធម៌ តាមបច្ចេកទេសត្រឹមត្រូវ (https://hellokrupet.com)។ ក្នុងន័យនេះបង្ហាញថា មូលដ្ឋានគ្រឹះនៃការអប់រំគឺកើតឡើងពីការអាន ស្តាប់ជាដើម តាំងពីក្នុងផ្ទៃរបស់មាតាមកម្ល៉េះ ប៉ុន្តែការអប់រំបន្ត គឺជាកាតព្វកិច្ចរបស់សាលារៀន។ ហេតុដូចនេះហើយ គ្រប់ប្រទេសទាំងអស់នៅក្នុងសកលលោក នៅពេលកុមារចូលដល់វ័យសិក្សា ត្រូវតែបញ្ជូនពួកគេទៅសិក្សារៀនសូត្រ ហើយចំណេះដឹងរបស់កុមារទៀតសោត ត្រូវផ្តើមចេញពីការនិយាយ ស្តាប់ អាន សរសេរ។

ដោយសារការអានមានសារៈប្រយោជន៍នៃការបង្កើតនូវចំណេះដឹងដូច្នេះហើយ បានជាមានការប្រារព្ធទិវាអំណានពិភពលោកឡើង ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែមេសា ជារៀងរាល់ឆ្នាំ។ សម្រាប់ទិវាអំណានពិភពលោកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១ នេះគឺជា “ទិវាអំណានពិភពលោក”លើកទី២៦ ហើយ។ មិនថាមនុស្សចាស់ ឬក្មេង មិនថាអ្នកក្រ ឬអ្នកមាន ទោះបីអ្នកមានជំងឺ ឬមានសុខភាពល្អ សង្ឃឹមថាមនុស្សដែលរស់នៅលើពិភពលោក សុទ្ធតែអាចរីករាយជាមួយការអានសៀវភៅ អាចគោរព និងអរគុណអ្នកនិពន្ធល្បីៗ ដែលបានរួមចំណែកដ៏ធំដល់អារ្យធម៌មនុស្សជាតិ និងអាចការពារកម្មសិទ្ធិបញ្ញាផងដែរ។ នេះជាសេចក្តីប្រកាសសំខាន់នៃទិវាអំណានពិភពលោ(http://cambodian.cri.cn/i)។

ការអានសៀវភៅអាចបណ្តុះបណ្តាលសីលធម៌ និងគុណធម៌របស់មនុស្សម្នាក់ៗ។ ប៉ុន្មានឆ្នាំកន្លងមកនេះ លោក ស៊ី ជីនភីង ប្រធានរដ្ឋចិនធ្លាប់លើកឡើងអំពីការអានសៀវភៅជាសាធារណៈច្រើន

ដង និងបានថ្លែងថា "ការអានសៀវភៅបានក្លាយជាវិធីរស់នៅម៉្យាងរបស់ខ្ញុំ" ។ លោក ស៊ី ជីន ភីង ប្រធានរដ្ឋចិនលើកទឹកចិត្តចំពោះយុវជនទាំងឡាយថា ត្រូវបំផុសជំនឿ ទទួលបានការបំផុសគំនិត និងកម្លាំងពីការអានសៀវភៅ។ ស្របនឹងការអភិវឌ្ឍលើវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា វិធីដែលមនុស្សអានសៀវភៅមានភាពចម្រុះបែប ពីមួយថ្ងៃទៅមួយថ្ងៃ ហើយអត្ថន័យនៃការអានសៀវភៅចំពោះមនុស្សគឺកាន់តែសម្បូរបែបឡើង។ ប៉ុន្មានឆ្នាំចុងក្រោយនេះ ការលេចចេញនៃសៀវភៅអេឡិចត្រូនិក និងកម្មវិធីអូឌីយ៉ូ(Audio) ធ្វើឱ្យការស្តាប់ ការអានសៀវភៅកំពុងក្លាយជារបៀបថ្មី នៃអំណាន (http://cambodian.cri.cn )។

សម្រាប់ព្រះរាជាណាចក្រកម្ពុជាយើង យោងតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ១២០ អនក្រ.បក. ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់យកថ្ងៃទី១១ ខែមីនា រៀងរាល់ឆ្នាំជាទិវាជាតិអំណាននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ រួមចំណែកការពារ និងពង្រឹងវប្បធម៌ខ្មែរ ដែលក្នុងនោះមានចំនួន៣ មាត្រា ដោយចែងអំពី៖

- មាត្រា១ ÷ ចែងពីការកំណត់កាលបរិច្ឆេទនៃ ទិវាជាតិអំណាន និងគោលបំណង។
- មាត្រា២ ÷ ចែងពីការចូលរួមពីភាគីពាក់ព័ន្ធ ដើម្បីបង្កើតការប្រឡងប្រណាំង ការតែងនិពន្ធ និងកិច្ចសហការរវាងស្ថាប័ន និងអ្នកពាក់ព័ន្ធជាមួយក្រសួងអប់រំ ក្នុងការបង្កើតទិវាជាតិអំណាន។
- មាត្រា៣ ÷ ចែងពីតួនាទី ភារកិច្ចរបស់ស្ថាប័នពាក់ព័ន្ធ ជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា (https://www.coj.gov.kh/wpcontent/uploads)។

ការប្រារព្ធទិវាជាតិអំណាននាថ្ងៃទី១១ ខែមីនា នេះក៏ធ្វើឡើងដើម្បីជាការរំឭកដល់ថ្ងៃប្រសូតរបស់សម្តេចព្រះមហាសុមេធាធិបតី ជួន ណាត (ជោតញ្ញាណោ) សម្តេចព្រះសង្ឃរាជថ្នាក់ទី១ គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា ដែលទ្រង់ប្រសូតនៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៨៨៣។

ក្នុងការប្រារព្ធទិវាជាតិអំណានរាល់លើក តែងតែមានការប្រកួតប្រជែង ដោយការកំណត់ប្រធានបទសម្រាប់បុគ្គលិកអប់រំក្នុងការតែងនិពន្ធ និងសម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ ការសូត្រកំណាព្យរបស់សិស្សមធ្យមសិក្សាបឋមភូមិ និងការអានអត្ថបទសម្រាប់សិស្សកម្រិតបឋមសិក្សា។ សម្រាប់ឆ្នាំ២០២១នេះដែរ គឺជាខួបលើកទី៦ហើយ នៃទិវាជាតិអំណានរបស់ព្រះរាជាណាចក្រកម្ពុជាយើង។ខាងក្រោមនេះជាប្រធានបទ ដែលបានបង្កើតឡើងសម្រាប់ទិវាជាតិអំណានទៅតាមឆ្នាំនីមួយៗ៖

- ទិវាជាតិអំណានលើកទី១ ក្រោមប្រធានបទ៖ "បណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន"

- ទិវាជាតិអំណានលើកទី២ ក្រោមប្រធានបទ៖ "អានដើម្បីភាពសុខដុមនៃជីវិត"

- ទិវាជាតិអំណានលើកទី៣ ក្រោមប្រធានបទ៖ "អំណានជាកំណប់វិជ្ជាមហាសាល"

- ទិវាជាតិអំណានលើកទី៤ ក្រោមប្រធានបទ៖"ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត"

- ទិវាជាតិអំណានលើកទី៥ ក្រោមប្រធានបទ៖ «ការអានបណ្តុះបញ្ញាការស្រាវជ្រាវ និង នវានុវត្តន៍» (https://web.facebook.com បណ្ណាល័យអក្សរសាស្ត្រខ្មែរ)និង

- ទិវាជាតិអំណានលើកទី៦ ក្រោមប្រធានបទ៖ «អំណានក្នុងបរិបទកូវីដ-១៩»។ (https://thmeythmey.com/?page)

ជាមួយគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានធ្វើកំណែទម្រង់ជាបន្តបន្ទាប់ ដើម្បីធ្វើឱ្យសិស្សមានចំណេះដឹង មានជំនាញពិតប្រាកដ។ យ៉ាងណាមិញ ក្រសួងក៏បានធ្វើកំណែទម្រង់ចំនួន១៥ចំណុច ក្នុងនោះក៏មានការកែទម្រង់លើការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិផងដែរ ជាទឡ្ហីករណ៍ធ្វើឱ្យទទួលបានលទ្ធផលគួរឲ្យកត់សម្គាល់។ ប៉ុន្តែក៏នៅមានមតិ

ឬទស្សនៈបានលើកឡើងផងដែរថា ការឆ្លងភូមិសិក្សាពីបឋមសិក្សាទៅអនុវិទ្យាល័យនៅតែមិនទាន់មានគុណភាពនៅឡើយគឺមានតែបរិមាណ។ ចំណែកឯក្រុមគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ ក៏បានលើកឡើងដែរថា សិស្សដែលឡើងពីថ្នាក់ទី៦មកទី៧ គឺសមត្ថភាពក្នុងការអានអក្សរនៅមានកម្រិត ហើយក៏មានសិស្សខ្លះមិនចេះអានតែម្តង (អត្ថបទទស្សនៈព្រឹត្តិការណ៍ខ្មែរ សំឡេងពិភពលោក)។ ក្នុងនោះដែរ ការធ្វើតេស្តឡើងថ្នាក់ពីកម្រិតបឋមសិក្សាឆ្លងទៅមធ្យមសិក្សាបឋមភូមិ ផ្តោតសំខាន់លើការពង្រឹងសមត្ថភាពអំណាន សរសេរ ការគណនាលេខរបស់សិស្ស។ ដូច្នេះ អំណានគឺពិតជាមានសារៈសំខាន់ ព្រោះជាមូលដ្ឋានគ្រឹះ ក្នុងការរៀនមុខវិជ្ជា ដទៃទៀត។

ដើម្បីពង្រឹងគុណភាពអំណានរបស់សិស្ស យើងសង្កេតឃើញថា នៅតាមសាលានីមួយៗសុទ្ធតែមានបណ្ណាល័យដែលមានសៀវភៅជាច្រើន និងមានបណ្ណារក្សសម្រាប់ជួយពួកគេក្នុងការអានឲ្យបានស្ទាត់ជំនាញផងដែរ។ ក្នុងនោះដែរលោកស្រី ខ្លូតវិបុលឡា នាយិកាបណ្ណាល័យជាតិបាននិយាយថា មានសិស្ស និស្សិតប្រមាណ១០០ ទៅ១៥០នាក់ បានចូលមកអានសៀវភៅសិក្សាស្រាវជ្រាវ ព្រោះនៅបណ្ណាល័យជាតិមានផ្ទុកសៀវភៅ ឯកសារ អនុក្រឹត្យនានាទាំងអស់ តែសម្រាប់ទម្លាប់អានរបស់ប្រជាជនកម្ពុជាគឺនៅមានកម្រិតតិចតួចនៅឡើយ។ ចំណែកលោក ហុក សិទ្ធ នាយកអង្គការស៊ីប៉ា និងជាប្រធានសមាគមបណ្ណារក្ស និងឯកសារវិទូកម្ពុជា បានថ្លែងថា ការបង្កើតទិវាជាតិអំណានរបស់រាជរដ្ឋាភិបាល គឺបង្កើតឲ្យមានព្រឹត្តិការណ៍ជាថ្នាក់ជាតិ បណ្តុះគំនិតដល់ពលរដ្ឋក្នុងការទម្លាប់អាន។ លោកថា ការអានរបស់ប្រជាពលរដ្ឋកម្ពុជានៅមានកម្រិតដោយសារយើងធ្លាប់ឆ្លងកាត់សង្គ្រាម ចំណាកស្រុក ខ្វះសៀវភៅអាន និងខ្វះអ្នកនិពន្ធជាដើម។ លោកបានបន្តថា យើងសង្ឃឹមថានឹងមានផលវិជ្ជមាន ដែលជាកម្លាំងរួមគ្នាពញ្ញាក់អារម្មណ៍ ឲ្យប្រជាជនយើងមានទម្លាប់អាន ព្រោះយើងដឹងហើយថា អានច្រើន ចេះច្រើន។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងអនុវត្តនូវកំណែទម្រង់វិស័យអប់រំដោយផ្តោតលើសសរស្តម្ភចំនួន៥គឺ ទី១៖ ការអនុវត្តផែនការសកម្មភាពនៃគោលនយោបាយគ្រូបង្រៀន ទី២៖ ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ព្រមទាំងការធ្វើឲ្យប្រសើរ

ឡើងនូវបរិស្ថានសាលារៀន ទី៣៖ ការធ្វើអធិការកិច្ច ទី៤៖ ការពង្រឹងការវាយតម្លៃការសិក្សា និងទី៥ ៖ ការធ្វើកំណែទម្រង់ការសិក្សានៅថ្នាក់ឧត្តមសិក្សា។ ជាងនេះទៅទៀត ស្របតាមសសរស្តម្ភទី២គឺការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ព្រមទាំងការធ្វើឲ្យប្រសើរឡើងនូវបរិស្ថានសាលារៀន ក្រសួងអប់រំយុវជន និងកីឡា បានធ្វើការកែលម្អកម្មវិធីសិក្សាលើសៀវភៅសិក្សាគោលថ្មីពីថ្នាក់ទី១ដល់ទី៣ ក្នុងឆ្នាំ២០១០ និងដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ២០១១-២០១២-២០១៣ នៅទូទាំងប្រទេស ក្នុងគោលបំណងជួយដល់គ្រូងាយស្រួលក្នុងការបង្រៀនអំណាន និងដើម្បីបញ្ឈប់កង្វល់ពីមុនដែលការអានរបស់សិស្សទទួលបានលទ្ធផលទាប ហើយមិនទទួលបានលទ្ធផលជោគជ័យ (ស្តង់ដាអំណាន) (https://khmer-lfrd.com/wpcontent/uploads)។

បន្ថែមលើនេះទៀត ដើម្បីជាការរួមចំណែកក្នុងការបណ្តុះនូវការអាន ធ្វើឱ្យកុមារឆាប់ចេះអានចេះសរសេរ មានភាពប្រសើរឡើងផ្នែកអំណានថែមទៀត ដោយគិតចាប់ពីថ្នាក់ដំបូងឡើងទៅ ទើបក្រសួងអប់រំ យុវជន និងកីឡា ដោយមានកិច្ចសហការជាមួយអង្គការដៃគូគាំទ្រអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា បានបង្កើតឡើងនូវកម្មវិធីមួយដែលមានឈ្មោះថា«កញ្ចប់អំណានថ្នាក់ដំបូង»។ នាដើមឆ្នាំ២០១៧ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID)បានចាប់ផ្តើមនូវកម្មវិធីថ្មីមួយហៅថា «កម្មវិធីអំណានថ្នាក់ដំបូង» (Early Grade Reading) ដើម្បីជួយដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអភិវឌ្ឍនូវកម្មវិធីអំណានដំបូងថ្នាក់ជាតិមួយប្រកបដោយភាពស៊ីសង្វាក់ និងស្ថិតស្ថេរ។ កម្មវិធីដែលមានរយៈពេលប្រាំឆ្នាំនេះ (២០១៧ ដល់២០២១) នឹងជួយធ្វើឱ្យប្រសើរឡើងនូវជំនាញក្នុងការអានរបស់កុមារដែលសិក្សានៅថ្នាក់ទី១ ដល់ថ្នាក់ទី៣ ដោយផ្អែកលើវិធីសាស្ត្រមួយទៀងទាត់ ដែលអាចធ្វើបាន និងមានភាពប្រាកដប្រជាក្នុងប្រទេសកម្ពុជា និងដែលអាចយកទៅអនុវត្តបាននៅទូទាំងប្រទេស។ ដោយមានការជួយផ្នែកបច្ចេកទេសដល់ក្រសួងអប់រំ និងតាមរយៈការផ្តល់នូវការបណ្តុះបណ្តាលសមត្ថភាព ដល់នាយកដ្ឋានបច្ចេកទេសសំខាន់ៗមួយចំនួនរបស់ក្រសួងលើគោលបំណងជាក់លាក់មួយចំនួនរួមមាន៖

- ការធ្វើអោយប្រសើរឡើងនូវសមត្ថភាពរបស់ក្រសួងអប់រំ ដើម្បីអាចគ្រប់គ្រងកម្មវិធី អំណានដំបូងអោយកាន់តែមានប្រសិទ្ធភាពនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់សាលា

- ការពង្រឹងភាពជាដៃគូ និងភាពជាប់ទាក់ទងគ្នា ដើម្បីគាំទ្រដល់គោលដៅនៃកម្មវិធីអំណានដំបូងក្នុងប្រទេសកម្ពុជា

- ធ្វើកិច្ចសហការ និងការធ្វើអោយមានភាពចុះសម្រុងនៃកម្មវិធីអំណានដំបូង និងការសរសេរកម្មវិធីសិក្សាដែលត្រូវបានគាំទ្រ និងអនុវត្តនៅថ្នាក់ទី១រហូតដល់ថ្នាក់ទី៣។

ជាពិសេស កម្មវិធីនេះនឹងធ្វើសមាហរណកម្មនូវគំនិតនៃការអប់រំ ប្រកបដោយបរិយាបន្ន ទៅក្នុងកិច្ចអន្តរាគមន៍ នៃកម្មវិធីអំណានដំបូង ដើម្បីឱ្យកុមារគ្រប់រូប រួមទាំងកុមារដែលមានពិការភាពកម្រិតស្រាល មធ្យម និងធ្ងន់ អាចទទួលបាននូវសេវាអប់រំនៅថ្នាក់បឋមសិក្សា ប្រកបដោយគុណភាព (https://www.usaid.gov/node)។

បន្ទាប់មកនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចជ្រើសរើសយកខេត្តកំពង់ធំជាខេត្តគោលដៅ សម្រាប់បើកវគ្គបំប៉នស្តីពី **«ការអនុវត្តសាកល្បងកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូងដល់លោកគ្រូ-អ្នកគ្រូថ្នាក់ទី១»** ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។ ឯកឧត្តមបានមានប្រសាសន៍ថា ការបើកវគ្គសិក្ខាសាលានេះគឺដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣។ ក្នុងនោះក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំរួមមាន៖

**ទី១៖** កំណែទម្រង់គ្រប់គ្រងការសិក្សាផ្តោតលើការវាយតម្លៃរបស់សិស្ស

**ទី២៖** កំណែទម្រង់គ្រប់គ្រងរដ្ឋបាល ផ្តោតលើការជានា ការចូលរួមរបស់មាតាបិតាសិស្សនិងសហគមន៍ការអនុវត្តគ្រប់គ្រងតាមសាលារៀន និងការអនុវត្តផែនកាយុទ្ធសាស្ត្រវិស័យអប់រំ កំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុ ផ្តោតការបង្កើនស្វ័យភាព និងគណនេយ្យភាពហិរញ្ញវត្ថុសាលារៀន ការធ្វើ

សវនកម្មថវិកាអប់រំជាទៀងទាត់ បង្កើនការបែងចែកថវិកា ផ្សារភ្ជាប់នឹងគោលការរអប់រំ៤ កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស ផ្តោតលើការបណ្តុះបណ្តាលដោយវិធីសាស្ត្របង្រៀន និងកម្មវិធីបំប៉ននៅនឹងកន្លែង បង្កើនបណ្តុះបណ្តាលគ្រូបង្រៀន និងអនុវត្តវាយតម្លៃការងារការបន្តអភិវឌ្ឍ សមត្ថភាពវិជ្ជាជីវៈជាប្រចាំ គឺទាមទារឱ្យមានកម្មវិធីបំប៉នច្បាស់លាស់មានសម្ភារ និងឯកសារបំប៉នប្រកបដោយគុណភាព និងត្រូវមានគ្រូឧទ្ទេស ប្រកបដោយសមត្ថភាព និងបំណិនខ្ពស់។ តាមរយៈកម្មវិធីនេះ គ្រូបង្រៀនទាំងអស់នឹងទទួលបានការបំប៉នយ៉ាងទៀងទាត់ ឆ្លើយតបទៅនឹងចំណុចខ្វះខាតដែលពួកគាត់មាន និងការសិក្សា ដើម្បីឆ្លើយតបទៅនឹងសំណូមពរខាងលើនេះ ក្រសួងបាន និងកំពុងដឹកនាំ ក្រោមការសម្របសម្រួលរបស់អង្គការ (RTI) ព្រមទាំងមានការចូលរួម ពីដៃគូពាក់ព័ន្ធ ផលិតបាននូវសម្ភារ និងឯកសារបំប៉នផ្អែកតាមបទពិសោធន៍ និងលទ្ធផលនៃការអភិវឌ្ឍកន្លងមក ដោយមានឈ្មោះថា កញ្ចប់សម្ភារអំណានថ្នាក់ដំបូង សៀវភៅណែនាំគ្រូ សៀវភៅជំនួយសិស្ស ប័ណ្ណអក្សរ និងរូបភាព និងសៀវភៅរឿងខ្លីៗ។ សម្ភារទាំងនេះ គឺត្រូវបំប៉នលោកគ្រូ-អ្នកគ្រូ បង្រៀនថ្នាក់ទី១ រយៈពេល៩ថ្ងៃ ដែលពេលនោះមានរយៈពេល៤ថ្ងៃ អំឡុងខែធ្នូ និងទទួលបានការបំប៉ន រយៈពេលបីថ្ងៃចុងក្រោយ អំឡុងខែមីនា ហើយអ្វីដែលលោកគ្រូ-អ្នកគ្រូទទួលបានពីការបំប៉ន អាចយកទៅអនុវត្តបានត្រឹមត្រូវទៀងទាត់ចុងក្រោយ គឺសិស្សថ្នាក់ទី១ ទទួលបានអំណានទាំងអស់គ្នា។ លោក ចន ខូលីន តំណាងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិកប្រចាំកម្ពុជា បានថ្លែងថាគម្រោងអនុវត្តនេះ គឺជួយពង្រឹងថ្នាក់ដំបូងនៅកម្ពុជា។ គម្រោងនេះ ត្រូវបានអនុវត្តនៅក្នុង៤០ប្រទេស ហើយមានកុមារប្រហែល៧០លាននាក់ កំពុងបានទទួលផល នៃការអនុវត្តគម្រោង និងការកសាងឯកសារកញ្ចប់សម្ភារអំណានដំបូង សម្រាប់វគ្គបំប៉ននេះ មានការដឹកនាំដោយក្រសួងអប់រំ និងមានការចូលរួមចែករំលែកពីអង្គការដៃគូពាក់ព័ន្ធ អ្នកឯកទេសអប់រំ និងគ្រូ។ ជាមួយគ្នានោះដែរលោក ហួន វ៉ាន់និត អភិបាលរងខេត្តកំពង់ធំ បានថ្លែងថា ក្នុងនាមជាអាជ្ញាធរខេត្តបានថ្លែងអំណរគុណដល់ក្រសួងអប់រំ និងមន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់ទាំងអស់ ព្រមទាំងដៃគូអភិវឌ្ឍន៍បានជ្រើសរើសយកខេត្តកំពង់ធំ ជាខេត្ត

គោលដៅបើកវគ្គបំប៉នសាកល្បងគម្រោង និងខិតខំជំរុញឱ្យវិស័យអប់រំទទួលបាននូវការរីកចម្រើនគួរជាទីមោទកភាព ក្រោមការដឹកនាំ ប្រកបដោយគតិបណ្ឌិតរបស់សម្ដេចតេជោ ហ៊ុន សែន ព្រោះថាវគ្គបំប៉ននេះមានសារៈសំខាន់ដល់មន្ត្រីគ្រប់គ្រង និងគ្រូបង្រៀនគ្រប់លំដាប់ថ្នាក់ ព្រោះវគ្គបំប៉ននេះនឹងផ្ដល់ចំណេះដឹង និងបច្ចេកទេសបង្រៀន អំពីការអាន សរសេរ របស់សិស្សថ្នាក់ទី១ ដល់លោកគ្រូអ្នកគ្រូទូទាំងខេត្ត ព្រមទាំងយល់ដឹងពីវិធីសាស្ត្របង្រៀន ឱ្យមានភាពច្បាស់លាស់ប្រកបដោយប្រសិទ្ធភាព និងគុណភាពកាន់តែប្រសើរឡើង ( http://freshnewsasia.com/index.php/en/localnews )។

ក្រោយមក នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីបើកសិក្ខាសាលាបំប៉នគ្រូបង្រៀនថ្នាក់ទី១ និងថ្នាក់ទី២ ស្ដីពីការប្រើប្រាស់កញ្ចប់សម្ភារអំណានថ្នាក់ដំបូង នៅសាលាបឋមសិក្សាទៀបាញ់គំរូ ស្ថិតនៅស្រុកពួក ខេត្តសៀមរាប។ ឯកឧត្តមបានមានប្រសាសន៍ថាបន្ទាប់បានចុះសិក្សាដោយផ្ទាល់នៅតាមសាលារៀនឃើញថា អត្រាសិស្សមិនចេះអានអក្សចាប់ពីថ្នាក់ទី៥ចុះក្រោម គឺនៅមានកម្រិតខ្ពស់ បើធៀបជាមួយប្រទេសនៅក្នុងតំបន់។ ប៉ុន្តែបន្ទាប់ពីក្រសួងបានបំប៉នគ្រូបង្រៀនថ្នាក់ទី១ និងថ្នាក់ទី២ ស្ដីពីការប្រើប្រាស់កញ្ចប់សម្ភារអំណានថ្នាក់ដំបូងនៅក្នុងរយៈពេល២ឆ្នាំមកនេះ អត្រាសិស្សចេះអានអក្សរក៏មានការល្អប្រសើរជាងមុន។ ឯកឧត្តមបានមានប្រសាសន៍ថាផងដែរថា នៅក្នុងការប្រឡងជាមួយបណ្ដាប្រទេសនានានៅក្នុងតំបន់កន្លងមកនេះ ឃើញថា ផ្នែកគណិតវិទ្យាសិស្សកម្ពុជាធ្វើបានល្អ ប៉ុន្តែសម្រាប់អំណានវិញយើងនៅទាបជាងគេនៅឡើយ ដែលបញ្ហានេះក្រសួងអប់រំបានខិតខំធ្វើកំណែទម្រង់ ជាពិសេសកំណែទម្រង់គ្រូបង្រៀន ដោយបានដាក់ឱ្យប្រើប្រាស់កញ្ចប់សម្ភារអំណានថ្នាក់ដំបូង ដែលរួមមានសៀវភៅណែនាំគ្រូ សៀវភៅជំនួយសិស្ស ប័ណ្ណអក្សរ រូបភាព និងសៀវភៅរឿងខ្លីៗ។ ឯកឧត្តមបានបញ្ជាក់ថា សម្ភារទាំងនេះត្រូវបានបំប៉នជូនលោកគ្រូ អ្នកគ្រូដែលបង្រៀនថ្នាក់ទី១ ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណវុឌ្ឍិរបស់គ្រូបង្រៀន ជាពិសេសបច្ចេកទេសក្នុងការបង្រៀន និងរៀនការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំ(https://www.information.gov.kh/articles)។

## ១.២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ថ្មីៗនេះមានការលើកកម្ពស់ប្រសិទ្ធភាពអំណានសម្រាប់កុមារកម្ពុជា ហើយតាំងពីមានការកែទម្រង់កម្មវិធីសិក្សាទូទៅថ្នាក់ជាតិមកពីឆ្នាំ២០១០ ដល់ ២០១៣ ក៏ដោយ តាមរបាយការណ៍របស់ World Bank កាលឆ្នាំ ២០១៤ ថាជាទូទៅពិន្ទុអំណាននៅតែទាបមិនអាចទទួលយកបាន ព្រមទាំងឃើញថា កុមារជាង២៥% នៅតែមានសមត្ថភាពអានទាបជាងស្តង់ដា។ ពីព្រោះថាសមត្ថភាពអាន គឺជាមូលដ្ឋានគ្រឹះសម្រាប់រៀនមុខវិជ្ជាដទៃទៀត ហើយការធ្លាក់ចុះនៃប្រព័ន្ធអប់រំ ក្នុងការសម្រេចបានប្រសិទ្ធភាពខ្ពស់នៃអំណាននៅថ្នាក់ដំបូង(ទី១ ទី២ និងទី៣) ធ្វើឱ្យលទ្ធផលសិក្សាធ្លាក់ចុះនៅឆ្នាំសិក្សាបន្តបន្ទាប់ (http://www.kapekh.org/kh)។

ទោះបីស្ថានភាពកុមារមានភាពប្រសើរឡើងនៅកម្ពុជាក៏ដោយ ក៏សូចនាករសំខាន់ៗរួមមានការទទួលបានការអភិវឌ្ឍ និងការអប់រំកុមារតូចនៅតែជាបញ្ហាប្រឈម។ វិសមភាពនៅតែបន្តកើតមានទាក់ទងនឹងប្រាក់ចំណូលភេទ ឬពិការភាព។ បើនិយាយពីការអភិវឌ្ឍ និងការអប់រំកុមារតូចៗ ៣៣ភាគរយ នៃកុមារថ្នាក់ទី២ មិនអាចអានពាក្យដែលធ្លាប់ស្គាល់ និងច្រើនជាង ៣៦ភាគរយនៃកុមារអាយុ៥ឆ្នាំ មិនបានចុះឈ្មោះក្នុងការអប់រំណាមួយឡើយ។ កុមារពិការងាយនឹងបាត់បង់ការសិក្សាទ្វេដង បើប្រៀបធៀបនឹងសិស្សដែលមិនមានពិការភាព ហើយមានតែក្មេងជំទង់៤ភាគរយប៉ុណ្ណោះដែលបានបញ្ចប់ការសិក្សាមធ្យមសិក្សាទុតិយភូមិ បើប្រៀបធៀបទៅនឹងមិត្តភ័ក្ត្រជនពិការ៤១ភាគរយ។ (**https://cambodia.savethechildren.net 2018**)

ដោយឡែកក្នុងឆ្នាំសិក្សា២០១៧-២០១៨ ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើ ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍនានាបានបង្កើតកញ្ចប់សម្ភារៈអំណានដំបូងឡើងដើម្បីពង្រឹងគុណភាពអប់រំនៅកម្ពុជា។ ផ្អែកតាមរបាយការណ៍ទៅលើការធ្វើតេស្តអ៊ីហ្គ្រា(EGRA) បានបង្ហាញថា ចំនួនសិស្សចេះអានបានស្មើនឹង៦៨% លទ្ធផលនេះសបញ្ជាក់ឲ្យឃើញថាការអានរបស់សិស្សមានការរីកចម្រើន និងជោគជ័យគួរឲ្យកោតសរសើរ។

ជាមួយគ្នានេះ ខេត្តកំពង់ឆ្នាំងក៏មានការអនុវត្តកម្មវិធីកញ្ចប់អំណាននេះផងដែរ តាមរយៈអង្គការ Save the Children ក្រោមកិច្ចគាំទ្ររបស់គម្រោង EQUAL បានអនុវត្តកម្មវិធីនេះនៅក្នុងសាលាទាំង២០ របស់គម្រោង ដែលមានថ្នាក់ទី១ និងថ្នាក់ទី២។

## ១.៣.គោលបំណង និងសារៈសំខាន់នៃការស្រាវជ្រាវ

ដោយមើលឃើញពីលទ្ធផលនៃការអនុវត្តសាកល្បង នូវកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងនៅខេត្តកំពង់ធំ ព្រមទាំងការលើកសរសើររបស់លោកគ្រូ អ្នកគ្រូ ដែលបានអនុវត្តកម្មវិធីនេះ ថាល្អ ធ្វើឱ្យកុមារឆាប់ចេះអាន និងទទួលបានលទ្ធផលល្អក្នុងការសិក្សា។ ម្យ៉ាងទៀតដោយការចង់ដឹងពីស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់លោកគ្រូ អ្នកគ្រូដែលបង្រៀននៅថ្នាក់ទី២ នៅសាលាបឋមសិក្សាទាំង២០ ក្នុងខេត្តកំពង់ឆ្នាំង លើការបង្រៀនកន្លងមក នៅសាលារៀនរបស់ខ្លួនថាតើអនុវត្ត និងមានដំណើរការទៅយ៉ាងដូចម្តេច។ ដូចនេះជារួមមក ក្នុងការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទនេះដែរ ក៏មានគោលបំណងសំខាន់ៗចំនួនពីរផងដែរគឺ៖

- ការយល់ឃើញរបស់ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូលើការអនុវត្តកម្មវិធីកញ្ចប់អំណានកន្លងមក
- លទ្ធផលនៃការសិក្សារបស់សិស្សលើផ្នែកអំណាន

ហេតុផលទាំងនេះហើយ ទើបធ្វើឱ្យខ្ញុំបាទចង់ដឹង និងលើកយកប្រធានបទមួយមកធ្វើការសិក្សាស្រាវជ្រាវគឺ «ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងក្នុងខេត្តកំពង់ឆ្នាំង» ដោយផ្តោតសំខាន់លើថ្នាក់ទី២តែម្តង។

ក្នុងនាមជាបុគ្គលិកអប់រំ ក៏ដូចជាអ្នកស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រអប់រំផងដែរនោះ យើងនឹងចាប់ផ្តើមធ្វើការស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់អស់ពីសមត្ថភាព ទៅលើប្រធានបទខាងលើនេះដើម្បីសិក្សាស្វែងយល់អំពីអ្វីៗដែលទាក់ទងការអនុវត្តកម្មវិធីកញ្ចប់អំណានរបស់លោកគ្រូ អ្នកគ្រូរួមមានសមត្ថ

ភាព ចំណេះដឹង ចំណេះធ្វើបទពិសោធ និងធនធាននានាដែលមានស្រាប់ សម្រាប់ការអនុវត្តកញ្ចប់អំណានដំបូងនៅសាលាបឋមសិក្សារបស់ពួកគាត់។ការសិក្សាស្រាវជ្រាវនេះនឹងផ្តល់ជាព័ត៌មានសម្រាប់ថ្នាក់ដឹកនាំក្រសួងអប់រំ និងដៃគូអភិវឌ្ឍការអប់រំ អ្នកសិក្សាជំនាន់ក្រោយៗ ដើម្បីយកទៅសិក្សាបន្ត និងអ្នកដែលពាក់ព័ន្ធទាំងអស់នានា ជាពិសេសគឺថ្នាក់ដឹកនាំក្រសួងអប់រំធ្វើការវិភាគ និងអាចដាក់ឲ្យថ្នាក់ក្រោមជាតិអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងនេះនៅទូទាំងប្រទេសឆាប់ៗនាពេលខាងមុខ។

## ១.៤.សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណង និងដើម្បីឲ្យការសិក្សាស្រាវជ្រាវមានលក្ខណៈស៊ីជម្រៅបែបវិទ្យាសាស្ត្រ ខ្ញុំបាទបានដាក់ចេញនូវសំណួរស្រាវជ្រាវដូចខាងក្រោម៖

១. តើលោក លោកស្រីយល់ឃើញយ៉ាងណាដែរ ចំពោះកម្មវិធីកញ្ចប់អំណាននេះ?

២. តើសមត្ថភាពអំណានរបស់សិស្សពេលបានអនុវត្តកញ្ចប់អំណានហើយ មានភាពរីកចម្រើនយ៉ាងណាខ្លះ?

## ១.៥.ដែនកំណត់ និងវិសាលភាព

ដើម្បីឲ្យការស្រាវជ្រាវមានលក្ខណៈបែបវិទ្យាសាស្ត្រពិតប្រាកដ ប្រកបដោយប្រសិទ្ធភាព និងដើម្បីឲ្យការសិក្សាស្រាវជ្រាវកាន់ស៊ីជម្រៅ ខ្ញុំបាទនឹងលើកយកកត្តាមួយចំនួនដែលមាននៅសាលាបឋមសិក្សាមកសិក្សាស្រាវជ្រាវដូចជា៖

កត្តាមនុស្សគឺ សំដៅដល់សមត្ថភាពលោកគ្រូ អ្នកគ្រូ នាយក ប្រធានក្រុមបច្ចេកទេស និងថ្នាក់ដឹកនាំការិយាល័យអប់រំស្រុក។

កត្តាធនធានដែលមានស្រាប់ក្នុងអង្គភាព គឺសំដៅដល់សាលារៀន គ្រូ សិស្ស កម្មវិធីសិក្សាសៀវភៅសិស្ស សៀវភៅណែនាំគ្រូពីវិធីសាស្ត្របង្រៀន សម្ភារៈឧបទេស និងកញ្ចប់ថវិកាដំណើរការសាលារៀន ។

អាស្រ័យដោយថវិកា និងពេលវេលាមានកំណត់ ខ្ញុំបាទកំណត់យកករណីសិក្សានៅខេត្តកំពង់ឆ្នាំង ចំនួន៣ស្រុក មានស្រុករលាប្អៀរ ស្រុកកំពង់ត្រឡាច និងស្រុកសាមគ្គីមានជ័យ(ទីប្រជុំជន និងជនបទ) ដែលមានសាលាសរុបចំនួន២០សាលារៀន ការិយាល័យអប់រំស្រុកចំនួន៣ មកធ្វើជាភាគសំណាក។ ចំពោះក្រុមគោលដៅដែលនឹងត្រូវធ្វើការប្រមូលព័ត៌មាន គឺត្រូវបំពេញកម្រងសំណួររួមមានដូចជា៖

- ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក ចំនួន៣នាក់

- នាយកសាលាចំនួន ២០នាក់

- ប្រធានក្រុមបច្ចេកទេសចំនួន ២០នាក់

- លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ ចំនួន ៣១នាក់

-សរុបរួម ៧៤នាក់

## ១.៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

លទ្ធផលស្រាវជ្រាវត្រូវបានរៀបចំជានិក្ខេបបទ សម្រាប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំមាន ៥ជំពូកដូចខាងក្រោម៖

**ជំពូកទី១៖ សេចក្តីផ្តើម**

ជំពូកនេះបង្ហាញអំពី សារតារនៃការស្រាវជ្រាវ ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ វិសាលភាពនិងដែនកំណត់សារៈសំខាន់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធ និងគម្រោងស្រាវជ្រាវ នៃនិក្ខេបបទទាំងមូល។

**ជំពូកទី២៖ រំលឹកទ្រឹស្តី**

ជំពូកនេះរៀបរាប់អំពីទ្រឹស្តីនិង វិធីសាស្ត្របង្រៀនកញ្ចប់អំណានទាំងឡាយណាដែលទាក់ទៅនឹងប្រធានបទទាំងមូល ដែលមានដូចជា ៖ ប្រវត្តិនៃអំណាន និយមន័យនៃអំណាន និយមន័យកញ្ចប់

អំណានដំបូង ហេតុដែលនាំឲ្យមានការបង្រៀនអំណានដំបូង ការបង្រៀនអំណានដំបូង វិធីសាស្ត្របង្រៀនអំណានដំបូង បំណិនទាំង៥នៃអំណាន សកម្មភាពគោលទាំង៧នៃអំណានដំបូង ។

**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ**

បង្ហាញអំពីគម្រោងដំណើរការស្រាវជ្រាវមានដូចជា៖ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ ទីកន្លែងសិក្សាស្រាវជ្រាវ ការជ្រើសរើសភាគសំណាក ឧបករណ៍ស្រាវជ្រាវ កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ កម្រងសំណួរសម្រាប់ថ្នាក់ដឹកនាំការិយាល័យអប់រំស្រុក កម្រងសំណួរសម្រាប់នាយកសាលា កម្រងសំណួរសម្រាប់ប្រធានក្រុមបច្ចេកទេស កម្រងសំណួរសម្រាប់គ្រូបន្ទុកថ្នាក់ទី២ ដំណើរការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ ។

**ជំពូកទី៤៖ លទ្ធផល និងការវិភាគ**

រៀបរាប់ពីលក្ខណៈជាក់ស្តែងដែលបានធ្វើការស្រាវជ្រាវ និងវិភាគទៅលើព័ត៌មានទាំងអស់ដែលបានចុះប្រមូលតាមសាលារៀនជាក់ស្តែង ថាតើវាដូចទៅនឹងទ្រឹស្តីដែរឬទេ? គឺក្នុងគោលបំណងរកឲ្យឃើញភាពដែលអាចធ្វើទៅបានដោយមានចំណេះដឹង ចំណេះធ្វើ បទពិសោធ និងធនធានដែលមានស្រាប់ក្នុងការអនុវត្តអំណានកញ្ចប់អំណានថ្នាក់ដំបូង នៅសាលាបឋមសិក្សាដែលយកចេញពីការវិភាគកម្រងសំណួរ ។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

ធ្វើការសន្និដ្ឋានទៅលើរាល់គ្រប់ចំណុចទាំងអស់ដែលបានវិភាគលើលទ្ធផល នៃការស្រាវជ្រាវ និងផ្តល់យោបល់បន្ថែម ។

# ជំពូក២

# រំឭកទ្រឹស្តី

## ២.១.ប្រវត្តិនៃអំណាន

### ២.១.១.និយមន័យនៃអំណាន

«អំណាន» អ្នកណាក៏តែងតែស្គាល់ និងធ្លាប់ឮវាជារៀងរាល់ថ្ងៃ។ ប៉ុន្តែ បើយើងក្រឡេកទៅរកការផ្តល់និយមន័យ គឺមិនសូវជាមានការបកស្រាយច្រើនទេ។ ចំពោះពាក្យថា «អំណាន» គឺមានការឱ្យនិយមន័យផ្សេងៗគ្នា តែបើយោងលើអត្ថន័យជារួមគឺពុំសូវមានលក្ខណៈឃ្លាតឆ្ងាយពីគ្នាប៉ុន្មានឡើយ។ ខាងក្រោមនេះ ជានិយមន័យនៃ «អំណាន» ទៅតាមការយល់ឃើញរបស់លោកអ្នកប្រាជ្ញខាងអក្សរសាស្ត្រខ្មែរ ដោយការដកស្រង់ពីវចនានុក្រមខ្មែរ វេបសាយ( website) ហ្វេសប៊ុកផេក facebook page ជាដើម។

តើ «អំណាន» គឺជាអ្វី?

១. «អំណាន» ជាទម្រង់នៃការកសាងអត្ថន័យចេញពីអត្ថបទ។ វាជាជំនាញស្មុគស្មាញមួយដែលទាមទារឲ្យមានការសម្របសម្រួលប្រភពទាក់ទងគ្នាទៅវិញទៅមកនៃព័ត៌មាន។

២. «អំណាន» ជាទម្រង់ចំណេះដឹងនៃការទាញយកអត្ថន័យពីអត្ថបទដែលបានសរសេរ ឬបោះពុម្ពផ្សាយ ។

៣. «អំណាន» ជាទម្រង់នៃការចងចាំ និងការយល់អត្ថន័យនៃគំនិត ឬព័ត៌មានដែលបានរក្សាទុកមក ។

៤. «អំណាន» គឺជាទម្រង់ទទួលដឹងឮដ៏ស្មុគស្មាញមួយដែលទាក់ទងដល់ការបកស្រាយអក្សរ ឬនិមិត្តសញ្ញាសម្ងាត់ ក្នុងបំណងស្ថាបនា ឬទាញយកអត្ថន័យពីអក្សរ ឬនិមិត្តសញ្ញាទាំងនោះ។ វាជាចំណែកដ៏សំខាន់មួយនៃជីវិតប្រចាំថ្ងៃរបស់មនុស្ស ហើយវាក៏មានសមត្ថភាពជួយយើងក្នុងការធ្វើអន្តរកម្ម និងការយល់ដឹងពីពិភពនានាដែលកំពុងនៅជុំវិញខ្លួនយើង។ អ្នកអានទាំងឡាយអាចនឹងប្រើចំណែកដ៏ស្លួចស្លើងបំផុតនៃភាសាដែលមានអត្ថន័យដោយខ្លួនឯង ជាជាងពាក្យ ឬផ្នែករបស់ពាក្យ ការសិក្សាអត្ថ

ន័យទាំងឡាយក្នុងភាសា និងលំដាប់ពាក្យក្នុងលំដាប់ណាមួយ ព្រមទាំងស្លាក ស្នាមបរិបទ (អត្ថបទទាំងមូលដែលនៅពីមុខ ឬពីក្រោយប្រយោគ/សំនួនសេចក្តីមួយ) ដើម្បីស្គាល់អត្ថន័យ ពាក្យទាំងឡាយដែលមិនស្គាល់។ វិធីសាស្ត្រអំណានទាមទារឲ្យបន្តការអនុវត្ត ការអភិវឌ្ឍ ក៏ដូចជាការធ្វើឲ្យកាន់តែប្រសើរឡើងខាងការយល់ដឹង ។

៥. «អំណាន» គឺជាជំនាញ ឬសកម្មភាពនៃការទទួលព័ត៌មានចេញពីសៀវភៅ ឬឯកសារនានា ។

៦. «អំណាន» គឺជាឱកាស នៅពេលអ្វីមួយដែលគេបានសរសេរ ជាពិសេសទាក់ទងនឹងកិច្ចការអក្សរសាស្ត្រ ដែលត្រូវបានគេនិយាយទៅកាន់អ្នកស្តាប់។

៧. «អំណាន» គឺជារបៀបនៃការយល់ដឹងពីអ្វីមួយដែលគេបានសរសេរ ចង់ប្រាប់ ចង់បង្ហាញ។

៨. «អំណាន» គឺជាការមើល ឬការថាតាមអក្សរ។

៩. យោងតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលបោះពុម្ពដោយពុទ្ធសាសនបណ្ឌិត ឱ្យនិយមន័យថា «អំណាន» គឺជាការស្វែងយល់ ការដុះខាត់គំនិត ឬការយល់ដឹងពីគំនិតដែលគេបានសរសេរ ឬបានគូសវាសប្រាប់ឲ្យមានភាពភ្លឺថ្លានៅក្នុងខ្លួន(ខួរក្បាល-អារម្មណ៍)របស់អ្នកទទួល(អ្នកអាន) ឬការមើលថាតាមអក្សរ។ (ភ្នំពេញថ្ងៃទី០៦ កុម្ភៈ ឆ្នាំ២០១៥ ប្រែសម្រួលពី ឯកសារបរទេស ដោយលោក ឃី ឆេងអ៊ួ(ប៉េង)ប្រធានបណ្ណាល័យCICI (https://l.facebook.com/l.php?u =http%3A%2F%2Fsmaradeykhmer.org)។

១០. តាមសៀវភៅ ភាសាអង់គ្លេស (**Arab Ideal**) លោកបានពន្យល់ថា៖

- «អំណាន ឬការអាន» គឺសំដៅដល់ការ សម្លឹងមើល និងយល់ដឹងពីន័យសេចក្តី នៃពាក្យពេចន៍ដែលបានសរសេរ ឬបោះពុម្ព។

- «អំណាន» គឺជាការនិយាយឮៗនូវពាក្យដែលបានសរសេរ ឬបោះពុម្ពផ្សាយ។

- «អំណាន ឬការអាន» មានន័យថា ការស្វែងយល់ពីអត្ថន័យនៃពាក្យពេចន៍ ដែលបានបង្កប់ដែលមិនបានបង្ហាញឲ្យឃើញភ្លាមៗ។

- «អំណាន» មានន័យថា ជាសកម្មភាព នៃការស្វែងយល់ពីអត្ថន័យ នៃពាក្យពេចន៍ ដែលបានសរសេរ ឬបោះពុម្ពផ្សាយ។(គល់រាំង - ភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ៖ មនោរម្យព័ងអាំងហ្វូ Crédit photo : Lori-Ga!/flickr.com)។

## ២.១.២. ដើមកំណើតនៃអំណាន

តើអំណាន បានចាប់កំណើតតាំងពីពេលណាមក និងតាមមធ្យោបាយអ្វីខ្លះ?

អំណានត្រូវបានចាប់កំណើតឡើង តាំងតែពីមានជីវិតមនុស្សមកម្ល៉េះ។ ជាដំបូង មនុស្សអានតាមរយៈកាយវិការ សំឡេង សញ្ញា និងរូបភាពផ្សេងៗ ដូចជា កាយវិការដេក ដើរ ឈរ អង្គុយ សកម្មភាពប្រចាំថ្ងៃរបស់សត្វ ប្រភេទសញ្ញាបាតុភូតធម្មជាតិ ស្នាមជើងមនុស្ស និងសត្វ លាមកសត្វ គុម្ពោធព្រៃដែលសត្វ ឬមនុស្សកាច់សម្គាល់ សូរសំឡេងមនុស្ស សត្វ និងធម្មជាតិជាដើម។

បន្ទាប់មកទៀត មនុស្សបានអាន តាមរយៈអក្សរ ដែលបានដាប់សម្គាល់នៅលើថ្ម បានចារនៅលើស្លឹករឹត និងស្បែកសត្វ បានសរសេរដោយដៃ នៅលើសន្លឹកសៀវភៅ បានបោះពុម្ពនៅលើសន្លឹកសៀវភៅដោយម៉ាស៊ីនអង្គុលីលេខ បានបោះពុម្ព នៅលើសន្លឹកសៀវភៅ ដោយគ្រឿងម៉ាស៊ីនទំនើប បានវាយបញ្ចូលក្នុងម៉ាស៊ីនកុំព្យូទ័រ ឬទូរស័ព្ទជាដើម។ អំណានខ្លះ ត្រូវបានគេធ្វើតាមរយៈម៉ាស៊ីនចាប់យករូបភាពវីឡេទាក់ទងសំឡេង គំនូរលើក្រដាស ម៉ាស៊ីនថតសំឡេង ឧបករណ៍ទាយ ពីចិត្តសាស្ត្រមនុស្ស ម៉ាស៊ីនឆ្លុះ...។ល។(គល់រាំង - ភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ៖ មនោរម្យព័ងអាំងហ្វូ Crédit photo : Lori-Ga!/flickr.com)។

## ២.១.៣. ប្រភេទនៃអំណាន

តើអំណានមានប៉ុន្មានប្រភេទ? អ្វីខ្លះ?

តាមការសង្កេត យើងអាចចែកអំណាន ជាបួនប្រភេទគឺ៖

**ក. អំណានក្នុងចិត្ត ឬអំណានស្ងាត់៖** គឺជាការអាន ដែលប្រើប្រាស់សកម្មភាពយល់ដឹង ពីពាក្យពេចន៍ ឃ្លាប្រយោគ ល្បះ អត្ថបទ កាយវិការ រូបភាព សូរសំឡេង ឬរលកគំនិតទាំងឡាយ តែក្នុងចិត្តពោលគឺ មិនប្រើប្រាស់សំឡេងខ្លួនឯង ចេញមកក្រៅអ្វីឡើយ។

**ខ. អំណានខ្សឹប៖** គឺជាការអាន ដែលប្រើប្រាស់សកម្មភាពយល់ដឹង ពីពាក្យពេចន៍ ឃ្លាប្រយោគ ល្បះ អត្ថបទ កាយវិការ រូបភាព សូរសំឡេង ឬរលកគំនិតទាំងឡាយ ដោយប្រើប្រាស់ សំឡេងតិចៗ ឬខ្សឹបៗចេញមកក្រៅ។

**គ. អំណានឮ៖** គឺជាការអាន ដែលប្រើប្រាស់សកម្មភាពយល់ដឹង ពីពាក្យពេចន៍ ឃ្លាប្រយោគ ល្បះ អត្ថបទ កាយវិការ រូបភាព សូរសំឡេង ឬរលកគំនិតទាំងឡាយ ដោយប្រើប្រាស់សំឡេងខ្លាំងៗចេញមកក្រៅ។

**ឃ. អំណានស្ទាប៖** គឺជាអំណាន ដែលភាគច្រើន ត្រូវបានប្រើប្រាស់ដោយជនពិការភ្នែក។ ពួកគេអានសៀវភៅ តាមរយៈសញ្ញា អក្សរស្ទាប។ អំណានប្រភេទនេះ គឺអ្នកអានអាចធ្វើតាមរយៈអំណានស្ងាត់ អំណានខ្សឹប ឬអំណានឮក៏បាន។(គល់រាំង - ភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ៖ មនោរម្យព័ត៌មានអាំងហ្វូ Crédit photo : Lori-Ga!/flickr.com)។

## ២.១.៤. ប្រភេទអ្នកអាន

**ក. អ្នកអានលម្អិត ឬអ្នកអានវិភាគ៖** ជាប្រភេទអ្នកអាន ដែលចូលចិត្តអាន ដោយយកការយល់គ្រប់ចំណុចសាច់រឿង ដែលបានសរសេរនៅក្នុងសៀវភៅ ឬអត្ថបទណាមួយ។ អ្នកអានប្រភេទនេះ ច្រើនតែជាអ្នកឯកទេសខាងការស្រាវជ្រាវអ្វីមួយ ព្រោះថាដើម្បីបានអំណះអំណាងមួយច្បាស់លាស់ លុះត្រាតែគេបានពិនិត្យល្អិតល្អន់ លើអ្វីដែលខ្លួនបានអាន។

**ខ. អ្នកអានត្រួសៗ ឬអ្នកអានរំលង៖** ជាប្រភេទអ្នកអានទាំងឡាយណា ដែលចូលចិត្តអានត្រឹមតែត្រួសៗ ដោយគ្រាន់តែចង់ដឹង ចំណែកណាមួយ ដែលគេចង់ដឹង ឬដែលគេមិនទាន់យល់ប៉ុណ្ណោះ។

ពួកគេច្រើនជាអ្នកអានឯកទេស និងជាអ្នកដែលមិនសូវមានពេលវេលាច្រើន សម្រាប់ការអាន។ គេចង់ប្រើប្រាស់ពេលវេលារបស់ខ្លួនឲ្យមានប្រសិទ្ធភាពបំផុត។

**គ. អ្នកអានកំសាន្ត៖** ជាប្រភេទអ្នកអានដែលបានចាត់ទុកថា ការអាន គឺជាផ្នែកមួយដែលជួយឲ្យអារម្មណ៍របស់គេ បានសប្បាយចិត្ត បានទទួលចំណេះដឹងថ្មីៗជាដើម។ គេជាមនុស្សដែលប្រកបដោយភាពជឿជាក់ ទៅលើទំនាក់ទំនងសង្គម។ គេមានគំនិតច្រើន ក្នុងការចែករំលែក ក៏ដូចជាការទទួលយកនូវចំណេះដឹងថ្មីៗ តាមរយៈសកម្មភាពអំណាន។

**ឃ. អ្នកអានបន្លប់ពេលវេលា៖** ជាប្រភេទអ្នកអាន ដែលខ្វះគោលបំណងពិតប្រាកដ អានក៏ព្រោះតែកាលៈទេសៈបង្ខំ អានក៏ព្រោះតែគ្មានអ្វីធ្វើល្អជាងនេះ ឬអានដោយរកគោលបំណង នៃការអានមិនឃើញ។ អ្នកអានប្រភេទនេះ គឺតម្រូវឲ្យមានការលើកទឹកចិត្ត ឲ្យបានច្រើនពីអ្នកឯកទេសអំណាន ឬពីគ្រួសារ និងមិត្តភក្តិរបស់ពួកគេ។(គល់វាំង - ភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ៖ មនោរម្យព័ងអាំងហ្វូ Crédit photo : Lori-Ga!/flickr.com)។

## ២.១.៥. ភាពចាំបាច់ក្នុងការអានសៀវភៅ

ហេតុអ្វីចាំបាច់អានសៀវភៅ?

ការអាន មានសារៈប្រយោជន៍គ្រប់វេលា មិនថាសម្រាប់ការសិក្សា ការងារ ឬការកម្សាន្តឡើយ។ មិនតែប៉ុណ្ណោះ ការអាន ថែមទាំងជួយបង្កើន ឲ្យខួរក្បាលលោកអ្នក មានភាពរហ័សរហួន ប្រាជ្ញាស្មារតីកាន់តែភ្លឺស្វាងថែមទៀតផង។ ការអាន អាចជួយឲ្យលោកអ្នក បានស្គាល់ប្រភេទមនុស្ស ហេតុការណ៍នានា ដែលបាន កំពុង ឬនឹងកើតមានឡើង ព្រមទាំងយល់ដឹង ពីពិភពចម្លែក ៗជាច្រើនទៀត។ ក្រៅពីនេះ អំណាន ឬការអាន នៅមានសារៈសំខាន់មួយចំនួនទៀត ដូចខាងក្រោម៖

**ក. ដំណើរកំសាន្ត៖** នៅពេលដែលលោកអ្នក ចង់ធ្វើដំណើរទៅកាន់ទីណាមួយ ប្រកប ដោយជោគជ័យ លោកអ្នកត្រូវតែឆ្លងកាត់ការអានជាមុន។ តើមានតំបន់ណា ដែលយើងគួរតែទៅលេង? តើមានអ្នកណាខ្លះ ដែលអាចនាំយើង ទៅដល់ទីនោះបាន? តើនៅទីនោះមានអ្វីខ្លះ ដែលគួរឲ្យចាប់អារម្មណ៍

ក្នុងការទស្សនា? ដើម្បីទៅដល់ទីនោះ តើលោកអ្នក ត្រូវឆ្លងកាត់តំបន់ណាខ្លះ? នៅតាមដងផ្លូវដែលលោកអ្នកកំពុងធ្វើដំណើរ លោកអ្នកក៏អាចអាន សេចក្តីណែនាំផ្សេងៗ ដើម្បីទៅឲ្យដល់កន្លែង ដែលលោកអ្នកចង់ទៅផងដែរ។

**ខ. ការសិក្សា៖** ដើម្បីរៀនឲ្យបានពូកែ ធ្វើលំហាត់ឲ្យបានពិន្ទុល្អ បញ្ចប់កិច្ចការ ដែលលោកគ្រូអ្នកគ្រូ បានដាក់ឲ្យប្រកបដោយជោគជ័យ សិស្ស និស្សិត ត្រូវតែមានភាពស្ទាត់ជំនាញ ខាងការអានសៀវភៅ ឬឯកសារនានា ដែលមានជាចាំចាច់។

**គ. ការងារ៖** ស្ទើរតែនៅគ្រប់ការងារ គឺសុទ្ធតែត្រូវការអំណាន។ មិនថាការងាររដ្ឋ ឯកជន ឬអង្គការ សុទ្ធតែត្រូវការអំណាន។ ជំនួយការ លេខាធិការ សុទ្ធតែត្រូវការអំណានយ៉ាងច្រើន ក្នុងការជួយឲ្យការងាររបស់ប្រធានខ្លួន ដំណើរការបានល្អ។ លោកគ្រូអ្នកគ្រូ អ្នកប្រាជ្ញបណ្ឌិត អ្នកស្រាវជ្រាវ មគ្គុទ្ទេសក៍ទេសចរណ៍ សិល្បករ អ្នកជំនួញ បណ្ណារក្ស អ្នកឯកទេសវិទ្យាសាស្ត្រ អ្នកសរសេរកាសែត ឬអ្នកយកព័ត៌មាន សុទ្ធសឹងត្រូវការអំណានជាចាំបាច់។

**ឃ. ការចែករំលែក៖** តាមរយៈអំណាន គេអាចធ្វើការចែករំលែក ភាពសប្បាយរីករាយ និងចំណេះដឹងឲ្យគ្នា ទៅវិញទៅមក មិនថាតែសម្រាប់មិត្តភក្តិ គ្រួសារ សហគមន៍ ប្រទេសជាតិ ឬក៏សកលលោក។ តាមរយៈអំណាន មនុស្សអាចយល់ចិត្តគ្នានៅគ្រប់កាលៈទេសៈ។ មនុស្សជំនាន់ថ្មី អាចយល់ដឹងពីគំនិតមនុស្សចាស់ ក៏ដោយសារតែតាមរយៈអំណាននេះឯង។ មនុស្សខ្លះ បានចាត់ទុកការអានថា ជារបៀបនៃការកម្សាន្តមួយដ៏ល្អសម្រាប់ពួកគេ។

**ង. ការស្រាវជ្រាវ៖** រឿងរ៉ាវក្នុងពិភពលោកនេះ មនុស្សអាចដឹង អាចព្យាករណ៍ទុកមុន ក៏អាស្រ័យដោយអំណាន ពីសិលាចារឹក សាស្ត្រាស្លឹករឹត សាស្ត្រាល្បែង សាស្ត្រាទេស សៀវភៅ គំនូរ គំនិត សម្ភារប្រើប្រាស់របស់មនុស្ស ក៏ដូចជាបាតុភូតធម្មជាតិ។ មនុស្សសម័យបុរាណ អាចទស្សន៍ទាយកម្រិតទឹកភ្លៀងតាមរយៈគំនូសប្រាប់ឲ្យដឹង តាមរយៈចលនារបស់ពពក ក៏ដូចជាកម្លាំងខ្យល់បក់។( គល់រាំង - ភ្នំពេញថ្ងៃ

ទី១៩ ខែមីនា ឆ្នាំ២០១២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ៖ មនោរម្យព័ងអាំងហ្វូ Crédit photo : Lori-Ga!/flickr.com)។

## ២.១.៦. ការចាប់ផ្តើម និងការបញ្ចប់នៅនៃអំណាន

តើអំណានគួរចាប់ផ្តើម និងបញ្ចប់នៅពេលណា?

«អំណាន» គឺមានសារៈសំខាន់ណាស់សម្រាប់ទាំងអស់គ្នា មិនថាចាស់ ក្មេង ប្រុសស្រី អ្នកមាន អ្នកក្រ ស្តេច រាស្ត្រ មន្ត្រី សេដ្ឋី ប្រភេទជាតិសាសន៍ ឬសាសនាណាឡើយ។ សង្គមបុរាណ ឬសង្គមសម័យទំនើបទេ គឺសុទ្ធតែត្រូវការអំណាន។ អំណានដែលល្អ គួរចាប់ផ្តើមជាប្រចាំ ចាប់តាំងតែទារកនៅក្នុងផ្ទៃម្តាយឡើងទៅ។ ដើម្បីជួយដល់ការរីកចម្រើននៃខួរក្បាល លោកអ្នក គួរតែបន្តសកម្មភាពអំណានឲ្យបានពេញមួយជីវិតរបស់ខ្លួន។ នៅពេលណា ដែលលោកអ្នកត្រូវការ ខ្យល់បរិសុទ្ធដកដង្ហើម ឬអាហារដែលមានសុខភាព ដើម្បីរស់ដរាបនោះ អំណានក៏ជាផ្នែកមួយ នៃជីវិត ដែលមានសារៈសំខាន់ ស្រដៀងគ្នានេះដែរ។(គល់រាំង - ភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ៖ មនោរម្យព័ងអាំងហ្វូ Crédit photo : Lori-Ga!/flickr.com)។

## ២.១.៧. ប្រទេសដែលឱ្យតម្លៃលើអំណាន

តើប្រជាជននៅប្រទេសណាខ្លះដែលឲ្យតម្លៃលើការអានសៀវភៅច្រើនជាងគេ?

តាមបណ្តាញសារព័ត៌មានខ្មែរជាច្រើនក្នុងរយៈពេលកន្លងមក លោកបានបង្ហាញថា ប្រជាជនដែលឲ្យតម្លៃ លើការអានច្រើនជាងគេមានដូចជា៖ ជប៉ុន បារាំង អាមេរិក ចិន សាំងហ្គាពួ អូស្ត្រាលី អង់គ្លេស ស៊ុយអែត កាណាដា អាឡឺម៉ង់ ប្រទេសស្វីស ប្រទេសញូវហ្ស៊ីលែន។ ប្រជាជនប្រទេសទាំងអស់នេះ ច្រើនតែអនុវត្តការអានសៀវភៅជាប្រចាំ ច្រើនជំរុញឲ្យអ្នកគ្រប់រូប អនុវត្តការអានសៀវភៅ និងតែងលើកទឹកចិត្តឲ្យមានការតែងនិពន្ធស្នាដៃថ្មីៗជាច្រើន។ មិនតែប៉ុណ្ណោះ ពួកគេថែមទាំងបង្កើតឲ្យមានការតាំងពិព័ណ៌ ស្នាដៃនិពន្ធចាស់ថ្មី និងបង្កើតឲ្យមានបណ្ណាល័យនៅក្នុងគ្រួសារ សាលារៀន សហគមន៍ រហូតដល់បណ្ណាល័យថ្នាក់ជាតិថែមទៀតផង។ មានអ្នកប្រាជ្ញដែលពិភពលោកបានស្គាល់គ្រប់គ្នា ពីភាពថ្កុំ

ថ្កើងរបស់លោក តាមរយៈការអាន ដូចជា៖ អ្នកប្រាជ្ញ អារីយ៉ូស្សា អ្នកប្រាជ្ញញូតុន អ្នកប្រាជ្ញ អាប៉ាហ្គោ ប្រធានាធិបតី នែលសុន ម៉ាឌីឡា ប្រធានាធិបតី អាប្រាហាំ លីងកុន មហាត្មៈគន្ធី អ្នកប្រាជ្ញ សូក្រាត អ្នកប្រាជ្ញ ខុងជឺ ព្រះពុទ្ធបរមគ្រូ ព្រះយេស៊ូគ្រីស្ត និងព្រះមហាម៉ាត់ ជាដើម។( គល់រាំង - ភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ៖ មនោរម្យព័ងអាំងហ្វូ Crédit photo : Lori-Ga!/flickr.com)។

## ២.១.៨. កម្រិតចូលចិត្តអានរបស់ប្រជាជនកម្ពុជា

តើប្រជាជនខ្មែរចូលចិត្តអានសៀវភៅក្នុងកម្រិតណា?

**ក. សម័យបុរាណ៖** កាលពីសម័យបុរាណ ជាពិសេសនៅក្នុងសម័យអង្គរ បុព្វបុរសខ្មែរមានចំណូលចិត្តអំណានខ្លាំងណាស់។ កាលណោះ គេឃើញខ្មែរ មានប្រភេទឯកសារសំខាន់ៗជាច្រើន រាយនៅពាសពេញផ្ទៃនគរ ជាពិសេសតាមវត្តអារាម តាមបណ្ណាល័យជាដើម តាមជញ្ជាំងប្រាសាទ ដែលមានដូចជា សិលាចារឹក សាស្ត្រាស្លឹករឹត សាស្ត្រាល្បែង សាស្ត្រាទេស។ កាលណោះ ខ្មែរសំបូរទៅដោយអ្នកប្រាជ្ញជាច្រើន ដែលជាព្រះសង្ឃ ជាមន្ត្រី មេទ័ព...។ល។ ខ្មែរកាលសម័យណោះ មាន ភាពស្ទាត់ជំនាញខាងអក្សរសាស្ត្រ អក្សរសិល្ប៍ សិល្បៈ ចម្លាក់ គំនូរ និងខាងស្ថាបត្យកម្ម។ មានអ្នកប្រាជ្ញជាច្រើនដែលពូកែខាង ភាសាខ្មែរ ភាសាបាលី និងសំស្ក្រឹត ក៏ដូចជាភាសាចិន។ ក៏ព្រោះហេតុអ្វី?

នោះក៏មកតែខ្មែរកាលជំនាន់នោះ ចូលចិត្តខាងអំណាន។ ចាស់បុរាណច្រើនយកពេលទំនេររបស់ខ្លួនអានសាស្ត្រា និងនិទានរឿងឲ្យក្មេងៗអ្នកស្រុកបានស្តាប់កម្សាន្ត។ លោកយកចិត្តទុកដាក់ណាស់ ក្នុងការបណ្តុះបណ្តាលដល់អ្នកជំនាន់ក្រោយ តាមរយៈការអាន។ ព្រះនាងឥន្ទ្រទេវី ព្រះបាទអង្គឌួង គឺជាអ្នកប្រាជ្ញដ៏កំពូលខាងផ្នែកអក្សរសាស្ត្រខ្មែរ។ ដោយសារតែមូលហេតុខ្មែរសម័យបុរាណ ចូលចិត្តការអានដូច្នេះហើយ បានជាយើងឃើញ មានសល់អក្សរបុរាណ រាប់មិនអស់នៅលើសាស្ត្រាស្លឹករឹត ឬជញ្ជាំងប្រាសាទរហូតមកដល់សព្វថ្ងៃនេះ។

**ខ. សម័យទំនើប៖** នៅដើមសម័យកាលទំនើប បើទោះណាជាមានចម្បាំងរាំងជល់ខ្លាំងយ៉ាងណាក្តី ក៏ខ្មែរមិនបានភ្លេចពីរឿងអំណានឡើយ។ នៅសម័យអាណានិគមនិយមបារាំង ប្រទេសខ្មែរមានអ្នក

ប្រាជ្ញជាច្រើនដូចជា កវីសន្ធរម៉ុក កវីសុត្តន្តប្រីជាឥន្ទ្រ អ្នកព្រះភិរម្យភាសាអ៊ូហៅង៉ុយ ជាដើម។ នៅសម័យសង្គមរាស្ត្រនិយម អ្នកចូលចិត្តអានសៀវភៅជាងគេ យើងឃើញមាន សម្តេចព្រះសង្ឃរាជ ជួន ណាត និងក្រុមរបស់លោក ក្រុមអ្នកស្រាវជ្រាវពុទ្ធសាសនបណ្ឌិត្យ រួមទាំងប្រជារាស្ត្រ អ្នកប្រាជ្ញ កវីនិពន្ធ និងអ្នកសិល្បករជាច្រើនរូបទៀត។ ចាប់តាំងពីសម័យខ្មែរក្រហម ហូតដល់សព្វថ្ងៃ គេសង្កេតឃើញប្រជាជនខ្មែរទូទៅ មិនសូវមានចំណូលចិត្តអានសៀវភៅប៉ុន្មានទេ។ មនុស្សភាគច្រើន គិតខ្វល់តែរឿងសប្បាយ ឬការកើតទុក្ខ ខ្វល់តែរឿងក្រពះ សម្រាប់តែមួយពេលៗ។ ឯអ្នកខ្លះទៀតគិតថា អំណានជារឿងដែលមិនចាំបាច់សម្រាប់ពួកគេ។

តែទោះជាយ៉ាងណាក្តី ឆ្លងកាត់ការសង្កេតមួយរយៈពេលថ្មីៗនេះ យើងឃើញថា កូនខ្មែរកំពុងតែមានការចាប់អារម្មណ៍លើរឿងអំណានឡើងវិញខ្លះៗហើយ។ យើងសង្ឃឹមថា មិនយូរប៉ុន្មាន ខ្មែរនឹងមានការរីកចម្រើនផ្នែកអំណានខ្លាំងវិញមិនខាន។( គល់រាំង - ភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ៖ មនោរម្យព័ងអាំងហ្វូ Crédit photo:Lori-Ga!/flickr.com)។

## ២.១.៩. ប្រភេទសៀវភៅគួរជ្រើសរើសដើម្បីអាន

តើលោកអ្នកគួរជ្រើសរើសសៀវភៅប្រភេទណាដើម្បីអាន?

ការអានសៀវភៅមិនកំណត់ថា ជាសៀវភៅមុខវិជ្ជាណា ភាសាណា ឬអ្នកនិពន្ធណាឡើយ។ ចំណុចសំខាន់ គឺលោកអ្នក គិតតែត្រឹមថា តើសៀវភៅប្រភេទណា ដែលលោកអ្នកចូលចិត្តអាន? ហើយតើសៀវភៅទាំងនោះ គឺជាប្រភេទដែលបានបង្កប់ ទៅដោយការអប់រំ និងគោរពតាមក្រមសីលធម៌ជាតិ និងមិនសូវមានកំហុស លើអក្ខរាវិរុទ្ធដែរឬទេ?

សរុបមកវិញ យើងអាចសន្និដ្ឋានបានថា ការអានពិតជាមានសារៈសំខាន់ណាស់ សម្រាប់យើងទាំងអស់គ្នា។ ក្នុងនាមយើង ជាកូនខ្មែរ គួរតែខិតខំអាន ស្រាវជ្រាវ និងតែងនិពន្ធឲ្យបានជាប់ជាប្រចាំ ដើម្បីជាការរីកចម្រើនដល់ខ្លួនយើងផង ក៏ដូចជាការរីកចម្រើនដល់ប្រទេសជាតិយើងផង។

(គល់រាំង - ភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ៖ មនោរម្យព័ងអាំងហ្វូ Crédit photo:Lori-Ga!/flickr.com)( https://archive.monoroom.info/news/post/67)។

## ២.២. កម្មវិធីកញ្ចប់អំណានដំបូង

### ក. និយមន័យ:

«អំណាន» មានន័យថា ជាការមើលថាតាមអក្សរ ឬសកម្មភាព នៃការស្វែងយល់ ពីអត្ថន័យ នៃពាក្យពេចន៍ ដែលបានសរសេរ ឬបោះពុម្ពផ្សាយ។

«ដំបូង» គឺ ជាសំដៅលើពាក្យថា ជាបឋម , ជាខាងដើម, មុន, ទីមួយ។

ដូចនេះ « អំណានដំបូង » ទីនេះ សំដៅលើការចាប់ផ្តើមរៀនអានអក្សរលើកទីមួយ របស់កុមារតូចៗ ចាប់ពីពួកគេបានរៀនចប់មត្តេយ្យសិក្សា ដែលផ្តោតសំខាន់លើលំហូរសកម្មភាពទាំង៧ជំហាន រួមមាន **ទី១ ការស្គាល់សូរអក្សរថ្មី ទី២ ការស្គាល់តួអក្សរថ្មី ទី៣ ការអានព្យាង្គ និងការអានពាក្យ ទី៤ វាក្យសព្ទ ទី៥ ការអានល្បឿន ទី៦ ការអានអត្ថបទខ្លី និងទី៧ ការសរសេរ។** (សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២ ស្តីពីសម្ភារៈជំនួយបន្ថែមលើសៀវភៅសិក្សាគោលភាសាខ្មែរ អាន-សរសេរ របស់ក្រសួងអយក. ឆ្នាំ២០១៩)។

### ខ. សារៈប្រយោជន៍នៃកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង

កម្មវិធី «អំណានដំបូង» ជាកម្មវិធីគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅផ្ទះ យ៉ាងល្អប្រសើរ និងគ្រប់ជ្រុងជ្រោយ ដែលលើកកម្ពស់មាតាបិតា និងអាណាព្យាបាលកុមារ ឲ្យចូលរួមចំណែកសំខាន់ ក្នុងការអភិវឌ្ឍជំនាញអក្ខរកម្មសំខាន់ៗ និងកសាងមូលដ្ឋានគ្រឹះ សម្រាប់ការសិក្សារបស់កុមារនៅពេលអនាគត។ ក្រុមគ្រួសារដែលបានចូលរួមជាមួយកម្មវិធី«អំណានដំបូង» ទទួលបានសម្ភារៈសម្រាប់ហាត់រៀនអានដែលមានគុណភាព និងសមស្របតាមកម្រិតអាយុរបស់កុមារ ដែលជួយឲ្យកុមាររៀនព្យញ្ជនៈ ប្រកបពាក្យ និងចំណេះដឹងមូលដ្ឋានផ្សេងទៀត ។ (http://freshnewsasia. com/index.php/en/localnews/56767-2017-06-06-08-07-12.html)

កុមារតូចអាយុក្រោម៦ឆ្នាំ និងអាណាព្យាបាល ដែលបានចូលរួមក្នុងកម្មវិធី «អំណានដំបូង» ទទួលបានឱកាសអានសៀវភៅ និងធនធានផ្សេងទៀត ដែលជួយឲ្យពួកគាត់ ត្រៀមខ្លួនបានល្អប្រសើរ សម្រាប់ការចូលរៀនថ្នាក់ទី១របស់កូនៗគាត់ នេះបើយោងតាមទីប្រឹក្សាកម្មវិធីគាំពារ និងអភិវឌ្ឍន៍កុមារតូច នៃអង្គការ Save the Children។ (http:// freshnewsasia.com/index. php/en/localnews /56767-2017-06-06-08-07-12.html)

កុមារអាចចាប់ផ្តើមរៀនតាំងពីតូចៗទៅ ប៉ុន្តែកុមារជាច្រើននៅក្នុងប្រទេសកម្ពុជា មិនមានឱកាសអភិវឌ្ឍជំនាញដែលជួយឲ្យគាត់រៀនសូត្រឆាប់ចេះនោះទេ។ យោងតាមស្ថិតិរបស់រាជរដ្ឋាភិបាល មានកុមារតិចជាង៤២% ដែលបន្តចូលរៀនរហូតដល់បញ្ចប់ថ្នាក់ទី៩ តាមការកំណត់របស់រដ្ឋ ហើយមានកុមារប្រមាណ ២២% ប៉ុណ្ណោះដែលទទួលបានការអប់រំ និងអភិវឌ្ឍន៍កុមារតូច ហើយ មានការស្រាវជ្រាវនៅទូទាំងពិភពលោក ដែលបង្ហាញយ៉ាងច្បាស់ថា កុមារដែលទទួលបានការអប់រំពីតូចទៅ អភិវឌ្ឍចំណេះដឹងបានលឿនជាង និងល្អជាងកុមារដែលមិនបានទទួលការអប់រំពីតូច នៅពេលចាប់ផ្តើមចូលសាលា។ (http:// freshnewsasia.com/index. php/en/localnews/ 56767-2017-06-06-08-07-12.html)

អ្នកស្រី ខូយ រ៉ានី ទីប្រឹក្សាកម្មវិធីគាំពារ និងអភិវឌ្ឍន៍កុមារតូច នៃអង្គការ Save the Children បានថ្លែងថា៖ «កម្មវិធីអំណានដំបូង មានគោលបំណងអភិវឌ្ឍកុមារ ដើម្បីឲ្យពួកគាត់ អាចត្រៀមខ្លួនបានល្អសម្រាប់ការចូលរៀនបឋមសិក្សាថ្នាក់ទី១។ សម្រាប់កុមារដែលបានចូលរួមក្នុងកម្មវិធីនេះ នៅពេលចាប់ផ្តើមចូលរៀន គឺគាត់ស្គាល់សៀវភៅ ចេះកាន់ខ្មៅដៃ គាត់ស្គាល់អក្សរមួយចំនួន គាត់ចេះរាប់លេខបានខ្លះៗ ហើយគាត់ចេះលេងជាមួយមិត្តភ័ក្តិដោយមិនបង្កជម្លោះ និងចេះរៀនសូត្រពីគ្នា»។

អ្នកស្រី ខូយ រ៉ានី បន្ថែមទៀតថា៖ «ជាក់ស្តែង យើងឃើញស្រាប់ហើយ នៅទីនេះក្តី ឪពុកម្តាយគាត់ប្រាប់យើងថា កាលពីមុនគាត់អត់ដឹងថា ត្រូវជួយកូនគាត់យ៉ាងម៉េចទេ ។ ប៉ុន្តែ ដល់ពេលចូលរួមជាមួយនឹងកម្មវិធីយើង គាត់បានចំណេះដឹងក្នុងការជួយបង្ហាត់បង្ហាញកូនគាត់ ដោយប្រើប្រាស់សៀវភៅក្នុងការជួយកូនឲ្យមានទម្លាប់ចូលចិត្តសៀវភៅ ស្គាល់ពណ៌ ស្គាល់អក្សរ ហើយបន្ទាប់ពីការអនុវត្តកម្មវិធី

បានបីឆ្នាំដំបូង ៨០% នៃឪពុកម្ដាយ និងអាណាព្យាបាលកុមារដែលចូលរួមក្នុងកម្មវិធី «អំណានដំបូង» បានរាយការណ៍ថា ពួកគាត់បានបង្រៀនអក្សរ និងលេខដល់កូនៗរបស់ពួកគាត់នៅផ្ទះ ហើយ ៦១% នៃឪពុកម្ដាយដែលមានកូនអាយុពី ៣ទៅ៦ឆ្នាំ បានបញ្ជាក់ថា គាត់បានអានសៀវភៅឱ្យកូនស្ដាប់ជាប្រចាំ»។ មូលនិធិព្រូជិនស៍ និងអង្គការ Save the Children រំពឹងថា កម្មវិធី «អំណានដំបូង»នេះ នឹងជួយអភិវឌ្ឍប្រាជ្ញាស្មារតី រាងកាយ និងអារម្មណ៍ ដល់កុមារតូចៗនៅកម្ពុជា និងធានាថា ពួកគាត់ត្រៀមខ្លួនរួចរាល់ដើម្បីចាប់យកចំណេះដឹង និងកសាងអនាគតភ្លឺស្វាង។ (http:// freshnewsasia.com/index. php/en/localnews/ 56767-2017-06-06-08-07-12.html)

ចំពោះការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទស្ដីពី«ស្ថានភាពនៃការអនុវត្តកញ្ចប់អំណានថ្នាក់ដំបូង នៅខេត្តកំពង់ឆ្នាំង» នេះ គឺដោយសារធ្លាប់បានឮការកោតសរសើរពីលោកគ្រូ អ្នកគ្រូដែលបានអនុវត្តនៅតាមសាលាគោលដៅខ្លះៗផងដែរថាកម្មវិធីនេះល្អ បង្រៀនកុមារឆាប់ចេះអាន ចេះសរសេរ ប៉ុន្តែដើម្បីបានជាភស្តុតាងបញ្ជាក់ថា កម្មវិធីនេះពិតជាល្អ ឬល្អកម្រិតណានោះ លោកគ្រូ អ្នកគ្រូមានវិធីសាស្ត្រ មានសម្ភារៈ មានបទពិសោធបែបណាក្នុងការបង្ហាត់បង្រៀនកុមារឱ្យឆាប់ចេះអាន ចេះសរសេរ ទើបខ្ញុំបាទជ្រើសរើសយកប្រធានបទនេះមកសិក្សាស្រាវជ្រាវឡើង ដែលអាចឱ្យសាលាបឋមសិក្សានានាក្នុងខេត្តទាំងមូល ក៏ដូចជាក្នុងព្រះរាជាណាចក្រកម្ពុជាយកកម្មវិធីនេះទៅអនុវត្តនៅតាមសាលារបស់ខ្លួន ដើម្បីជួយដល់កុមារនៅសាលារបស់ខ្លួនឱ្យឆាប់ចេះអាន ចេះសរសេរផងដែរ។

ជាការពិត កម្មវិធីកញ្ចប់អំណានមានពីរកម្រិតថ្នាក់គឺសម្រាប់ថ្នាក់ទី១ និងថ្នាក់ទី២។ ប៉ុន្តែក្នុងការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទនេះ បានផ្ដោតសំខាន់ទៅលើតែកញ្ចប់អំណានសម្រាប់ថ្នាក់ទី២ប៉ុណ្ណោះ។

នៅក្នុងបុព្វកថារបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២ ស្ដីពីសម្ភារៈជំនួយបន្ថែមលើសៀវភៅសិក្សាគោលភាសាខ្មែរ អាន-សរសេរ របស់ក្រសួងអយក.ឆ្នាំ២០១៩ បានបញ្ជាក់ពីភាពចាំបាច់នៃកញ្ចប់សម្ភារៈអំណានដំបូងសម្រាប់ថ្នាក់ទី២នេះផងដែរថា៖

«ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្តកំណែទម្រង់វិស័យអប់រំ សំដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀន ដើម្បីអភិវឌ្ឍធនធានមនុស្សឱ្យស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០១៥-២០៣០»។

«ផ្អែកលើលទ្ធផលនៃកម្មវិធីអន្តរជាតិ ស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ហៅកាត់ថា PISA-D បង្ហាញថា ក្រសួងគួរផ្តោតលើសមត្ថភាពរបស់សិស្សចាប់ពីបឋមសិក្សា ជាពិសេសលើផ្នែកអំណាន មានន័យថា បើសិស្សមិនមានមូលដ្ឋានគ្រឹះផ្នែកអំណាននៅកម្រិតថ្នាក់ដំបូង នោះការសិក្សានៅភូមិសិក្សាបន្ទាប់ទៀត នឹងមិនទទួលបានលទ្ធផលល្អប្រសើរឡើយ។ ដូច្នេះ ការអប់រំនៅកម្រិតថ្នាក់ដំបូង ជាមូលដ្ឋានគ្រឹះក្នុងការសិក្សាលើមុខវិជ្ជាដទៃ និងជំនាញវិជ្ជាជីវៈផ្សេងៗ ជាពិសេសកាលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា»។

«ដើម្បីឆ្លើយតបជាវិជ្ជមាន និងចំគោលដៅទៅនឹងបញ្ហាប្រឈមខាងលើ ក្រសួងបាន និងកំពុងសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំកញ្ចប់សម្ភារៈអំណានដំបូង ដែលជាធនធានសម្ភារៈចាំបាច់សម្រាប់ជួយគាំទ្រដល់សៀវភៅភាសាខ្មែរ «អាន-សរសេរ» ថ្នាក់ទី២។ ខ្លឹមសារក្នុងសៀវភៅណែនាំនេះបានមកពីការប្រមូលផ្តុំបញ្ចូលគ្នានូវបទពិសោធ និងវិធីសាស្ត្របង្រៀនល្អៗ របស់អង្គការពាក់ព័ន្ធ ព្រមទាំងផ្អែកលើបទពិសោធ និងលទ្ធផលជាវិជ្ជមានដែលបានមកពីការពិនិត្យតាមដាន និងវាយតម្លៃរបស់ក្រសួងស្តីពីការបង្រៀន និងរៀន លើការអនុវត្តកញ្ចប់សម្ភារៈអំណានថ្នាក់ទី១ នាពេលកន្លងមក។ សៀវភៅណែនាំនេះផ្តោតសំខាន់លើសកម្មភាពស្នូលទាំង៧ រួមមាន (១)ការស្គាល់សូរ (២)ការស្គាល់តួអក្សរ (៣)ការអានព្យាង្គ និងពាក្យ (៤)ការចេះវាក្យស័ព្ទ (៥)ការអានល្បឿន (៦) ការអានអត្ថបទខ្លី និង(៧) ការសរសេរ ដោយប្រើវិធីសាស្ត្របង្រៀន ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ ដែលទាមទារនូវអន្តរកម្មរវាងសិស្ស និងគ្រូ និងការចូលរួមសកម្មភាពជាមួយគ្នា ឆ្លើយតបបានទៅនឹងគោលវិធីសិស្សមជ្ឈមណ្ឌល»។

«ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា គ្រប់ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ជាពិសេសគ្រូបង្រៀនថ្នាក់ទី២ នឹងគាំទ្រយ៉ាងពេញទំហឹង ព្រមទាំងចូលរួមអនុវត្តតាម

សៀវភៅណែនាំនេះ ឱ្យបានត្រឹមត្រូវតាមនិយាមគរុកោសល្យ ដើម្បីពង្រឹងសមត្ថភាពអាន និងសរសេរនៅថ្នាក់ទី២ ឈានទៅបង្កើនលទ្ធផលសិក្សា និងអត្រាឡើងថ្នាក់របស់សិស្ស ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់»។ (សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២ ស្ដីពីសម្ភារៈជំនួយបន្ថែមលើសៀវភៅសិក្សាគោលភាសាខ្មែរ អាន-សរសេរ របស់ក្រសួងអយក.ឆ្នាំ២០១៩)។

ខាងក្រោមនេះ ជាលំណែនាំនៃការបង្រៀនសម្ភារៈកញ្ចប់អំណានថ្នាក់ទី២ ដែលដកស្រង់ពីសៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២ ស្ដីពីសម្ភារៈជំនួយបន្ថែមលើសៀវភៅសិក្សាគោល ភាសាខ្មែរ អាន-សរសេរ។

## ២.៣.គោលការណ៍ក្នុងលំនាំ នៃការបង្រៀន និងរៀន កញ្ចប់អំណានថ្នាក់ទី២

### ២.៣.១.បំណិនទាំង៤ នៃការរៀនភាសា

យើងបានដឹងហើយថា បំណិនទាំង៤ ក្នុងភាសា មានទំនាក់ទំនងគ្នាទៅវិញទៅមក។ បំណិននិយាយ និងស្ដាប់ គាំទ្របំណិនអាន និងសរសេរ ហើយគ្រប់សកម្មភាពអាន និងសរសេរ ក៏ត្រូវការ ការនិយាយ និងការស្ដាប់។ ការសរសេរជួយដល់ការអាន ហើយបញ្ច្រាសមកវិញ ការអានក៏ជួយដល់ការសរសេរផងដែរ។ ដូច្នេះ ការបញ្ជ្រាប ឬបញ្ចូលបំណិនទាំង៤នេះរួមគ្នា ក្នុងការបង្រៀនភាសា ធ្វើឱ្យការបង្រៀន និងរៀនមានប្រសិទ្ធភាពខ្ពស់។ (សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២ ស្ដីពីសម្ភារៈជំនួយបន្ថែមលើសៀវភៅសិក្សាគោលភាសាខ្មែរ អាន-សរសេរ របស់ក្រសួងអយក.ឆ្នាំ២០១៩)។

### ២.៣.២.សមាសភាគទាំង៥ នៃអំណាន និងសំណេរ

សមត្ថភាពជាក់លាក់ក្នុងការអាន និងសរសេរ ដែលសិស្សត្រូវទទួលបានពីខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោល ត្រូវបានប្រមូលផ្ដុំសម្រាប់មេរៀនណាមួយ ពីអ្វីដែលហៅថា«កម្រិតស្ដង់ដា»។ ដើម្បីឱ្យកម្រិតស្ដង់ដាអំណាន និងសរសេរមានប្រសិទ្ធភាព គ្រូបង្រៀនត្រូវដឹងអំពីសមាសភាគគន្លឹះទាំង៥ ដែលឆ្លុះបញ្ចាំងកម្រិតស្ដង់ដានីមួយៗ។ ការកត់សម្គាល់សមាសភាគទាំងនោះ ត្រូវបានយោងតាមការ

ស្រាវជ្រាវអន្តរជាតិ ដែលត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។ និយមន័យនៃសមាសភាគទាំងនោះ មានដូចតទៅ៖

**ក.សមាសភាគទី១៖ ការស្គាល់សូរ**

**ការស្គាល់សូរ** គឺសំដៅលើការបង្រៀនដើម្បីជួយឲ្យសិស្សមានសមត្ថភាពក្នុងការកំណត់ ប្រើប្រាស់ និងញែកសូរក្នុងភាសានិយាយ។ ការស្គាល់សូរ គឺបង្រៀនដោយការនិយាយផ្ទាល់មាត់ និងស្តាប់ដោយគ្មានការសរសេរ។ ការស្គាល់សូរ មានសារៈសំខាន់ក្នុងការជួយសិស្សឱ្យចេះកំណត់ ផ្សំប្រកប និងបំបែកសូរ។ ក្នុងការបង្រៀនឱ្យសិស្សស្គាល់សូរ គ្រូប្រើវត្ថុជាក់ស្តែង រូបភាព ធ្វើកាយវិការ ឬពណ៌នា ដើម្បីឱ្យសិស្សថាព្យាង្គ ឬពាក្យ និងប្រាប់សូរព្យញ្ជនៈនោះ។

ឧទាហរណ៍៖ សូរ«ខ» (នាំឱ្យសិស្សកំណត់បានសូរព្យញ្ជនៈ«**ខ**»)

- **គ្រូ៖** ចង្អុលទៅ «**ខោ**» របស់កុមារម្នាក់ រួចប្រាប់ថា នេះគឺ«**ខោ**»។ តើ «**ខោ**» មានសូរដើមអ្វី? (**ខ**)។ គ្រូថា «**ខ**» ។
- **គ្រូ និងសិស្ស៖** យើងថាទាំងអស់គ្នា «**ខ**»។
- **សិស្ស៖** សិស្សថាទាំងអស់គ្នា «**ខ**»។

**ខ.សមាសភាគទី២៖ ការស្គាល់តួអក្សរថ្មី**

ការស្គាល់តួអក្សរថ្មី គឺសំដៅដល់ការបង្រៀនដែលជួយសិស្សអាន និងអនុវត្តចំណេះដឹងស្តីពីទំនាក់ទំនងរវាងតួអក្សរ និងសូរ។ បំណិននេះមានសារៈសំខាន់ ឱ្យសិស្សចេះផ្សំ ប្រកបអក្សរ ហើយអានព្យាង្គ និងពាក្យ។ គ្រូមិនចាំបាច់ប្រើសម្ភារៈ។

ឧទាហរណ៍៖ តួអក្សរ «ខ» (នាំឱ្យសិស្សកំណត់បានរូបរាងព្យញ្ជនៈ«**ខ**»)

- **គ្រូ៖** គ្រូសរសេរអក្សរ «**ខ**» លើក្តារខៀន រួចអានថា «**ខ**»។
- **គ្រូ និងសិស្ស៖** គ្រូចង្អុល និងអានទាំងអស់គ្នា «**ខ**»។
- **សិស្ស៖** គ្រូចង្អុលអក្សរ សិស្សអានទាំងអស់គ្នា «**ខ**»។

**គ.សមាសភាគទី៣៖ ការចេះវាក្យស័ព្ទ**

**ការចេះវាក្យស័ព្ទ** គឺសំដៅលើការបង្រៀន ដើម្បីឲ្យសិស្សមានចំណេះដឹងពីពាក្យ ជាការយល់ន័យនៃពាក្យថ្មី និងដឹងពីរបៀបប្រើប្រាស់ពាក្យនោះ។ សិស្សរៀនពាក្យថ្មីបានល្អប្រសើរ កាលណាគ្រូបង្រៀនពីនិយមន័យនៃពាក្យតាមភាសាសាមញ្ញ ដែលសិស្សងាយយល់ ហើយហាត់តែងល្បះ ដោយប្រើពាក្យនោះបាន។

ឧទាហរណ៍៖ ពាក្យ «**កែខៃ**» (នាំឱ្យសិស្សយល់ន័យ និងប្រើប្រាស់ពាក្យ)

- **គ្រូ**៖ គ្រូសរសេរ ឬគូសរង្វង់លើក្ដារខៀន និងអានពាក្យ «**កែខៃ**» ច្បាស់ៗ រួចពន្យល់ថា «**កែខៃ មានន័យថា លៃលក ជួសជុល កែលម្អ។ ឧ. បូណាចេះកែខៃកាបូបស្ពាយ**»។
- **គ្រូ និងសិស្ស**៖ អានពាក្យជាមួយគ្នា។ គ្រូសួរសំណួរ «**តើនៅពេលកង់កូនខូច កូនធ្វើដូចម្ដេច?(ខ្ញុំកែខៃកង់**)»។ គ្រូសួរបន្តថា«**ដើម្បីអ្វី?»(ដើម្បីជិះ**)។ គ្រូ និងសិស្សបង្កើតល្បះរួមគ្នា«**ខ្ញុំកែខៃកង់ដើម្បីជិះ**»។
- **សិស្ស**៖ អានពាក្យ «**កែខៃ**» ដោយខ្លួនឯង។ បង្កើតល្បះជាមួយពាក្យ «**កែខៃ**» ជាដៃគូដោយផ្ទាល់មាត់។

**ឃ. សមាសភាគទី៤៖ ការចេះអានស្ទាត់**

**ការចេះអានស្ទាត់** គឺសំដៅលើការបង្រៀនដែលជួយពង្រឹងសមត្ថភាពអានបានត្រឹមត្រូវ ក្នុងល្បឿនសមស្រប និងមានការលើកដាក់សំឡេងតាមសញ្ញាសម្ព័ន្ធ។ ប្រសិនបើសិស្សអានយឺតពេក ហើយរវល់តែប្រកបពាក្យនីមួយៗ គេនឹងភ្លេចន័យនៃពាក្យនោះ នៅពេលអានល្បះចប់។ ក្នុងការអានស្ទាត់នេះដែររួមមានសកម្មភាព៖ ការអានពាក្យ ការអានល្បះ និងការអានអត្ថបទខ្លី។

**ង. សមាសភាគទី៥៖ ការអានដើម្បីយល់ន័យ**

ការអានដើម្បីយល់ន័យ គឺសំដៅទៅលើការបង្រៀនដែលឲ្យសិស្សមានសមត្ថភាពចូលរួម បញ្ចេញមតិ ដោយប្រើពាក្យសម្ដីផ្ទាល់ខ្លួនពីអត្ថបទដែលបានអាន។ វាជាការយល់ន័យ នៃអត្ថបទទាំងមូល ដោយ

សិស្សអាចឆ្លើយនឹងសំណួរដែលទាក់ទងនឹងអត្ថបទបានត្រឹមត្រូវ។ (សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២ ស្តីពីសម្ភារៈជំនួយបន្ថែមលើសៀវភៅសិក្សាគោលភាសាខ្មែរ អាន-សរសេរ របស់ក្រសួងអយក. ឆ្នាំ២០១៩)។

### ២.៣.៣.សកម្មភាពគោលក្នុងលំនាំបង្រៀន

សកម្មភាពគោលក្នុងលំនាំបង្រៀនគ្រប់មេរៀនទាំងអស់ ក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២ គឺស្របទៅនឹងសមាសភាគអំណានទាំង៥ខាងលើ។ សកម្មភាពគោលទាំងនោះរួមមាន៖ ១/. ការស្គាល់សូរអក្សរថ្មី ២/.ការស្គាល់តួអក្សរថ្មី ៣/.ការអានព្យាង្គ និងពាក្យ ៤/. វាក្យ ស័ព្ទ ៥/. ការអានល្បឿន ៦/. ការអានអត្ថបទ និង៧/.សំណេរ។(សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២ ស្តីពីសម្ភារៈជំនួយបន្ថែមលើសៀវភៅសិក្សាគោលភាសាខ្មែរ អាន-សរសេរ របស់ក្រសួងអយក.ឆ្នាំ២០១៩)។

### ២.៣.៤.គោលការណ៍បង្រៀនតាមរបៀប«ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ»

«ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ» ជាគោលការណ៍បង្រៀន និងរៀនដ៏សំខាន់ ដែលធានានូវការចូលរួមរបស់សិស្សក្នុងសកម្មភាពរៀន ប្រកបដោយទំនុកចិត្ត និងមោទកភាព។ វាគឺជាការបង្រៀនបំណិនថ្មី ដោយផ្តល់ការទទួលខុសត្រូវដល់សិស្សបន្តិចម្តងៗ តាមរយៈការអនុវត្តជាជំហានៗ ដោយមានការជួយគាំទ្រដល់ដំណើរការនៃការបង្រៀន។ ឧទាហរណ៍ដូចជាការរៀនជិះកង់របស់កុមារម្នាក់។ មុនដំបូង កុមារត្រូវការសង្កេតមើលគេជិះកង់ជាមុនសិន បន្ទាប់មក គេត្រូវការនរណាម្នាក់ជួយគេឱ្យរៀនជិះកង់ ដោយជិះជាមួយគ្នា។ ទីបំផុត គេមានទំនុកចិត្តអាចជិះកង់ដោយខ្លួនឯងបាន។ ការរៀនបំណិនថ្មីដទៃទៀត ជាពិសេសការអាន និងសរសេរក្នុងថ្នាក់រៀន ក៏ដូចគ្នានឹងឧទាហរណ៍ខាងលើនេះដែរ។ ដើម្បីបានរៀនល្អប្រសើរ សិស្សត្រូវការ៖ ១/. គ្រូធ្វើជាគំរូ ឱ្យសិស្សមើល ២/. គ្រូ និងសិស្ស ហាត់ជាមួយគ្នា ក្នុងថ្នាក់ទាំងមូល និង៣/. សិស្សហាត់ជា បុគ្គល ឬជាដៃគូ។(សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២ ស្តីពីសម្ភារៈជំនួយបន្ថែមលើសៀវភៅសិក្សាគោលភាសាខ្មែរ អាន-សរសេរ របស់ក្រសួងអយក.ឆ្នាំ២០១៩)។

**សូមមើលតារាងខាងក្រោម៖**

| អ្នកណា | ធ្វើដូចម្ដេច? | ហេតុអ្វីបានជាសំខាន់? | ត្រូវផ្ដោតលើអ្វី? |
| --- | --- | --- | --- |
| ខ្ញុំធ្វើ (គ្រូ) | គ្រូពន្យល់ពីអ្វីដែលសិស្សត្រូវធ្វើ រួចគ្រូធ្វើការបង្ហាញជាគំរូដល់សិស្ស។ | សិស្សបានសង្កេតសកម្មភាពគ្រូ តាមដំណាក់កាលនីមួយៗ មុនពេលអនុវត្តជាមួយគ្រូ។ | គ្រូត្រូវប្រាកដថា សិស្សទាំងអស់បានឃើញគ្រូ។ |
| យើងធ្វើ (គ្រូ និងសិស្ស) | គ្រូ និងសិស្សអនុវត្ត/ហាត់ជាមួយគ្នាក្នុងថ្នាក់ទាំងមូល។ | សិស្សមានឱកាសធ្វើមួយជំហានម្ដងៗជាមួយគ្រូ មុននឹងពួកគេធ្វើដោយខ្លួនឯង។ | គ្រូត្រូវប្រាកដថាសិស្សទាំងអស់បានធ្វើជាមួយគ្រូ។ |
| អ្នកធ្វើ (សិស្ស) | សិស្សអនុវត្ត/ហ្វឹកហាត់ ជាដៃគូ ឬជាបុគ្គល។ | សិស្សមានឱកាសធ្វើដោយខ្លួនឯងនូវបំណិន។ | គ្រូដើរតាមតុសិស្ស ដើម្បីឱ្យប្រាកដថា សិស្សទាំងអស់បានអានម្ដងម្នាក់ៗ ដោយប្ដូរវេនគ្នា ។ គ្រូស្ដាប់សិស្សអាន ជាពិសេសសិស្សរៀនយឺត។ |

# ជំពូក៣

# វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៣.១. ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ

ដោយសារប្រទេសកម្ពុជាយើង ក៏ដូចជាពិភពលោកទាំងមូលកំពុងស្ថិតក្នុងបរិបទកូវីដ-១៩ ការស្រាវជ្រាវរបស់អ្នកស្រាវជ្រាវនេះ ត្រូវបានរៀបចំធ្វើឡើងដោយប្រើទិន្នន័យបរិមាណវិស័យ(ការប្រើកម្រងសំណួរបំពេញ និងទទួលទិន្នន័យតាមរយៈ Google Forms និងតាមរយៈការប្រើ សូស(Soft) ជា Microsoft Word Office និងគុណវិស័យ(ការសាកសួរតាមរយៈទូរស័ព្ទ) ហើយបានយកមកវិភាគ ដើម្បីស្វែងយល់ពី«ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងនៅខេត្តកំពង់ឆ្នាំង» នៅសាលាបឋមសិក្សា ២០សាលាគោលដៅ ក្នុងស្រុកទាំងបី នៃខេត្តកំពង់ឆ្នាំង។

## ៣.២. ទីកន្លែងសិក្សាស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាបឋមសិក្សាចំនួន២០ ដែលស្ថិតក្នុងស្រុកទាំង៣ នៃខេត្តកំពង់ឆ្នាំង ហើយជាសាលាបឋមសិក្សារបស់គម្រោង EQUAL នៃអង្គការ Save the Children ដែលជាទីតាំងសម្រាប់ធ្វើការប្រមូលទិន្នន័យ។ ដូចដែលបានរៀបរាប់ក្នុងជំពូកទី១ ខាងលើ ការស្រាវជ្រាវនេះមានវត្ថុបំណងសំខាន់គឺចង់ដឹងពី «ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់លោកគ្រូ អ្នកគ្រូដែលបង្រៀននៅថ្នាក់ទី២ ក្នុងការបង្រៀនកន្លងមក នៅសាលារៀនរបស់ខ្លួនថាតើអនុវត្ត និងមានដំណើរការទៅយ៉ាងដូចម្តេច» ដែលក្នុងនោះរួមមាន៖

- ការយល់ឃើញរបស់ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូលើការអនុវត្តកម្មវិធីកញ្ចប់អំណានកន្លងមក
- លទ្ធផលនៃការសិក្សារបស់សិស្សលើផ្នែកអំណាន

ដោយផ្អែកទៅលើកត្តា ភេទ អាយុ កម្រិតនៃការអប់រំ ប្រភេទសមាជិក កម្រិតវិជ្ជាជីវៈ និងបទពិសោធន៍។ ដើម្បីសម្រេចបាននូវវត្ថុបំណងខាងលើនេះ វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ និងគុណវិស័យ ព្រមទាំងរួមផ្សំជាមួយនឹងព័ត៌មានដែលបានមកពីការសាកសួរបន្ថែមតាមទូរស័ព្ទរបស់អ្នកស្រាវជ្រាវជាមួយនឹងថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក នាយកសាលារៀននីមួយៗដែលបានជ្រើសរើស និងគ្រូបង្រៀនថ្នាក់ទី២ នៃសាលាដែលបានជ្រើសរើសទាំងអស់នោះ។

## ៣.៣. ការជ្រើសរើសសំណាក

ការសិក្សាស្រាវជ្រាវនេះត្រូវបានរៀបចំជាលក្ខណៈបរិមាណវិស័យ និងគុណវិស័យដែល មានការចូលរួមពីភាគីពាក់ព័ន្ធដូចជា ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក នាយក/នាយិកាសាលា ប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូថ្នាក់ទី២។ ភាគសំណាកសម្រាប់ការស្រាវជ្រាវនេះរួមមានថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក ០៣នាក់ នាយក/នាយិកាសាលា ២០នាក់ ប្រធានក្រុមបច្ចេកទេសថ្នាក់ទី២ ចំនួន២០នាក់ និងលោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ ចំនួន ៣១នាក់ នៅខេត្តកំពង់ឆ្នាំង ដោយយកតែស្រុកចំនួនបីប៉ុណ្ណោះ។ សូមបញ្ជាក់ផងដែរថា ខេត្តកំពង់ឆ្នាំង មានក្រុងចំនួន១ និងស្រុកចំនួន៧ និងមានសាលាបឋមសិក្សាចំនួន២៧៩ និងមាន៤៩សាលាកម្រង។ ជាមួយគ្នានេះដែរ អ្នកស្រាវជ្រាវបានជ្រើសរើសភាគសំណាកចំនួន២០សាលា ដែលស្មើនឹង៧.១៦% នៃចំនួនសាលាសរុបប៉ុណ្ណោះ មកធ្វើការស្រាវជ្រាវ ដោយសារតែសាលាទាំង២០គឺជាសាលាដែលបានអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងដល់ថ្នាក់ទី២ហើយ ក្រៅពីនេះពុំទាន់មានសាលាផ្សេងទៀតបានអនុវត្តដល់ថ្នាក់ទី២នៅឡើយ។ មូលហេតុដែលអ្នកស្រាវជ្រាវរើសយកភាគសំណាកខាងលើមកធ្វើការស្រាវជ្រាវ គឺដើម្បីចង់ដឹងអំពីស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងនៅខេត្តកំពង់ឆ្នាំង ពីថ្នាក់ដឹកនាំស្រុក នាយក/នាយិកា និងពីអ្នកអនុវត្តផ្ទាល់គឺប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូនៅសាលាគោលដៅទាំង២០ ពីស្ថានភាពនៃការអនុវត្ត និងសមត្ថភាព ថាតើដូចទៅនឹងការអនុវត្តអំណានដំបូងនៅខេត្តសៀមរាប និងខេត្តកំពង់ធំ ដែលក្រសួងអប់រំ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលបានជួយគាំទ្រដល់លោក

គ្រូ អ្នកគ្រូ ហើយទទួលបានលទ្ធផលសិស្សអាចអានបាន៦៨%(EGRA 2017-2018) គួរឲ្យកោតសរសើរ។ រីឯសំណាកដែលត្រូវជ្រើសរើសមកបំពេញកម្រងសំណួរ និងសម្ភាស គឺអ្នកស្រាវជ្រាវធ្វើការជ្រើសរើសតែសាលាដែលបាននិងកំពុងអនុវត្តកម្មវិធីកញ្ចប់អំណានផ្ទាល់ ហើយសាលាទាំង២០នេះដែរ ក៏បានទទួលការគាំទ្រពីគម្រោង EQUAL នៃអង្គការ Save the Children ផងដែរ។ អ្នកស្រាវជ្រាវបានរៀបចំជាកម្រងសំណួរតាម Google Forms និងតាមរយៈការប្រើសូស(Soft) ជា Microsoft Word Office ផងដែរ ដើម្បីឱ្យភាគសំណាកទាំងអស់អាចមានជម្រើសក្នុងការបំពេញព័ត៌មានជូន ទៅតាមលទ្ធភាពរបស់ពួកគាត់ និងបានបញ្ជូនជាឯកសារពាក់ព័ន្ធទាក់ទងនឹងការសុំអនុញ្ញាតក្នុងការសហការប្រមូលព័ត៌មានជាមុនតាមតេឡេក្រាម (Telegram) ផ្ទាល់ខ្លួននិងហៅទូរស័ព្ទទាក់ទងបន្ថែមទៅតាមពេលវេលាដែលបានកំណត់ និងអាចអនុញ្ញាតបាន។

## ៣.៤. ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវ បានរៀបចំបង្កើតកម្រងសំណួរឡើងដែលជាលក្ខណៈកម្រិតសំណួរ និងចម្លើយ បែបទម្រង់បិទ និងបើកសម្រាប់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក នាយក/នាយិកា ប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូដែលបង្រៀនថ្នាក់ទី២។ កម្រងសំណួរមានបួនប្រភេទ ត្រូវបានបង្កើតឡើង ដើម្បីប្រមូលទិន្នន័យរួមមាន ៖

- កម្រងសំណួរសម្រាប់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក នាយក/នាយិកាសាលា ប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូដែលបង្រៀនថ្នាក់ទី២។ ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរតាមរយៈ Google Forms និងតាមរយៈការប្រើសូស(Soft) ជា Microsoft Word Office ដើម្បីតម្រូវតាមលទ្ធភាពរបស់ពួកគាត់ក្នុងការបំពេញ ដែលអត្ថន័យនៃសំណួរដូចគ្នា។ ក្នុងនោះដែរសម្រាប់ការឆ្លើយតប ដោយការប្រគល់ទិន្នន័យត្រឡប់មកវិញមានជាអាទិ៍៖ ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុកចំនួន៣នាក់ បានបំពេញតាមរយៈ Google Forms ទាំង៣នាក់។ នាយក/នាយិកា២០រូប បានឆ្លើយតបដោយផ្តល់ទិន្នន័យតាម Google Forms

ចំនួន ១២នាក់ និងតាមរយៈសូស(Soft) ជា Microsoft Word Office ចំនួន០៨នាក់ ។ ចំពោះប្រធានក្រុមបច្ចេកទេស បានបំពេញតាម Google Forms ទាំង២០នាក់ និងគ្រូបង្រៀន បានបំពេញតាម Google Forms ចំនួន២១នាក់ និងផ្តល់ជាសូស(Soft) Microsoft Word Office ចំនួន១០នាក់។

ក្នុងការបង្កើតកម្រងសំណួរនេះ អ្នកស្រាវជ្រាវបានរៀបចំតាក់តែងខ្លឹមសារនៃកម្រងសំណួរ ស្របនឹងវិធីសាស្ត្របង្រៀនកញ្ចប់អំណានដំបូង ដែលបានដកស្រង់ចេញពីសៀវភៅណែនាំគ្រូបង្រៀនថ្នាក់ទី២ (ភាគ១ ភាគ២) សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២ ស្តីពីសម្ភារៈជំនួយបន្ថែមលើសៀវភៅសិក្សាគោលភាសាខ្មែរ អាន-សរសេរ របស់ក្រសួងអយក. ឆ្នាំ២០១៩ និងឧបករណ៍សង្កេតការបង្រៀនកញ្ចប់អំណានថ្នាក់ទី២ របស់អង្គការ Save the Children ដើម្បីវាស់សមត្ថភាពលោកគ្រូ អ្នកគ្រូប្រៀបធៀបនឹងការបង្រៀនរបស់ពួកគាត់។

## ៣.៥. កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ

### ៣.៥.១. កម្រងសំណួរសម្រាប់ប្រធានការិយាល័យអយក.នៃរដ្ឋបាលស្រុក

កម្រងសំណួរសម្រាប់ប្រធានការិយាល័យអយក. នៃរដ្ឋបាលស្រុក បែងចែកចេញជាពីរប្រភេទគឺ កម្រងសំណួរទម្រង់បិទ និងកម្រងសំណួរសម្រាប់សម្ភាសន៍ ហើយចែកជាបីផ្នែកគឺ៖

**-ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន** ៖ ក្នុងផ្នែកនេះមាន៨សំណួរ ។ អ្នកស្រាវជ្រាវចង់ដឹងអំពីឈ្មោះ ភេទ អាយុ កម្រិតវប្បធម៌ កម្រិតវិជ្ជាជីវៈ មុខវិជ្ជាឯកទេស(សម្រាប់គ្រូកម្រិតមូលដ្ឋាន ឬគ្រូកម្រិតឧត្តម) រយៈពេលបំពេញការងារក្នុងវិស័យអប់រំ ការទទួលខុសត្រូវលើការងារក្នុងការិយាល័យអយក.ស្រុកបច្ចុប្បន្ន និងរយៈពេលបំពេញតួនាទីជាប្រធានការិ.អយក.ស្រុក និងបទពិសោធការងារនៃអ្នកបំពេញកម្រងសំណួរ។

**-ផ្នែកទី២ ការងារស្នូល ៖** ក្នុងផ្នែកនេះមានចំនួន៩សំណួរ ដោយសំណួរផ្តោតលើប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ក្នុងផ្នែកនេះអ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញពីស្ថានភាពចំណេះដឹង និងសមត្ថភាពថ្នាក់ដឹកនាំការិយាល័យ អំពីកញ្ចប់អំណានដំបូង ថាតើមានស្ថានភាពដូចម្តេច

និងមានភាពរីកចម្រើនកម្រិតណា និងចង់វាស់ស្ទង់មតិរបស់លោកប្រធានការិយាល័យ អំពីស្ថានភាពនៃការដាក់ឲ្យអនុវត្តកម្មវិធីកញ្ចប់អំណានដំបូង។

**-ផ្នែកទី៣ យោបល់ និងសំណូមពរ ៖** គឺចង់ដឹងពីចំណាប់អារម្មណ៍របស់លោកប្រធានការិយាល័យ អំពីស្ថានភាព ប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងនៅសាលាគោលដៅ។

## ៣.៥.២. កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង(នាយក/នាយិកា)

កម្រងសំណួរសម្រាប់នាយក/នាយិកា បានបែងចែកចេញជាពីរប្រភេទគឺ កម្រងសំណួរទម្រង់បិទ និងកម្រងសំណួរសម្រាប់សម្ភាសន៍ ហើយចែកជាបីផ្នែកគឺ៖

**-ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន៖** ក្នុងផ្នែកនេះមាន៩សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងអំពីឈ្មោះ ភេទ អាយុ កម្រិតវប្បធម៌ កម្រិតវិជ្ជាជីវៈ មុខវិជ្ជាឯកទេស(សម្រាប់គ្រូកម្រិតមូលដ្ឋាន ឬគ្រូកម្រិតឧត្តម) រយៈពេលបំពេញការងារក្នុងវិស័យអប់រំ ការទទួលខុសត្រូវលើការងារក្នុងសាលារៀនរបស់ខ្លួនបច្ចុប្បន្ន និងរយៈពេលបំពេញតួនាទីជានាយក/នាយិកា និងបទពិសោធការងារនៃអ្នកបំពេញកម្រងសំណួរ។

**-ផ្នែកទី២ ការងារដឹកនាំ និងគ្រប់គ្រង និងការបង្រៀន និងរៀន៖** ក្នុងផ្នែកនេះមានចំនួន១៤ សំណួរ ដោយសំណួរផ្តោតលើប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ក្នុងផ្នែកនេះអ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញពីស្ថានភាព ចំណេះដឹង និងសមត្ថភាពគណៈគ្រប់គ្រងសាលារៀន អំពីកញ្ចប់អំណានដំបូង ថាតើមានស្ថានភាពដូចម្តេច និងមានភាពរីកចម្រើនកម្រិតណា មានថវិកាសម្រាប់ដំណើរការឬទេ និងចង់វាស់ស្ទង់មតិរបស់នាយក/នាយិកា អំពីស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានដំបូង។

**-ផ្នែកទី៣ យោបល់ និងសំណូមពរ ៖** គឺចង់ដឹងពីចំណាប់អារម្មណ៍របស់នាយក/នាយិកា អំពីស្ថានភាព ប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងនៅសាលារៀនរបស់ខ្លួន។

### ៣.៥.៣. កម្រងសំណួរសម្រាប់ប្រធានក្រុមបច្ចេកទេស

កម្រងសំណួរសម្រាប់ប្រធានក្រុមបច្ចេកទេស បានបែងចែកចេញជាពីរប្រភេទគឺ កម្រងសំណួរទម្រង់បិទ និងកម្រងសំណួរសម្រាប់សម្ភាសន៍ ហើយចែកជាបីផ្នែកគឺ៖

**-ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន៖** ក្នុងផ្នែកនេះមាន៨សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងអំពីឈ្មោះ ភេទ អាយុ កម្រិតវប្បធម៌ កម្រិតវិជ្ជាជីវៈ មុខវិជ្ជាឯកទេស(សម្រាប់គ្រូកម្រិតមូលដ្ឋាន ឬគ្រូកម្រិតឧត្តម) រយៈពេលបំពេញការងារក្នុងវិស័យអប់រំ ការទទួលខុសត្រូវលើការងារ និងតួនាទីរបស់ខ្លួន រយៈពេលបំពេញតួនាទីជាប្រធានក្រុមបច្ចេកទេស រួមទាំងបទពិសោធការងារនៃអ្នកបំពេញកម្រងសំណួរ។

**-ផ្នែកទី២ ការងារបង្រៀន និងរៀន៖** ក្នុងផ្នែកនេះមានចំនួន៩សំណួរ ដោយសំណួរផ្តោតលើការចុះធ្វើអធិការកិច្ចក្នុងនាមជាប្រធានក្រុមបច្ចេកទេស បានធ្វើឬទេ មានចំណុចល្អ និងចំណុចគួរកែលម្អអ្វីខ្លះក្នុងពេលចុះអធិការកិច្ច គ្រូមានរដ្ឋបាលគ្រប់គ្រាន់ឬទេ ពេលប្រជុំក្រុមគ្រូបានចូលរួមគ្រប់គ្នាឬទេ។ ការស្រាវជ្រាវក៏ចង់ដឹងផងដែរ ពីរយៈពេលនៃការអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងនៅសាលារៀនរបស់គាត់ ការចូលរួមសិក្ខាសាលាស្តីអំពីកម្មវិធីកញ្ចប់អំណានដំបូង ថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណានដំបូង អត្ថប្រយោជន៍នៃកម្មវិធីកញ្ចប់អំណាន លទ្ធផលនៃការសិក្សារបស់សិស្សថ្នាក់ទី២លើផ្នែកអំណានមុនពេលអនុវត្តកញ្ចប់អំណាន និងចាប់តាំងពីចាប់ផ្តើមអនុវត្តកញ្ចប់អំណានមក ថាមានភាពរីកចម្រើនយ៉ាងណា។

**-ផ្នែកទី៣ យោបល់ និងសំណូមពរ ៖** គឺចង់ដឹងពីចំណាប់អារម្មណ៍របស់ប្រធានក្រុមបច្ចេកទេស អំពីស្ថានភាព ប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងនៅសាលារៀនរបស់ខ្លួន។

### ៣.៥.៤. កម្រងសំណួរសម្រាប់សម្ភាសលោកគ្រូ អ្នកគ្រូ

កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ បានបែងចែកចេញជាពីរប្រភេទគឺ កម្រងសំណួរទម្រង់បិទ និងកម្រងសំណួរសម្រាប់សម្ភាសន៍ ហើយចែកជាបីផ្នែកគឺ៖

**-ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន៖** ក្នុងផ្នែកនេះមាន៨សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងអំពីឈ្មោះ ភេទ អាយុ កម្រិតវប្បធម៌ កម្រិតវិជ្ជាជីវៈ មុខវិជ្ជាឯកទេស(សម្រាប់គ្រូកម្រិតមូលដ្ឋាន ឬគ្រូកម្រិតឧត្តម) រយៈពេលបំពេញការងារក្នុងវិស័យអប់រំ ការទទួលខុសត្រូវលើការងាររបស់ខ្លួន និងរយៈពេលបំពេញការងារ និងបទពិសោធការងារនៃអ្នកបំពេញកម្រងសំណួរ។

**-ផ្នែកទី២ ការងារបង្រៀន និងរៀន៖** ក្នុងផ្នែកនេះមានចំនួន១៤សំណួរ ដោយសំណួរផ្តោតលើចំនួនសិស្សនៅក្នុងថ្នាក់រៀន ចំនួននៃការចុះអធិការកិច្ចរបស់នាយក ការងាររដ្ឋបាលថ្នាក់រៀន និងផ្ទាល់ខ្លួន មតិលើកសរសើរពីចំណុចល្អ ក៏ដូចជាមតិកែលម្អរបស់អ្នកចុះធ្វើអធិការកិច្ចចំពោះគ្រូបង្រៀន រយៈពេលផ្តល់ព័ត៌មានត្រឡប់ ឬអនុសាសន៍របស់អ្នកចុះធ្វើអធិការកិច្ច រយៈពេលនៃការអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងនៅសាលារៀន ការចូលរួមសិក្ខាសាលាស្តីអំពីកម្មវិធីកញ្ចប់អំណានដំបូង ការសាកសួរពីឧវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណានដំបូងនៅសាលារៀន ការអនុវត្តវិធីសាស្ត្របង្រៀន ទៅតាមលំដាប់លំដោយនៃកម្មវិធីបង្រៀនកញ្ចប់អំណាន សម្រាប់ ថ្នាក់ទី២ ការមើលឃើញ និងបទពិសោធន៍ពីអត្ថប្រយោជន៍នៃកម្មវិធីកញ្ចប់អំណានដំបូងក្នុងសាលារៀន ភាពរីកចម្រើនលើលទ្ធផលសិក្សារបស់សិស្សលើផ្នែកអំណាន របៀបនៃការវាយតម្លៃលើសមត្ថភាពអំណានរបស់សិស្សរបស់គ្រូបង្រៀន។

**-ផ្នែកទី៣ យោបល់ និងសំណូមពរ ៖** គឺចង់ដឹងពីចំណាប់អារម្មណ៍របស់គ្រូបង្រៀន អំពីស្ថានភាពប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងនៅសាលារៀនរបស់ខ្លួន។

## ៣.៦. ដំណើរការប្រមូលទិន្នន័យ

មុនពេលផ្តល់កម្រងសំណួរនេះដល់អ្នកចូលរួមផ្តល់ព័ត៌មាន ជាដំបូង អ្នកស្រាវជ្រាវបានទទួលលិខិតអនុញ្ញាតឱ្យចុះប្រមូលព័ត៌មាន ឬទិន្នន័យពីវិទ្យាស្ថានជាតិអប់រំ ដែលចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលសុំឱ្យប្រធានមន្ទីរនៃខេត្តដែលនិស្សិតត្រូវចុះប្រមូលទិន្នន័យ ក្នុងការចូលរួមសហការ អនុញ្ញាតឱ្យនិស្សិតចុះប្រមូលទិន្នន័យពីសាលារៀនគោលដៅ។ បន្ទាប់មកយកទៅប្រគល់ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ឆ្នាំង ដើម្បីសុំ

អនុញ្ញាតចុះប្រមូលទិន្នន័យស្រាវជ្រាវ បន្ទាប់ពីបានលិខិតអនុញ្ញាតពីលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រួចមក អ្នកស្រាវជ្រាវ ក៏បានយកលិខិតស្នើសុំនោះ ប្រគល់ជូនលោកប្រធានការិយាល័យអយក.នៃរដ្ឋបាលស្រុក នាយក/នាយិកា លោកគ្រូ អ្នកគ្រូ ដើម្បីសុំប្រមូលទិន្នន័យ ព្រមទាំងសម្ភាសលើសំណាកក្នុងនោះរួមមាន ប្រធានការិយាល័យអយក.នៃរដ្ឋបាល ស្រុក នាយក/នាយិកាសាលា និងលោកគ្រូ អ្នកគ្រូនៅតាមសាលាគោលដៅ ដោយអ្នកស្រាវជ្រាវបានផ្តល់ជាកម្រងសំណួរដល់ពួកគាត់ ទាំង Google Forms ទាំង សូស( Soft) ជា Microsoft Word Office តាមតេឡេក្រាមផ្ទាល់ខ្លួនរបស់ពួកគាត់។

## ៣.៧. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យដែលទទួលបាន តាមរយៈការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវប្រើប្រាស់កម្មវិធី Ms Excel ដើម្បីបញ្ចូល និងវិភាគទិន្នន័យ ដើម្បីបង្ហាញភាគរយ និងតារាងក្រាហ្វិក ក្នុងការវិភាគបែបបរិមាណវិស័យ ដែលបង្ហាញពីកម្រិតចម្លើយនៃ សកម្មភាពនានាដែលពាក់ព័ន្ធ ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងនៅបឋមសិក្សា។ រីឯកម្មវិធី Microsoft Word ត្រូវបានប្រើប្រាស់ដើម្បីវិភាគលើកម្រងសំណួរបែបគុណវិស័យ ដោយធ្វើការបកស្រាយពន្យល់លើសំណួរដែលតាក់តែងពាក់ព័ន្ធនឹងទស្សនៈរបស់ភាគីពាក់ព័ន្ធដូចបានរៀបរាប់ខាងលើ។ ដូច្នេះនៅក្នុងការវិភាគចម្លើយ ចំពោះរាល់សំណួរទាំងអស់ ត្រូវបានធ្វើការវិភាគ គឺអាស្រ័យទៅលើប្រភេទនៃសំណួរ ថាតើវាជាប្រភេទកម្រងសំណួរបើកឬកម្រងសំណួរបិទ ទៅតាមប្រភេទនៃសំណួរនីមួយៗ។

## ៣.៨. ក្រមសីលធម៌នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវនេះ ដើម្បីរក្សាបាននូវក្រមសីលធម៌ អ្នកសិក្សាស្រាវជ្រាវបានរៀបចំលិខិត ដើម្បីសុំការអនុញ្ញាតពីថ្នាក់ដឹកនាំនៃមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីបានផ្តល់ដំណឹងបន្តទៅដល់មូលដ្ឋានសាលារៀន និងថ្នាក់ដឹកនាំស្រុកគោលដៅ ក្នុងការសុំប្រមូលទិន្នន័យជាមួយប្រធានការិយាល័យ អប់រំយុវជន និងកីឡា នៃរដ្ឋបាលស្រុក នាយក/នាយិកាសាលា និងគ្រូបង្រៀន។ ដោយសារប្រទេសកម្ពុជាយើង ក៏ដូចជាពិភពលោកកំពុងស្ថិតក្នុងស្ថានភាពនៃការរាតត្បាតនៃជំងឺកូវីដ-

១៩ ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវពុំបានចុះទៅជួបសម្ភាស ជាមួយប្រធានការិយាល័យអយក.នៃរដ្ឋបាលស្រុក នាយក/នាយិកាសាលារៀន និងគ្រូបង្រៀនផ្ទាល់ទេ ដោយយើងបានទំនាក់ទំនង និងជូនព័ត៌មានគ្នាទៅវិញទៅមកតាមរយៈតេឡេក្រាមផ្ទាល់ខ្លួន ព្រមទាំងបានប្រាប់ពួកគាត់អំពីក្រមសីលធម៌របស់អ្នកសិក្សាស្រាវជ្រាវ ដែលជានាអះអាងរក្សានូវរាល់ការសម្ងាត់ចំពោះគ្រប់រាល់ចម្លើយរបស់ពួកគាត់ ដោយមិនបានបង្ហាញពីឈ្មោះរបស់អ្នកចូលរួមឆ្លើយពិតប្រាកដនោះទេ ដើម្បីទាមទារឱ្យបានចម្លើយដែលពិតប្រាកដ និងមានប្រសិទ្ធភាព។

# ជំពូក៤

# លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការវិភាគ បកស្រាយ និងពិភាក្សានូវអ្វីដែលត្រូវបានរកឃើញតាមរយៈកម្រងសំណួរដែលបានបំពេញដោយប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលស្រុក នាយក/នាយិកា ប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ ហើយនឹងបង្ហាញនូវលទ្ធផលដែលប្រមូលបានទៅតាម ខ្លឹមសារនៃកម្រងសំណួរម្តងមួយៗ តាមរយៈតារាង និងក្រាហ្វិក ដែលទាក់ទងនឹងខ្លឹមសារនៃប្រធានបទ ដោយផ្អែកលើចម្លើយនៃទិន្នន័យ ដែលប្រមូលបានពីសំណាកតាមរយៈកម្រងសំណួរ ដើម្បីបង្ហាញឱ្យឃើញពីស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងក្នុងខេត្តកំពង់ឆ្នាំង។

## ៤.១. ឧបករណ៍វិភាគទិន្នន័យ

ដើម្បីវិភាគទិន្នន័យ អ្នកស្រាវជ្រាវបានប្រើកម្មវិធី Microsoft Excel និងកម្មវិធី Microsoft Word ។ កម្មវិធី Microsoft Excel ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីកម្រិតនៃការយល់ឃើញ និងការចូលរួមអនុវត្តពីប្រធានការិយាល័យអយក.នៃរដ្ឋបាលស្រុក នាយក/នាយិកាសាលារៀន ប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ តាមរយៈកម្រងសំណួរ ដោយគិតជាចំនួនភាគរយ និងសង់ជាក្រាបផ្សេងៗ។ ដោយឡែកកម្មវិធី Microsoft Word ត្រូវបានប្រើប្រាស់ដើម្បីវិភាគលើកម្រងសំណួរបែបគុណវិស័យ ដោយធ្វើការបកស្រាយពន្យល់លើសំណួរដែលតាក់តែងពាក់ព័ន្ធនឹងទស្សនៈរបស់ភាគីពាក់ព័ន្ធដូចបានរៀបរាប់ខាងលើ។

## ៤.២. ដំណាក់កាលនៃការវិភាគទិន្នន័យ

នៅក្នុងដំណាក់កាលនៃការវិភាគទិន្នន័យ អ្នកស្រាវជ្រាវធ្វើការវិភាគទិន្នន័យដែលប្រមូលបានតាមរយៈការបំពេញកម្រងសំណួរ។ ការវិភាគកម្រងសំណួរសម្រាប់ប្រធានការិយាល័យអយក. នៃរដ្ឋបាលស្រុក នាយក/នាយិកា ប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ មានគោល

បំណងស្វែងរកឱ្យឃើញពីកម្រិតនៃការយល់ឃើញ ក៏ដូចជាការអនុវត្តរបស់គ្រូបង្រៀន ដើម្បីបង្ហាញឱ្យឃើញពីស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងក្នុងខេត្តកំពង់ឆ្នាំង។

### ៤.៣. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

ទិន្នន័យលើកម្រងសំណួរសម្រាប់អ្នកពាក់ព័ន្ធដូចមានបង្ហាញខាងលើ គឺប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក នាយក/នាយិកា ប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ នឹងត្រូវបានលើកមកធ្វើការបង្ហាញ និងវិភាគម្តងមួយៗទៅតាមលំដាប់។ ដំបូងគឺអ្នកសិក្សាស្រាវជ្រាវវិភាគលើកម្រងសំណួរសម្រាប់ ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក នាយក/នាយិកាសាលា ប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២។

#### ៤.៣.១. ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ និងកម្រិតវប្បធម៌

តាមការគ្រោងទុកសម្រាប់ភាគសំណាកដែលត្រូវបានកំណត់ក្នុងការប្រមូលទិន្នន័យ ជារួមមានចំនួន ៧៤នាក់។ ប៉ុន្តែជាក់ស្តែងនៃទិន្នន័យដែលប្រមូលបាន ក្រោយពេលបូកសរុបទិន្នន័យតាមគោលដៅដែលប្រមូលបានពីការបំពេញកម្រងសំណួរ និងឆ្លើយសំណួរសម្ភាសរួចមក អ្នកសិក្សាស្រាវជ្រាវរកឃើញថា អ្នកចូលរួមឆ្លើយក្នុងការផ្តល់ព័ត៌មាន សរុបមានចំនួនតែ ៦៨នាក់ ស្រី ៣៤នាក់ប៉ុណ្ណោះ បើគិតជាភាគរយបាន ៩១.៨៩% នៃភាគសំណាកដែលបានគ្រោងទុក។ ក្នុងនោះមាន ប្រធានការិយាល័យអយក.នៃរដ្ឋបាលស្រុកបានចំនួន ០២នាក់ ស្រី ០នាក់ នាយក/នាយិកាសាលាបានចំនួន ១៦នាក់ ស្រី ០២នាក់ ប្រធានក្រុមបច្ចេកទេសបានចំនួន ២០នាក់ ស្រី ១០នាក់ និងគ្រូបង្រៀនថ្នាក់ទី២ចំនួន ៣០នាក់ ស្រី ២២នាក់ ។

តារាងទី១ ៖ ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ

| អ្នកចូលរួមឆ្លើយសំណួរ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| ថ្នាក់ដឹកនាំការិយាល័យអយក. ស្រុក | ២នាក់ | ០០នាក់ | ០២នាក់ |

| | | | |
|---|---|---|---|
| នាយក/នាយិកាសាលា | ១៤នាក់ | ០២នាក់ | ១៦នាក់ |
| ប្រធានក្រុមបច្ចេកទេស | ១០នាក់ | ១០នាក់ | ២០នាក់ |
| គ្រូបង្រៀនថ្នាក់ទី២ | ០៨នាក់ | ២២នាក់ | ៣០នាក់ |
| **សរុប** | **៣៤នាក់** | **៣៤នាក់** | **៦៨នាក់** |

យោងតាមតារាងទី១បង្ហាញថា សមាសភាពអ្នកចូលរួមសរុបមានចំនួន ៦៨នាក់ ក្នុងនោះដែរស្រីមានចំនួន ៣៤នាក់ នេះបង្ហាញឱ្យឃើញថា បើគិតតាមយេនឌ័រគឺមានភាពស្មើគ្នាតែម្តង( សមភាពយេនឌ័រ )។

**តារាងទី២ ៖ កម្រិតវប្បធម៌ ថ្នាក់ដឹកនាំការិយាល័យអយក. ស្រុក នាយក/នាយិកា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន**

| កម្រិតវប្បធម៌ | ការិ.អយក.ស្រុក | | នាយក/នាយិកា | | ប្រធានក្រុមបច្ចេកទេស | | គ្រូបង្រៀន | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | |
| អនុបណ្ឌិត | ០១ន | ០០ន | ០០ន | ០០ន | ០០ន | ០០ន | ០០ន | ០០ន | ០១នាក់ |
| បរិញ្ញាបត្រ | ០០ន | ០០ន | ០៧ន | ០១ន | ០១ន | ០៣ន | ០២ន | ០៦ន | ២០នាក់ |
| ជាប់បាក់ឌុប | ០១ន | ០០ន | ០៧ន | ០១ន | ០៩ន | ០៦ន | ០៦ន | ១៣ន | ៤៣នាក់ |
| ទាបជាងបាក់ឌុប | ០០ន | ០០ន | ០០ន | ០០ន | ០០ន | ០១ន | ០០ន | ០៣ន | ០៤នាក់ |
| **សរុប** | ០២ន | ០០ន | ១៤ន | ០២ន | ១០ន | ១០ន | ០៨ន | ២២ន | **៦៨នាក់** |

តាមតារាងទី២បង្ហាញថា ៖ អ្នកដែលបានចូលរួមឆ្លើយសំណួរសម្ភាសន៍រួមមាន៖ ថ្នាក់ដឹកការិយាល័យអយក.ស្រុក មាន០១នាក់ មានកម្រិតវប្បធម៌ថ្នាក់អនុបណ្ឌិត និងម្នាក់ទៀត មានកម្រិតវប្បធម៌ជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ នាយក/នាយិកាសាលាដែលមានកម្រិតវប្បធម៌បរិញ្ញាបត្រ

មានចំនួន ០៨នាក់ ស្រី ០១នាក់ និងមានសញ្ញាបត្រជាប់បាក់ឌុបមានចំនួន ០៨នាក់ ស្រី ០១នាក់។ ចំណែកប្រធានក្រុមបច្ចេកទេសវិញ មានសញ្ញាបត្របរិញ្ញាបត្រចំនួន ០៤នាក់ ស្រី ០៣នាក់ មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំនួន ១៥នាក់ ស្រី ០៦នាក់ និងសញ្ញាបត្រក្រោមមធ្យមសិក្សាទុតិយភូមិចំនួន ០១នាក់ ស្រី ០១នាក់។ ចំពោះគ្រូបង្រៀនវិញបានចូលរួមសរុប មានចំនួន ៣០នាក់ ស្រី២២នាក់។ លោកគ្រូ អ្នកគ្រូដែលមានកម្រិតវប្បធម៌ ថ្នាក់បរិញ្ញាបត្រមានចំនួន ០៨នាក់ ស្រី ០៦នាក់ ជាប់បាក់ឌុបមានចំនួន ១៩នាក់ ស្រី ១៣នាក់ និងក្រោមបាក់ឌុបមានចំនួន ០៣នាក់ ស្រី ០៣នាក់។ ដូចនេះឃើញថាចំនួនអ្នកចូលរួម ដែលមានកម្រិតសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានចំនួនច្រើនជាងអ្នកដែលមានកម្រិតវប្បធម៌បរិញ្ញាបត្រ និងអនុបណ្ឌិត ចំណែកក្រោមបាក់ឌុបមានតែ ០៤នាក់ប៉ុណ្ណោះ។

### ៤.៣.២. ការវិភាគទិន្នន័យលើកម្រងសំណួរប្រធានការិយាល័យអយក.ស្រុក

**ផ្នែកទី១៖ ព័ត៌មានទូទៅ**

**តារាងទី៣៖ បង្ហាញពីបទពិសោធការងារអ្នកចូលរួមផ្តល់សម្ភាសន៍ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក ក្នុងដំណែងជាប្រធានការិយាល័យ៖**

| បទពិសោធ | ចំនួនអ្នកចូលរួម | ភាគរយ |
|---|---|---|
| ៤ឆ្នាំ | ២នាក់ | ១០០% |

តាមរយៈតារាងទី៣ បង្ហាញថាប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុកទាំងពីររូបមានបទពិសោធជាប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុករយៈ៤ឆ្នាំស្មើគ្នា។

**តារាងទី៤៖ បង្ហាញពីអំពីរយៈពេលបំពេញការងារក្នុងវិស័យអប់រំរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក៖**

| បទពិសោធ | ចំនួនអ្នកចូលរួម | ភាគរយ |
|---|---|---|
| ១៩ឆ្នាំ | ១នាក់ | ១០០% |

| | | |
|---|---|---|
| ៤០ឆ្នាំ | ១នាក់ | ១០០% |

តាមរយៈតារាងទី៤ បង្ហាញថាប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុកទាំង១រូបបានបំពេញការងារក្នុងវិស័យអប់រំអស់រយៈពេល១៩ឆ្នាំ និងម្នាក់ទៀតបានបំពេញការងារក្នុងវិស័យអប់រំអស់រយៈពេល៤០ឆ្នាំហើយ។ ដូចនេះបង្ហាញថាអ្នកទាំងពីរសុទ្ធតែមានបទពិសោធយូរឆ្នាំក្នុងវិស័យអប់រំ។




**ក្រាបទី១៖ បង្ហាញពីកម្រិតវិជ្ជាជីវៈរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក**

តាមរយៈក្រាបទី១បង្ហាញថាក្នុងចំណោមប្រធានការិយាល័យអយក.នៃរដ្ឋបាលស្រុកទាំងពីរនាក់មានម្នាក់ជាគ្រូបង្រៀនកម្រិតឧត្តម និងម្នាក់ទៀតជាគ្រូបង្រៀនកម្រិតមូលដ្ឋាន។




**ក្រាបទី២៖ បង្ហាញពីភេទអ្នកចូលរួមផ្តល់ទិន្នន័យ របស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក**

ក្រាបទី២ បង្ហាញពីភេទរបស់ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុកមានទាំង ០២រូប សុទ្ធតែប្រុស ស្មើនឹង១០០% ។

### ផ្នែកទី២៖ ការងារដឹកនាំ និងគ្រប់គ្រង




ក្រាបទី៣៖ បង្ហាញពីការចុះអធិការកិច្ច របស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក

ក្រាបទី៣ បង្ហាញថាការធ្លាប់ចុះអធិការកិច្ចនៅសាលាបឋមសិក្សាគោលដៅរបស់លោកប្រធានទី២ក្នុងស្រុករបស់គាត់បាន៨០% និងលោកប្រធានទី១ បានចំនួន៥០% ប៉ុណ្ណោះ។




ក្រាបទី៤៖ បង្ហាញពីការអនុវត្តកម្មវិធីកញ្ចប់អំណាននៅតាមសាលាគោលដៅ នៃស្រុកទាំង២

តាមការផ្តល់ទិន្នន័យរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក

យោងតាមក្រាបទី៤ បង្ហាញថា សាលាបឋមសិក្សាគោលដៅ ក្នុងស្រុកទាំងពីរ គឺបានអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង ពីថ្នាក់ទី១ ដល់ថ្នាក់ទី២ បាន១០០% គឺគ្មានសាលាណាមួយមិនបានអនុវត្តនោះឡើយ គឺបានគ្រប់សាលា។




**ក្រាបទី៥៖ បង្ហាញពីការងាររដ្ឋបាល(កិច្ចតែងការ)របស់លោកគ្រូ អ្នកគ្រូ នៅតាមសាលាគោលដៅ នៃស្រុកទាំង២ តាមការផ្តល់ទិន្នន័យរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក**

តាមរយៈក្រាបទី៥ បង្ហាញថា ក្នុងចំណោមស្រុកទាំងពីរគឺ ស្រុកទី១ គ្រូមានកិច្ចតែងការមិនគ្រប់មេរៀនទេ មូលហេតុបានបញ្ជាក់ថា គាត់ទើបតែត្រូវបានឱ្យឡើងទៅបង្រៀនថ្នាក់ទី២ថ្មីសម្រាប់ឆ្នាំសិក្សានេះ តែដោយមានការរាតត្បាតពីជំងឺកូវីដ-១៩សាលាត្រូវផ្អាកដំណើរការ ប៉ុន្តែសម្រាប់គ្រូដែលធ្លាប់បង្រៀនហើយគឺមានគ្រប់មេរៀនផងដែរ។ ទោះបីគាត់ មិនបានតែងចប់គ្រប់មេរៀនក៏ដោយ តែក៏ស្ថិតក្នុងកម្រិតខ្ពស់ផងដែរ គឺបាន៨០%។ ចំពោះស្រុកមួយទៀតគ្រូគាត់ធ្លាប់បង្រៀនមួយឆ្នាំមុនការរាតត្បាតនៃជំងឺកូវីដ-១៩មកហើយ ដូច្នេះ កិច្ចតែងការរបស់គាត់មានគ្រប់មេរៀន ស្មើនឹង១០០% ដោយគាត់គ្រាន់តែធ្វើបច្ចុប្បន្នភាពបន្តិចបន្តួចប៉ុណ្ណោះ សម្រាប់បង្រៀនក្នុងឆ្នាំសិក្សាថ្មី។



## ក្រាបទី៦៖ បង្ហាញពីការចូលរួមសិក្ខាសាលាស្ដីពីកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់ប្រធានការិយាល័យ អប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក

ក្រាបទី៦ បង្ហាញថា លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុកទាំងពីរ សុទ្ធតែធ្លាប់បានចូលរួមសិក្ខាសាលាស្ដីពីកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង ដែលឧបត្ថម្ភឡើងដោយគម្រោង EQUAL នៃអង្គការ Save the Children ដូចៗគ្នា។




## ក្រាបទី៧៖ បង្ហាញពីថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់សាលារៀនគោលដៅ តាមទិន្នន័យរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក

ក្រាបទី៧ បង្ហាញថាក្នុងស្រុកទី១ មានថវិកាដំណើរការកម្មវិធីកញ្ចប់អំណាន ដោយក្នុងចំណោម ៦សាលា មានតែ២សាលាប៉ុណ្ណោះ គឺស្មើនឹង៣៣.៣៣%។ ចំណែកស្រុកមួយទៀតក្នុងចំណោម៦ សាលា មាន៤សាលា ដែលបានគ្រោងថវិកាដំណើរការសាលារៀនមួយផ្នែកសម្រាប់អនុវត្តកម្មវិធីកញ្ចប់អំណាននៅសាលារៀន។ ចំណែកឯសាលាដែលមិនមានថវិកាសម្រាប់កម្មវិធីកញ្ចប់អំណាន ដោយសារសាលាមិនបានបញ្ចូលគម្រោងថវិកាទៅក្នុងផែនការប្រតិបត្តិរបស់សាលារៀន។



ក្រាបទី៨៖ បង្ហាញពីគំនិតយល់ឃើញពីសារៈប្រយោជន៍នៃកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់សាលារៀនគោលដៅ តាមទិន្នន័យរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក

តាមរយៈក្រាបទី៨ បង្ហាញថា លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុកយល់ឃើញថា កម្មវិធីកញ្ចប់អំណានពិតជាមានសារៈសំខាន់ណាស់ក្នុងការបង្ហាត់បង្រៀនសិស្សឱ្យចាប់ចេះអាន និងសរសេរ។ ខាងក្រោមនេះជាទស្សនៈយល់ឃើញពីសារៈប្រយោជន៍ និងលទ្ធផលសិក្សារបស់សិស្សក្នុងការសិក្សាកម្មវិធីកញ្ចប់អំណាន៖

- ជួយដល់គ្រូបង្រៀន សិស្សងាយស្រួលបង្រៀន និងរៀនទៅតាមលំហូរនៃកម្មវិធីកញ្ចប់អំណាន
- បានផ្តល់វិធីសាស្ត្រថ្មីៗងាយស្រួលក្នុងការបង្រៀនមុខវិជ្ជាភាសាខ្មែរដល់គ្រូបង្រៀន ធ្វើឱ្យសិស្សចូលចិត្តរៀនមុខវិជ្ជាភាសាខ្មែរ និងចាប់ចេះអាន ចេះសរសេរ
- ការបង្រៀនរបស់គ្រូមានភាពសម្បូរបែបទាំងសម្ភារៈបង្រៀន និងរៀន។

**៤.៣.៣. ការវិភាគទិន្នន័យលើកម្រងសំណួរនាយក/នាយិកាសាលារៀន**

**ផ្នែកទី១៖ ព័ត៌មានទូទៅ**




ក្រាបទី៩៖ បង្ហាញពីភេទរបស់គណៈគ្រប់គ្រង

តាមរយៈក្រាបទី៩បង្ហាញថា នាយក/នាយិកាដែលបានជួយបំពេញកម្រងសំណួរទាំងអស់មានចំនួន១៦រូប។ ទាក់ទងទៅនឹងភេទគណៈគ្រប់គ្រងដែលមានភេទប្រុស មានភាគរយខ្ពស់ជាងរហូតដល់

៨៧.៥% ចំណែកឯគណៈគ្រប់គ្រងភេទស្រីមានតែ១២.៥%ប៉ុណ្ណោះ។ តាមរយៈរូបភាពខាងលើ យើងអាចសន្និដ្ឋានបានថា គណៈគ្រប់គ្រងភាគច្រើនជាមនុស្សប្រុស។

### តារាងទី៥៖ បង្ហាញពីកម្រិតអាយុរបស់នាយក/នាយិកា

| ល.រ | អាយុ | ប្រុស | ស្រី | សរុប | ភាគរយ |
|---|---|---|---|---|---|
| ១ | ៣០ទៅ៤០ឆ្នាំ | ៣ | ០ | ៣ | ១៨.៧៥% |
| ២ | ៤១ទៅ៥០ឆ្នាំ | ១១ | ១ | ១២ | ៧៥% |
| ៣ | លើស៥១ឆ្នាំ | ០ | ១ | ១ | ៦.២៥% |
| **សរុប** | | **១៤** | **២** | **១៦** | **១០០%** |

ក្នុងចំណោមអាយុគណៈគ្រប់គ្រង ដែលបានបំពេញកម្រងសំណួរទាំងអស់ មានកម្រិតអាយុផ្សេងៗគ្នា។ គណៈគ្រប់គ្រងដែលមានអាយុចន្លោះពី៣០ទៅ៤០ឆ្នាំ មានចំនួន១៨.៧៥%។ ចំណែកឯគណៈគ្រប់គ្រងអាយុចន្លោះពី៤១ទៅ៥០ឆ្នាំ មានចំនួន៧៥%។ គណៈគ្រប់គ្រងដែលមានអាយុលើសពី៥១ ឆ្នាំមានចំនួន ៦.២៥% ។ តាមរយៈតារាងខាងលើ អាចសន្និដ្ឋានបានថា គណៈគ្រប់គ្រងភាគច្រើនជាបុគ្គល ដែលមានអាយុចន្លោះពី៤១ទៅ៥០ឆ្នាំ គឺជាវ័យដែលមានសក្តានុពលល្អសម្រាប់ចូលរួមធ្វើការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអប់រំ។

### តារាងទី៦៖ បង្ហាញពីរយៈពេលបំពេញការងារក្នុងវិស័យអប់រំរបស់នាយក/នាយិកា

| ល.រ | រយៈពេលបំពេញការងារ | ប្រុស | ស្រី | សរុប | ភាគរយ |
|---|---|---|---|---|---|
| ១ | ១០-១៥ឆ្នាំ | ០១នាក់ | ០០នាក់ | ០១នាក់ | 6.25% |
| ២ | ១៦-២០ឆ្នាំ | ០២នាក់ | ០១នាក់ | ០៣នាក់ | 18.75% |
| ៣ | ២១-២៥ឆ្នាំ | ០៥នាក់ | ០០នាក់ | ០៥នាក់ | 31.25% |
| ៤ | ២៦-៣០ឆ្នាំ | ០៣នាក់ | ០០នាក់ | ០៣នាក់ | 18.75% |

| | | | | | |
|---|---|---|---|---|---|
| ៥ | លើស៣០ឆ្នាំ | ០៣នាក់ | ០១នាក់ | ០៤នាក់ | 25% |
| **សរុប** | | **១៤នាក់** | **០២នាក់** | **១៦នាក់** | **100%** |

តាមរយៈតារាងទី៧ បង្ហាញថា នាយក/នាយិកាទាំង១៦រូប មានរយៈពេលក្នុងការបំពេញការងារក្នុងវិស័យអប់រំផ្សេងៗគ្នា គឺបើគិតពី១០-១៥ឆ្នាំ មានចំនួន ០១នាក់ ស្រី ០ គិតជាភាគរយស្មើនឹង ៦.២៥%។ រយៈពេលចន្លោះពី១៦-២០ឆ្នាំ មានចំនួន ០៣នាក់ ស្រី ០១នាក់ គិតជាភាគរយ ១៨.៧៥% រយៈពេលពី២១-២៥ឆ្នាំ មានចំនួន០៥នាក់ ស្រី០ គិតជាភាគរយស្មើនឹង ៣១.២៥%។ ចំពោះរយៈពេលពី២៦-៣០ មានចំនួន ០៣នាក់ ស្រី ០ គិតជាភាគរយស្មើនឹង ១៨.៧៥% និងអ្នកដែលមានអតីតភាពការងារលើសពី៣០ឆ្នាំ មានចំនួន ០៣នាក់ ស្រី ០១នាក់ គិតជាភាគរយស្មើនឹង ២៥%។ ដូចនេះតាមរយៈការពិនិត្យលើអតីតភាពការងាររបស់នាយក/នាយិកាទាំង១៦រូប ឃើញថាអ្នកដែលមានអតីតភាពការងារចន្លោះពី២១-២៥ឆ្នាំ មានចំនួនច្រើនជាងគេ មានន័យថាគឺជារយៈពេល ដែលស្ថិតក្នុងកម្រិតមធ្យមនៅក្នុងការបំពេញក្របខណ្ឌ នៃវិស័យអប់រំ។ ចំណែកអ្នកដែលមានអតីតភាពការងារលើសពី៣០ឆ្នាំ គឺមានចំនួន ០៤នាក់ ក្នុងនោះស្រី ០១នាក់ ជារយៈពេលមួយដ៏វែង ដែលពួកគាត់បានចំណាយពេលវេលាក្នុងការជួយអភិវឌ្ឍវិស័យអប់រំរបស់យើង ហើយបើតាមរយៈពេលនេះគឺគាត់អាចដាក់ពាក្យចូលនិវត្តន៍មុនអាយុកាលចូលនិវត្តន៍បាន។

**តារាងទី៧៖ បង្ហាញពីរយៈពេលបំពេញតួនាទីជាគណៈគ្រប់គ្រងសាលា**

| ល.រ | រយៈពេលបំពេញតួនាទី | ប្រុស | ស្រី | សរុប | ភាគរយ |
|---|---|---|---|---|---|
| ១ | ១-៥ឆ្នាំ | ០៧នាក់ | ០២នាក់ | ០៩នាក់ | 56.25% |
| ២ | ៦-១០ឆ្នាំ | ០៦នាក់ | ០០នាក់ | ០៦នាក់ | 37.5% |
| ៣ | ១១-១៥ឆ្នាំ | ០០នាក់ | ០០នាក់ | ០០នាក់ | 0% |
| ៤ | ១៦-២០ឆ្នាំ | ០០នាក់ | ០០នាក់ | ០០នាក់ | 0% |

| | | | | | |
|---|---|---|---|---|---|
| ៥ | លើស២០ឆ្នាំ | ០១នាក់ | ០០នាក់ | ០១នាក់ | 6.25% |
| **សរុប** | | **១៨នាក់** | **០២នាក់** | **២០នាក់** | **100%** |

តាមរយៈតារាងទី៨ បង្ហាញថានាយក/នាយិកា ដែលមានបទពិសោធជាគណៈគ្រប់គ្រងសាលាមានរយៈពេលគ្រប់គ្រងខុសៗគ្នា ទៅតាមកាលបរិច្ឆេទនៃការតែងតាំង។ ក្នុងនោះដែរ គណៈគ្រប់គ្រងដែលមានរយៈពេលក្នុងការបំពេញតួនាទីពី០១-០៥ឆ្នាំ មានចំនួន០៩នាក់ ស្រី០២នាក់ ស្មើនឹង៥៦.២៥% ពី០៦-១០ឆ្នាំ មានចំនួន០៦នាក់ ស្រី០ ស្មើនឹង៣៧.៥% ពី១១-១៥ឆ្នាំ គ្មាន ស្មើនឹង០% ពី១៦-២០ឆ្នាំ ក៏គ្មាន ស្មើនឹង០%ដែរ។ ចំពោះអ្នកដែលមានរយៈពេលដឹកនាំ និង គ្រប់គ្រងលើសពី២០ឆ្នាំ មានចំនួន ០១នាក់ ស្រី០ គិតជាភាគរយ ស្មើនឹង៦.២៥%។ ដូចនេះក្នុងចំណោមគណៈគ្រប់គ្រងទាំង១៦នាក់ ឃើញថា អ្នកដែលមានរយៈពេលដឹកនាំ និងគ្រប់គ្រងសាលារៀនមានរយៈពេលពី១-៥ឆ្នាំ មានចំនួនច្រើនជាងគេរហូតដល់០៩នាក់ ទោះបីពួកគាត់ទើបតែទទួលបានតួនាទីក្នុងការដឹកនាំ និងគ្រប់គ្រងសាលារៀនក៏ពិតមែន ប៉ុន្តែការដឹកនាំ និងគ្រប់គ្រងសាលារៀនរបស់ពួកគាត់ឃើញថាល្អ តាំងពីហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន និងលទ្ធផលសិក្សារបស់សិស្សមានការរីកចម្រើនគួរឱ្យកោតសរសើរ។

### តារាងទី៨៖ បង្ហាញពីកម្រិតសញ្ញាបត្ររបស់គណៈគ្រប់គ្រងសាលា

| ល.រ | កម្រិតសញ្ញាបត្រ | ប្រុស | ភាគរយ | ស្រី | ភាគរយ | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|
| ១ | ស.បរិញ្ញាបត្រ | ០៧នាក់ | 43.75% | ០១នាក់ | 6.25% | ០៨នាក់ | 50% |
| ២ | ស.មធ្យមសិក្សាទុតិយភូមិ | ០៧នាក់ | 43.75% | ០១នាក់ | 6.25% | ០៨នាក់ | 50% |
| ៣ | ក្រោមបាក់ឌុប | ០០នាក់ | 0% | ០នាក់ | 0% | 0% | 0% |

យោងតាមរយៈតារាងទី៩ បង្ហាញថាគណៈគ្រប់គ្រងដែលមានសញ្ញាបត្របរិញ្ញាបត្រភេទប្រុសមានចំនួន ០៧នាក់ ត្រូវជា ៤៣.៧៥% ភេទស្រីមានចំនួន ០១នាក់ ត្រូវជា ៦.២៥% ជារួមត្រូវជា ៥០% ។ ចំពោះគណៈគ្រប់គ្រងដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ភេទប្រុសមានចំនួន ០៧នាក់ ស្មើនឹង ៤៣.៧៥% ភេទស្រីមានចំនួន ០១នាក់ ស្មើនឹង ៦.២៥% ហើយជារួមស្មើនឹង ៥០%។ ចំណែក

សញ្ញាបត្រក្រោមមធ្យមសិក្សាបឋមភូមិគឺគ្មាន។ ដូចនេះឃើញថាចំនួនភាគរយនៃសញ្ញាបត្របរិញ្ញាបត្រ និងមធ្យមសិក្សាទុតិយភូមិមានចំនួនភាគរយស្មើគ្នា ទាំងចំនួនភាគរយប្រុស ស្រីក៏ស្មើគ្នា។

### តារាងទី៩៖ បង្ហាញពីកម្រិតវិជ្ជាជីវៈរបស់គណៈគ្រប់គ្រងសាលា

| ល.រ | កម្រិតវិជ្ជាជីវៈ | ប្រុស | ភាគរយ | ស្រី | ភាគរយ | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|
| ១ | គ្រូកម្រិតឧត្តម | ០០នាក់ | 0% | ០០នាក់ | 0% | 0% | 0% |
| ២ | គ្រូកម្រិតមូលដ្ឋាន | ០៦នាក់ | ៣៧.៥% | ០២នាក់ | ១២.៥% | ០៨នាក់ | ៥០% |
| ៣ | គ្រូបឋមសិក្សា | ០៨នាក់ | ៥០% | ០០នាក់ | 0% | ០៨នាក់ | ៥០% |

យោងតាមរយៈតារាងទី១០ បង្ហាញថាគណៈគ្រប់គ្រងដែលមានកម្រិតវិជ្ជាជីវៈជាគ្រូកម្រិតឧត្តមគឺគ្មាន ស្មើនឹង 0%។ ចំពោះគណៈគ្រប់គ្រងដែលមានកម្រិតវិជ្ជាជីវៈជាគ្រូកម្រិតមូលដ្ឋានភេទប្រុស មានចំនួន ០៦នាក់ ត្រូវជា ៣៧.៥% ភេទស្រីមានចំនួន ០២នាក់ ត្រូវជា ១២.៥% ជារួមមានចំនួន ០៨នាក់ ត្រូវជា ៥០%។ ចំពោះគណៈគ្រប់គ្រងដែលមានកម្រិតវិជ្ជាជីវៈជាគ្រូបង្រៀនកម្រិតបឋមសិក្សា ភេទប្រុសមានចំនួន ០៨នាក់ ស្មើនឹង ៥០% ភេទស្រី ០ ស្មើនឹង 0%។ ដូចនេះឃើញថាគណៈគ្រប់គ្រងទាំង១៦រូប មានកម្រិតវិជ្ជាជីវៈតែពីរកម្រិតប៉ុណ្ណោះ គឺជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងជាគ្រូបង្រៀនកម្រិតបឋម ហើយចំនួននៃភាគរយក៏ស្មើគ្នាទៀត គឺ៥០% ដូចគ្នា ខុសគ្នាតែភាគរយនៃគណៈគ្រប់គ្រងស្រីប៉ុណ្ណោះ គឺជាគ្រូកម្រិតមូលដ្ឋានមានចំនួន ០២នាក់ ឯគ្រូកម្រិតបឋមជាស្រីគ្មាន។

## ផ្នែកទី២៖ ការដឹកនាំ និងគ្រប់គ្រង



## ក្រាបទី១០៖ បង្ហាញពីចំនួនថ្នាក់ទី២ តាមសាលានីមួយៗ នៃសាលាសំណាកទាំង១៦

ក្រាបទី១០ បង្ហាញថាចំនួនថ្នាក់ទី២ ដែលមានតែ១ថ្នាក់ មានចំនួន៦សាលា ត្រូវជា៣៧.៥% សាលាដែលមានថ្នាក់ទី២ ចំនួន២ថ្នាក់ មាន៧សាលា ស្មើនឹង៤៣.៧៥% សាលាដែលមានថ្នាក់ទី២ ចំនួន៣ថ្នាក់ មាន២សាលា ស្មើនឹង១២.៥% និងសាលាដែលមានថ្នាក់ទីរហូតទៅដល់ ៤ថ្នាក់ មានចំនួនតែ១សាលាប៉ុណ្ណោះ ស្មើនឹង ៦.២៥%។ ដូចនេះតាមរយៈរូបភាពបង្ហាញថា ចំនួនថ្នាក់ទី២ មានចំនួនច្រើន ឬតិចថ្នាក់អាស្រ័យទៅតាមចំនួននិយាមសិស្ស នៃថ្នាក់រៀន នៅតាមសាលានីមួយៗ។




## ក្រាបទី១១៖ បង្ហាញពីចំនួនវេនសិក្សា តាមសាលានីមួយៗ នៃសាលាសំណាកទាំង១៦

តាមរយៈក្រាបទី១១ បង្ហាញពីវេនសិក្សានៅតាមសាលាសំណាកទាំង១៦ នៃស្រុកទាំង៣ តាមការផ្តល់ទិន្នន័យរបស់នាយក/នាយិកាសាលា ក្នុងនោះដែរ សាលាដែលមានតែ១វេនសិក្សា មានចំនួន ៦ សាលា ស្មើនឹង ៣៧.៥% និងសាលាដែលបានអនុវត្ត ២វេនសិក្សា មានចំនួន១០សាលា ត្រូវជា ៦២.៥% ។ ដូចនេះបង្ហាញថា សាលាដែលបានអនុវត្តការបង្រៀនចំនួន២វេនសិក្សា មានចំនួនច្រើនជាងសាលាដែលអនុវត្តការបង្រៀនតែ១វេនសិក្សា។



### ក្រាបទី១២៖ បង្ហាញពីផែនការអធិការកិច្ចតាមសាលាសំណាក ដែលផ្ដល់ទិន្នន័យដោយនាយក/នាយិកាសាលា

យោងតាមក្រាបទី១២ បង្ហាញថា គ្រប់សាលាសំណាកដែលបានផ្ដល់ទិន្នន័យទាំងអស់សុទ្ធតែមានផែនការអធិការកិច្ចថ្នាក់រៀនគ្រប់សាលាទាំងអស់ គឺស្មើនឹង១០០%។




### ក្រាបទី១៣៖ បង្ហាញពីចំនួនសាលា និងភាគរយនៃការអនុវត្តផែនការ ចុះធ្វើអធិការកិច្ចថ្នាក់រៀន តាមការផ្ដល់ទិន្នន័យរបស់នាយក/នាយិកាសាលា

តាមរយៈក្រាបទី១៣ បង្ហាញពីការអនុវត្តតាមផែនការចុះអធិការកិច្ចថ្នាក់រៀន ដែលមានហើយរបស់នាយក/នាយិកា នាយករង/នាយិការង នៃសាលារៀនសំណាក ដែលផ្ដល់ទិន្នន័យដោយនាយក/នាយិកាសាលា ទៅតាមកម្រងសំណួរដែលបានសួរថា« តើលោក/លោកស្រីបានចុះអធិការកិច្ចថ្នាក់រៀនដែរឬទេ? បើបាន តើបានប៉ុន្មានភាគរយ?»។ ក្នុងនោះដែរចម្លើយដែលឆ្លើយថា«បាន»មានចំនួនទាំង១៦សាលា តែភាគរយនៃការដែលបានអនុវត្តនោះខុសៗគ្នា។ ជាមួយគ្នានេះដែរ យើងក៏បានយកភាគរយនៃការអនុវត្តផែនការអធិការកិច្ចរបស់សាលាទាំងអស់ មកធ្វើការបែងចែកជាក្រុម ដើម្បីរកឱ្យឃើញនូវភាគរយ នៃចំនួនសាលាសំណាកសរុបទាំង១៦ ថាតើមានចំនួនប៉ុន្មានសាលាដែលបានអនុវត្ត និងមានភាគរយខ្ពស់ជាងគេ។ ដូចនេះតាមរយៈរូបភាពទី១៣ បានបញ្ជាក់ថា មិនមានសាលាដែលមិនបានអនុវត្តផែនការសោះនោះឡើយ ស្មើនឹង០%។ ចំពោះសាលាដែលបានអនុវត្តពី១០-២០% មានចំនួន២សាលា ស្មើនឹង១២.៥% សាលាដែលបានអនុវត្តពី២១-៣០% មានចំនួន២សាលា ស្មើនឹង ១២.៥% សាលា

ដែលបានអនុវត្តពី៣១-៤០% គ្មាន ស្មើនឹង០% សាលាដែលបានអនុវត្តពី៤១-៥០%មានចំនួន៤សាលា ស្មើនឹង២៥% សាលាដែលបានអនុវត្តពី៥១-៦០% មានចំនួន២សាលា ស្មើនឹង១២.៥% សាលាដែលអនុវត្តបានពី៦១-៧០% គ្មាន ស្មើនឹង០% សាលាដែលអនុវត្តបានពី៧១-៨០% មានចំនួន៣សាលា ស្មើនឹង១៨.៧៥% សាលាដែលបានអនុវត្តពី៨១-៩០% មានចំនួន៣សាលា ស្មើនឹង១៨.៧៥% និងសាលាដែលបានអនុវត្តពី៩១-១០០% គឺគ្មាន ស្មើនឹង ០%។ ចំពោះសាលាដែលអនុវត្ត បានតិចតួច បានលើកឡើងថា ដោយសារបេរិបទកូវីដ-១៩ ត្រូវបានបិទសាលា។ ប៉ុន្តែក៏សុំកោតសរសើរចំពោះសាលាដែលបានអនុវត្តរហូតដល់៩០ភាគរយ ដោយសារពួកគាត់បានចុះមុនពេលបិទសាលា តែអំឡុងពេលបិទសាលាគឺគ្មានការចុះអធិការកិច្ចថ្នាក់រៀនដូចគ្នា។

ដោយផ្អែកលើទិន្នន័យនៃការសាកសួរបន្ថែមបែបគុណវិស័យ ចំពោះនាយក/នាយិកាសាលា អំពីចំណុចល្អ និងចំណុចគួរកែលម្អលើការងារបង្រៀន និងរៀនរបស់លោកគ្រូ/អ្នកគ្រូក្នុងការអនុវត្តកម្មវិធីកញ្ចប់អំណានដំបូង គឺទទួលបានលទ្ធផលជារួមមកដូចខាងក្រោម៖

### ក. ចំណុចល្អ៖

- គ្រូបង្រៀនបានគ្រប់ជំហាន

- ដើរតាមលំនាំនៃការបង្រៀនបែបកញ្ចប់អំណាន

- មានភាពរស់រវើក និងមានការបត់បែន

- អនុវត្តតាមវិធីសាស្ត្រ«ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ ឬគ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើ( I do, We do, You do )»

- គ្រូបានជួយសម្របសម្រួលសិស្សតាមតុទាក់ទងនឹងការសរសេរ ការអាន

- ការប្រើសំណួរបំផុសមានភាពទាក់ទាញ

- មានការយកចិត្តទុកដាក់ និងជួយសិស្សរៀនយឺត

- មានកិច្ចតែងការបង្រៀន និងមានគោលបំណងច្បាស់លាស់ បង្រៀនតាមជំហានៗ មានសកម្មភាពសិស្សសួរ និងឆ្លើយ ពិសេសសិស្សបរិយាបន្ន

- រៀបចំការងាររដ្ឋបាលបានល្អ(បានបំពេញបញ្ជី សៀវភៅ តារាងផ្សេងៗបានគ្រប់គ្រាន់ មានផែនការជួយសិស្សរៀនយឺតតាមសប្តាហ៍ក្នុងខែ ប្រើកិច្ចតែងការដែលមានវត្ថុបំណងច្បាស់លាស់ ក្នុងពេលបង្រៀនសិស្ស បានប្រើប្រាស់សម្ភារៈឧបទេសសមស្របតាមខ្លឹមសារមេរៀន ក្នុងម៉ោងបង្រៀន) និងតុបតែងថ្នាក់បានស្អាត មានអនាម័យ(សមស្របនឹងកម្រិតថ្នាក់) ហើយគ្រូមានសម្លៀកបំពាក់សមរម្យសំឡេងឮច្បាស់ល្អ

- លោកគ្រូ/អ្នកគ្រូបន្ទុកថ្នាក់បានយកវិធីសាស្ត្របង្រៀន ដែលទទួលបានថ្មីៗដូចជាកញ្ចប់អំណានថ្នាក់ទី១ ថ្នាក់ទី២ គណិតវិទ្យាថ្នាក់ទី៣ និងវិធីសាស្ត្របែបស្រាវជ្រាវថ្នាក់ទី៤ទី៥ទី៦ ការបង្រៀនមានបញ្ចូលល្បែងសិក្សា ពេលបញ្ចប់មេរៀនមានកិច្ចការវង្វាយតម្លៃសមត្ថភាពសិស្ស

-ការគ្រប់គ្រងវិន័យសិស្សក្នុងពេលបង្រៀនបានល្អការបង្រៀនគោរពពេលម៉ោងបានល្អ

### ខ. ចំណុចគួរកែលម្អ៖

- ពង្រឹងលើវិធីសាស្ត្របង្រៀនដែលមានស្រាប់ និងរបៀបរកវត្ថុបំណងមេរៀន

- ការបង្រៀនមិនទាន់កម្មវិធីសិក្សា

- ការបង្រៀនតាមកញ្ចប់អំណានលើសម៉ោងសិក្សា ដើម្បីឱ្យលោកគ្រូ អ្នកគ្រូ បង្រៀនត្រឹមត្រូវតាមម៉ោងសិក្សាបាន តម្រូវឱ្យគាត់ផលិតសម្ភារៈឧបទេសឱ្យបានច្រើនឲ្យបានច្រើន

- គ្រូគប្បីហៅសិស្សដែលរៀនយឺតឲ្យបានញឹកញាប់ និងត្រូវចេះពីរបៀបបង្កើត និងប្រើប្រាស់សំណួរទៅសិស្សរៀនយឺត

- សូមអនុវត្តការអានស្ទាត់ឱ្យបានច្រើន

- សម្ភារៈឧបទេសមិនទាន់គ្រប់គ្រាន់តាមមេរៀន

ដូចនេះ តាមរយៈការផ្តល់ទិន្នន័យទាក់ទងនឹងការអនុវត្តកម្មវិធីកញ្ចប់អំណានរបស់លោកគ្រូ អ្នកគ្រូនៅតាមសាលារៀនសំណាក ឃើញថាមានលក្ខណៈល្អប្រសើរច្រើន ហើយក៏នៅមានចំណុចខ្វះខាតខ្លះៗផងដែរ នៅតាមសាលាមួយចំនួន ប៉ុន្តែចំណុចខ្វះខាតទាំងអស់នោះសុទ្ធតែជាចំណុចដែលលោកគ្រូ អ្នកគ្រូអាចធ្វើ និងកែលម្អបាន ដើម្បីធ្វើឱ្យការបង្រៀនរបស់ពួកគាត់បានកាន់តែល្អប្រសើរ។




ក្រាបទី១៤៖ បង្ហាញពីរយៈពេលដែលបានអនុវត្តកម្មវិធីកញ្ចប់អំណាននៅសាលារៀនសំណាក

តាមរយៈក្រាបទី១៤ បង្ហាញថា សាលាដែលបានអនុវត្តកម្មវិធីកញ្ចប់អំណានរយៈពេល២ឆ្នាំ មានចំនួន៣សាលា ត្រូវជា ១៨.៧៥% និងសាលាដែលបានអនុវត្តរយៈពេល៣ឆ្នាំ មានចំនួន១៣សាលា ស្មើនឹង៨១.២៥%។ ដូចនេះបង្ហាញថា សាលាដែលបានអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងបានរយៈពេល៣ឆ្នាំ មានចំនួនច្រើនជាងសាលាដែលបានអនុវត្តមានរយៈពេល២ឆ្នាំ។ ប៉ុន្តែចំពោះសាលាដែលអនុវត្តបាន២ឆ្នាំ មានន័យថាសាលារបស់គាត់ក៏បានអនុវត្តដល់កម្រិតថ្នាក់ទី២ហើយ។



### ក្រាបទី១៥៖ បង្ហាញពីការចូលរួមសិក្ខាសាលាកម្មវិធីកញ្ចប់អំណានរបស់នាយក/នាយិកា

តាមរយៈក្រាបទី១៥ បង្ហាញថា នាយក/នាយិកា នៃសាលាសំណាកទាំង១៦ សុទ្ធតែធ្លាប់បានចូលរួមសិក្ខាសាលាស្តីពីកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងទាំងអស់គ្នា គឺស្មើនឹង ១០០% ដែលការចូលរួមសិក្ខាសាលាឧបត្ថម្ភឡើងដោយគម្រោង EQUAL នៃអង្គការ Save the Children ដូចៗគ្នា។




### ក្រាបទី១៦៖ បង្ហាញពីថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់សាលារៀនសំណាកតាមទិន្នន័យរបស់នាយក/នាយិកា

តាមរយៈក្រាបទី១៦ បង្ហាញថាក្នុងចំណោមសាលាសំណាកទាំង១៦ដែលបានផ្តល់ទិន្នន័យដោយនាយក/នាយិកាសាលា គឺសាលាដែលមានថវិកាដំណើរការកម្មវិធីកញ្ចប់អំណាន មានចំនួន៨សាលា ស្មើនឹង៥០% ចំណែកសាលាដែលមិនមានថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណាន មានចំនួន៨សាលាផងដែរ ដែលស្មើនឹង៥០%ដូចគ្នា។ ចំពោះសាលាដែលមិនមានថវិកាសម្រាប់កម្មវិធីកញ្ចប់អំណានបានផ្តល់មូលហេតុថា ដោយសារតែសាលារបស់គាត់មិនបានគ្រោងថវិកាក្នុងផែនការប្រតិបត្តិរបស់សាលារៀន។ រីឯសាលាដែលមានថវិកាសម្រាប់គាំទ្រកម្មវិធីកញ្ចប់អំណាន ដោយសារសាលាបានគ្រោងថវិកាដំណើរការសាលារៀនមួយផ្នែកសម្រាប់អនុវត្តកម្មវិធីកញ្ចប់អំណាននេះ នៅសាលារៀន។

ជាមួយគ្នានេះដែរ អ្នកស្រាវជ្រាវក៏បានសាកសួរបន្ថែមចំពោះសាលាដែលបានគ្រោងថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណានបន្ថែមថា«តើថវិកាដែលបានគ្រោងមានប្រភពពីណា?» នាយក/នាយិកាបានប្រាប់ថា«ថវិកាបានមកពីការលៃលក ពីថវិកាដំណើរការសាលារៀននិងមួយផ្នែកទៀតជាថវិកាមូលនិធិ

កែលម្អគុណភាពអប់រំ( PB,EU,SIG)»។ សាលាដែលបានគ្រោងថវិកាសម្រាប់គាំទ្រកម្មវិធីកញ្ចប់អំណាននេះ ក៏បានលើកឡើងបន្ថែមផងដែរថា «ហេតុដែលមានគំនិតធ្វើការគ្រោងថវិកានេះឡើង គឺដោយសារកម្មវិធីនេះមានវិធីសាស្ត្រល្អៗ ក្នុងការបង្រៀនសិស្សឱ្យឆាប់ចេះអាន ចេះសរសេរ និងដើម្បីធ្វើការបំប៉នដល់គ្រូផ្សេងៗទៀតដែលមិនបានចូលរួមសិក្ខាសាលា ឱ្យគាត់ចេះពីវិធីសាស្ត្របង្រៀនកញ្ចប់អំណានបានទាំងអស់គ្នា»។ នេះគឺជាគំនិតដែលគួរឱ្យគោរព និងកោតសរសើរក្រៃលែង ក្នុងនាមជាគណៈគ្រប់គ្រងដែលមានបំណងចង់ឱ្យបុគ្គលិករបស់ខ្លួន មានចំណេះ មានជំនាញដូចគ្នា ក្នុងការផ្ទេរចំណេះដឹងទៅសិស្សដើម្បីកសាងបាននូវធនធានមនុស្សដ៏ល្អសម្រាប់ជាតិនាពេលអនាគត។




ក្រាបទី១៧៖ បង្ហាញពីការអនុវត្តតាមលំនាំវិធីបង្រៀននៃកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់លោកគ្រូ អ្នកគ្រូ តាមទិន្នន័យរបស់នាយក/នាយិកា

តាមរយៈក្រាបទី១៧ បង្ហាញថា លោកគ្រូ អ្នកគ្រូនៅសាលាសំណាកដែលបានអនុវត្តតាមលំនាំនៃការបង្រៀនកម្មវិធីកញ្ចប់អំណានមានចំនួន១៥សាលា ត្រូវជា៩៣.៧៥% សម្រាប់លោកគ្រូ អ្នកគ្រូ ដែលអនុវត្តបានខ្លះមានចំនួន ១សាលា ស្មើនឹង៦.២៥% និងលោកគ្រូ អ្នកគ្រូដែលមិនបានអនុវត្តសោះ គឺមិនមាននៅសាលាណាមួយឡើយ។ សម្រាប់ហេតុផល នៅសាលាដែលអនុវត្តបានខ្លះ បានលើកឡើងថាអាស្រ័យដោយកត្តាពេលវេលា។ ដូចនេះឃើញថា លោកគ្រូ អ្នកគ្រូ បង្រៀននៅថ្នាក់ទី២ទាំងអស់ នៃសាលាសំណាកសុទ្ធតែបានអនុវត្តតាមលំនាំនៃការបង្រៀនកម្មវិធីកញ្ចប់អំណានទាំងអស់គ្នា ដោយសារ

លោកគ្រូ អ្នកគ្រូទាំងនោះបានទទួលវគ្គបណ្តុះបណ្តាលពីគម្រោង ការអប់រំប្រកបដោយគុណភាព និងបរិយាបន្ន (EQUAL) នៃអង្គការ Save the Children។




## ក្រាបទី១៨៖ បង្ហាញគំនិតយល់ឃើញពីសារៈប្រយោជន៍ នៃកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង តាមទិន្នន័យរបស់នាយក/នាយិកា

តាមរយៈក្រាបទី១៨ ជាទស្សនៈយល់ឃើញរបស់នាយក/នាយិកាទាំង១៦សាលា ដែលបង្ហាញថា កម្មវិធីកញ្ចប់អំណានពិតជាមានសារៈសំខាន់ គឺស្មើនឹង ១០០%។ ចំពោះទស្សនៈយល់ឃើញ ដែលបង្ហាញថា កម្មវិធីកញ្ចប់អំណានមានសារៈប្រយោជន៍ នាយក/នាយិកានៃសាលាសំណាកទាំង១៦ បានផ្តល់ហេតុផលជារួមមកដូចខាងក្រោម៖

- បង្រៀនសិស្សឆាប់ចេះ ឆាប់យល់ ចេះអានប្រកបដោយគុណភាព ស្គាល់សូរ ចេះអានស្ទាត់ និងឆាប់យល់ន័យរបស់អត្ថបទ អាចឆ្លើយសំណួរបានត្រឹមត្រូវ
- ជាវិធីសាស្ត្រល្អព្រោះធ្វើអោយសិស្សចូលចិត្តរៀន គ្រូមានវិធីសាស្ត្រថ្មីៗ ហើយប្លែក សិស្សក៏ទទួលបានការបង្រៀនថ្មីៗប្លែកៗពីគ្រូ
- ធ្វើឱ្យគ្រូងាយស្រួលក្នុងការបង្រៀន សិស្សក៏ចូលចិត្តរៀន
- សកម្មភាពសិស្ស និងគ្រូមានការប្រាស្រ័យទាក់ទងគ្នាជាប់ជានិច្ច
- ធ្វើឱ្យកុមារមានបំណិនក្នុងការអាន សរសេរ គិតលេខបានយ៉ាងរហ័ស ហើយត្រឹមត្រូវ។




ក្រាបទី១៩៖ បង្ហាញពីលទ្ធផលសិក្សារបស់សិស្សជាប់ លើផ្នែកអំណាន តាមទិន្នន័យរបស់នាយក/នាយិកា

តាមរយៈក្រាបទី១៩ បង្ហាញពីលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី២ លើផ្នែកអំណាន នៃសាលាសំណាកទាំង១៦ គឺលទ្ធផលជាប់ពី៧០-៧៥% មានចំនួន ៦សាលា ស្មើនឹង ៣៧.៥% លទ្ធផលជាប់ពី៧៦-៨០% មានចំនួន ៤សាលា ស្មើនឹង២៥% លទ្ធផលជាប់ពី៨១-៨៥% មានចំនួន៤សាលា ស្មើនឹង២៥% លទ្ធផលជាប់ពី៨៦-៩០% មានចំនួន១សាលា ស្មើនឹង៦.២៥% និងលទ្ធផលជាប់ពី៩១-៩៥% មានចំនួន១សាលា ស្មើនឹង៦.២៥%។ ចំណែកលទ្ធផលជាប់ពី៩៦-១០០% គឺគ្មាន ស្មើនឹង០%។ តាមរយៈលទ្ធផលនេះបង្ហាញថា ការសិក្សារបស់សិស្សលើផ្នែកអំណាន ទទួលបានលទ្ធផលជាប់កម្រិតបង្គួរឡើងទៅ។

ជាការសាកសួរសំណួរបន្ថែម ចង់ដឹងថា« តើសាលារៀនរបស់លោក/លោកស្រី ធ្វើការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី២ លើផ្នែកអំណានយ៉ាងដូចម្តេច?»។ ជាការឆ្លើយតបសំណួរ នាយក/នាយិកានៃសាលាសំណាកទាំង១៦ បានផ្តល់ជាចម្លើយជារួមមកដូចខាងក្រោម៖

- ការធ្វើតេស្តប្រចាំសប្តាហ៍ និងរៀងរាល់ខែ

-ប្រឡងដោយមានគណៈកម្មការដាក់ពិន្ទុ(អានច្បាស់ៗ អានឮៗ អានមិនរំលង អានមិនស្ទួន អានយល់ន័យ ការស្គាល់ស្នូរ ការស្គាល់តួអក្សរ ការចេះវាក្យសព្ទ ការអានស្ទាត់ និងការអានយល់ន័យ)

- ដោយផ្អែកលើបំណិនភាសាខ្មែរទាំង៤




**ក្រាបទី២០៖ បង្ហាញពីការតែងកិច្ចបង្រៀនរបស់គ្រូ តាមទិន្នន័យរបស់នាយក/នាយិកា**

តាមរយៈក្រាបទី២០ បង្ហាញពីការយកចិត្តទុកដាក់របស់លោកគ្រូ អ្នកគ្រូ ក្នុងការត្រៀមសម្ភារៈមុនពេលបង្រៀន ក្នុងនោះមានការតែងកិច្ចបង្រៀនផងដែរ ដែលជាកាតព្វកិច្ចចាំបាច់ក្នុងនាមជាគ្រូបង្រៀន ដើម្បីឱ្យដំណើរការបង្រៀនប្រព្រឹត្តទៅត្រឹមត្រូវតាមលំនាំ ឬលំហូរសកម្មភាពនៃការបង្រៀនកញ្ចប់អំណាន និងជំហាន។ ជាមួយគ្នានេះដែរ តាមរយៈទិន្នន័យដែលផ្តល់ជូនដោយនាយក/នាយិកាសាលា ជាលទ្ធផលគឺក្នុងចំណោមសាលាសំណាកទាំង១៦ គ្រូបង្រៀនមានកិច្ចតែងការគ្រប់មេរៀនមានចំនួន១១សាលា ស្មើនឹង៦៨.៧៥% មានខ្លះ(មិនគ្រប់មេរៀន) មានចំនួន៥សាលា ស្មើនឹង៣១.២៥% និងគ្មានកិច្ចតែងការសោះគឺគ្មាន ស្មើនឹង0%។ ដូចនេះបង្ហាញថា គ្រូបង្រៀនទាំងអស់សុទ្ធតែមានកិច្ចតែងការបង្រៀន គ្រាន់តែមានសាលាខ្លះ គ្រូបានតែងមិនគ្រប់មេរៀន ។ សម្រាប់សាលាដែលមានគ្រូតែងកិច្ចមិនគ្រប់មេរៀន បានលើកហេតុផលបញ្ជាក់ប្រាប់ថា ដោយសារតែសាលាខ្លះមាននាយកជាអ្នកបង្រៀនដែររវល់ការងារច្រើន គ្មានពេលវេលាគ្រប់គ្រាន់ក្នុងការតែងកិច្ច និងសាលាខ្លះថាគ្រូ មិនសូវយល់ច្បាស់ពីរបៀបតែងកិច្ចតាមបែបកញ្ចប់អំណាន ដោយសារវាជាកម្មវិធីថ្មីសម្រាប់ពួកគាត់។




ក្រាបទី២១៖ បង្ហាញពីការប្រជុំក្រុមបច្ចេកទេសនៅតាមសាលានីមួយៗ តាមទិន្នន័យរបស់នាយក/នាយិកា

តាមរយៈក្រាបទី២១ បង្ហាញថា គ្រប់សាលាសំណាកទាំង១៦ សុទ្ធតែបានប្រជុំក្រុមបច្ចេកទេសទាំងអស់ គឺបើគិតជាភាគរយស្មើនឹង១០០%។ នេះបង្ហាញពីការយកចិត្តទុកដាក់ក្នុងការងារបច្ចេកទេសរបស់លោកគ្រូ អ្នកគ្រូ ដើម្បីផ្លាស់ប្តូរបទពិសោធ និងបច្ចេកទេសគ្នាទៅវិញទៅមក ដើម្បីឱ្យការបង្រៀនទទួលបានលទ្ធផលល្អ ធ្វើឱ្យសិស្សចេះ និងជាប់បានច្រើន។

**ផ្នែកទី៣៖ សំណូមពរ និងចំណាប់អារម្មណ៍របស់នាយក/នាយិកាសាលា ចំពោះកម្មវិធីកញ្ចប់អំណានដំបូង៖**

- សូមឱ្យមានវគ្គបំប៉ន និងជួយបណ្តុះបណ្តាលបន្ថែមទៀតពីកញ្ចប់អំណាន និងរំឭកឡើងវិញកញ្ចប់អំណានថ្នាក់ទី២ និងសូមឱ្យមានសម្រាប់ថ្នាក់ទី៣បន្តទៀត

- សូមឲ្យមានសិក្ខាសាលាបន្ថែម បណ្តុះបណ្តាលវិធីសាស្រ្ត និងឧបត្ថម្ភគាំទ្រធនធានក្នុងការផលិតសម្ភារៈឧបទេស បង្រៀន និងរៀនបន្ថែមទៀត

- សំណូមពរឲ្យខាងអង្គការ និងក្រសួងមានបើកសិក្ខាសាលាបន្តទៀត ដើម្បីបំប៉នពីកម្មវិធីកញ្ចប់អំណានដល់លោកគ្រូ អ្នកគ្រូផ្សេងៗទៀត ដែលមិនទាន់បានទទួលការបណ្តុះបណ្តាល

- សូមបន្តជួយតាមដាន និងសម្របសម្រួលក្នុងការបង្រៀនកញ្ចប់អំណានដល់លោកគ្រូ អ្នកគ្រូបន្ថែមទៀត

- សូមចងក្រងសៀវភៅជំនួយនៅថ្នាក់បន្តបន្ទាប់ទៀត

- សូមបន្តជួយសៀវភៅជំនួយសិស្សឱ្យបានគ្រប់គ្នា។

## ៤.៣.៤. ការវិភាគទិន្នន័យលើកម្រងសំណួរប្រធានក្រុមបច្ចេកទេស

### ផ្នែកទី១៖ ព័ត៌មានទូទៅ




ក្រាបទី២២៖ បង្ហាញពីភេទរបស់ប្រធានក្រុមបច្ចេកទេសសាលាសំណាកទាំង២០ តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស

តាមរយៈក្រាបទី២២បង្ហាញថា ប្រធានក្រុមបច្ចេកទេសសាលាសំណាកទាំង២០ ដែលបានជួយបំពេញកម្រងសំណួរទាំងអស់មានចំនួន ២០រូប គឺគ្រប់ចំនួនតាមការគ្រោងទុក។ ទាក់ទងទៅនឹងភេទប្រធានក្រុមដែលមានភេទប្រុស មានចំនួន១០នាក់ ស្មើនឹង៥០% ចំណែកប្រធានក្រុមបច្ចេកទេសភេទស្រីមានចំនួន១០នាក់ ស្មើនឹង៥០% ដូចគ្នា។ ដូចនេះតាមរយៈរូបភាពខាងលើ យើងឃើញថា មានសមភាពយេនឌ័រល្អណាស់ គឺចំនួនប្រុស និងស្រីស្មើគ្នា។

តារាងទី១០៖ បង្ហាញពីអាយុរបស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស

| ល.រ | កម្រិតអាយុ | ប្រុស | ភាគរយ | ស្រី | ភាគរយ | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|
| ១ | 20-25 | 0 | 0% | 2 | 10% | 2 | **10%** |
| ២ | 26-30 | 2 | 10% | 1 | 5% | 3 | **15%** |
| ៣ | 31-35 | 2 | 10% | 3 | 15% | 5 | **25%** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | 36-40 | 2 | 10% | 2 | 10% | 4 | **20%** |
| ៥ | 41-45 | 3 | 15% | 1 | 5% | 4 | **20%** |
| ៦ | 46-50 | 0 | 0% | 0 | 0% | 0 | **0%** |
| ៧ | 51-55 | 1 | 5% | 1 | 5% | 2 | **10%** |
| ៨ | លើសពី55 | 0 | 0% | 0 | 0% | 0 | **0%** |
| **សរុប** | | **10** | **50%** | **10** | **50%** | **20** | **100%** |

តាមរយៈតារាងទី១០ បង្ហាញថា ក្នុងចំណោមអាយុប្រធានក្រុមបច្ចេកទេសទាំង២០នាក់ ដែលបានបំពេញកម្រងសំណួរ មានកម្រិតអាយុផ្សេងៗគ្នា។ ប្រធានក្រុមបច្ចេកទេសដែលមានអាយុចន្លោះពី ២០ទៅ២៥ឆ្នាំ មានចំនួន២នាក់ គឺប្រុសគ្មាន ស្មើនឹង០% ស្រី២នាក់ ស្មើនឹង១០%។ អាយុចន្លោះពី២៦ ទៅ៣០ឆ្នាំ មានចំនួន៣នាក់ ប្រុស២នាក់ ត្រូវជា១០% និងស្រី១នាក់ ត្រូវជា៥% ជារួមស្មើនឹង ១៥%។ ចន្លោះអាយុចាប់ពី៣១-៣៥ មានចំនួន៥នាក់ ប្រុស២នាក់ ត្រូវជា១០% និងស្រី៣នាក់ ស្មើនឹង១៥% ជារួមត្រូវជា២៥%។ ចំពោះអ្នកមានចន្លោះអាយុ ៣៦-៤០ មានចំនួន ៤នាក់ ប្រុស២នាក់ ស្មើនឹង១០% និងស្រី២នាក់ស្មើនឹង១០%ដែរ ជារួមត្រូវជា២០%។ ចំណែកអ្នកមានអាយុចន្លោះពី៤១-៤៥ឆ្នាំ មានចំនួន៤នាក់ ក្នុងនោះប្រុសមានចំនួន៣នាក់ ស្មើនឹង១៥% និងស្រីមានចំនួន១នាក់ ស្មើនឹង៥% ជារួមត្រូវជា២០%។ រីឯចន្លោះអាយុពី៤៦-៥០ឆ្នាំ គឺគ្មាន ស្មើនឹង០% ហើយចន្លោះអាយុពី៥១-៥៥ឆ្នាំ មានចំនួន ២នាក់ គឺប្រុស១នាក់ ស្មើនឹង៥% និងស្រី១នាក់ ស្មើនឹង៥%ដែរ ជារួមស្មើនឹង១០%។ ដោយឡែក អ្នកដែលមានអាយុលើសពី៥៥ ឆ្នាំគឺគ្មាន ស្មើនឹង០%។ ដូចនេះ តាមរយៈតារាងខាងលើ អាចនិយាយបានថា ប្រធានក្រុមបច្ចេកទេសភាគច្រើនយុវជន យុវនារី ជាបុគ្គលពេញកម្លាំង ដែលមានអាយុចន្លោះពី២០ ទៅ៤៥ឆ្នាំ មានរហូតដល់ទៅ១៨នាក់ទៅហើយ ក្នុងចំណោម២០នាក់ គឺមានន័យថា ជាវ័យដែលមានសក្តានុពលល្អសម្រាប់ចូលរួមធ្វើការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអប់រំ។

**តារាងទី១១៖ បង្ហាញពីកម្រិតវប្បធម៌របស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស**

| ល.រ | កម្រិតវប្បធម៌ | ប្រុស | ភាគរយ | ស្រី | ភាគរយ | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|
| ១ | ស.បរិញ្ញាបត្រ | 1 | 5% | 3 | 15% | 4 | **20%** |
| ២ | ស.មធ្យមសិក្សាទុតិយភូមិ | 9 | 45% | 6 | 30% | 15 | **75%** |
| ៣ | ស.ក្រោមបាក់ឌុប | 0 | 0% | 1 | 5% | 1 | **5%** |
| **សរុប** | | **10** | **50%** | **10** | **50%** | **20** | **100%** |

យោងតាមតារាងទី១១បង្ហាញថា ក្នុងចំណោមប្រធានក្រុមបច្ចេកទេសទាំង២០រូប ដែលបានបំពេញកម្រងសំណួរទាំងអស់ ខ្ញុំបាទបានបែងចែកជា៣កម្រិតផ្សេងៗគ្នា។ ប្រធានក្រុមបច្ចេកទេសដែលមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រមានភេទប្រុស០១នាក់ ត្រូវជា៥% និងស្រី០៣នាក់ ស្មើនឹង ១៥% ជារួមស្មើនឹង២០%។ ចំណែកឯ អ្នកមានកម្រិតវប្បធម៌ជាប់មធ្យមសិក្សាទុតិយភូមិ(បាក់ឌុប) ប្រុសមានចំនួន ០៩នាក់ ស្មើនឹង៤៥% និងស្រីមានចំនួន០៦នាក់ ស្មើ៣០% និងសញ្ញាបត្រក្រោមបាក់ឌុប មានចំនួន០១នាក់ ស្រី០១នាក់ ស្មើនឹង៥%។ ដូចនេះ យើងឃើញថា ប្រធានក្រុមបច្ចេកទេសភាគច្រើន មានកម្រិតសញ្ញាបត្រជាប់មធ្យមសិក្សាទុតិយភូមិ ដែលមានចំនួនច្រើនជាងគេ។

**តារាងទី១២៖ បង្ហាញពីកម្រិតវិជ្ជាជីវៈរបស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស**

| ល.រ | កម្រិតវិជ្ជាជីវៈ | ប្រុស | ភាគរយ | ស្រី | ភាគរយ | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|
| ១ | គ្រូកម្រិតឧត្តម | ០០នាក់ | ០% | ០០នាក់ | ០% | ០% | ០% |
| ២ | គ្រូកម្រិតមូលដ្ឋាន | ០១នាក់ | ៥% | ០១នាក់ | ៥% | ០២នាក់ | ១០% |
| ៣ | គ្រូបឋមសិក្សា | ០៩នាក់ | ៤៥% | ០៩នាក់ | ៤៥% | ១៨នាក់ | ៩០% |

| សរុប | ១០នាក់ | ៥០% | ១០នាក់ | ៥០% | ២០នាក់ | ១០០% |
|---|---|---|---|---|---|---|

យោងតាមរយៈតារាងទី១២ បង្ហាញថាប្រធានក្រុមបច្ចេកទេសដែលមានកម្រិតវិជ្ជាជីវៈជាគ្រូកម្រិតឧត្តមគឺគ្មាន ស្មើនឹង ០%។ ចំពោះប្រធានក្រុមបច្ចេកទេសដែលមានកម្រិតវិជ្ជាជីវៈជាគ្រូបង្រៀនកម្រិតមូលដ្ឋានភេទប្រុស មានចំនួន ០១នាក់ ត្រូវជា ៥% ភេទស្រីមានចំនួន ០១នាក់ ត្រូវជា ៥%ដែរ ជារួមមានចំនួន ០២នាក់ ត្រូវជា ១០%។ ចំពោះប្រធានក្រុមបច្ចេកទេសដែលមានកម្រិតវិជ្ជាជីវៈជាគ្រូបង្រៀនកម្រិតបឋមសិក្សា ភេទប្រុសមានចំនួន ០៩នាក់ ស្មើនឹង ៤៥% ភេទស្រី ០៩នាក់ ស្មើនឹង ៤៥% ដូចគ្នា។ ដូចនេះឃើញថាប្រធានក្រុមបច្ចេកទេសទាំង២០រូប មានកម្រិតវិជ្ជាជីវៈតែពីរកម្រិតប៉ុណ្ណោះ គឺជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងជាគ្រូបង្រៀនកម្រិតបឋម ហើយចំនួននៃភាគរយក៏ស្មើគ្នាទៀត ទាំងភាគរយប្រុស ស្រី ទាំងភាគរយនៃកម្រិតវិជ្ជាជីវៈ។

**តារាងទី១៣៖ បង្ហាញពីរយៈពេលបំពេញការងារក្នុងវិស័យអប់រំ របស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស**

| ល.រ | រយៈពេលបំពេញការងារ | ប្រុស | ស្រី | សរុប | ភាគរយ |
|---|---|---|---|---|---|
| ១ | ០១-០៥ឆ្នាំ | ០១នាក់ | ០២នាក់ | ០៣នាក់ | 15% |
| ២ | ០៦-១០ឆ្នាំ | ០៣នាក់ | ០១នាក់ | ០៤នាក់ | 20% |
| ៣ | ១១-១៥ឆ្នាំ | ០១នាក់ | ០៤នាក់ | ០៥នាក់ | 25% |
| ៤ | ១៦-២០ឆ្នាំ | ០២នាក់ | ០១នាក់ | ០៣នាក់ | 15% |
| ៥ | ២១-២៥ឆ្នាំ | ០២នាក់ | ០១នាក់ | ០៣នាក់ | 15% |
| ៦ | ២៦-៣០ឆ្នាំ | ០០នាក់ | ០០នាក់ | ០០នាក់ | 0% |
| ៧ | លើស៣០ឆ្នាំ | ០១នាក់ | ០១នាក់ | ០២នាក់ | 10% |
| សរុប | | ១០នាក់ | ១០នាក់ | ២០នាក់ | 100% |

តាមរយៈតារាងទី១៣ បង្ហាញថា ប្រធានក្រុមបច្ចេកទេសទាំង២០រូប មានរយៈពេលក្នុងការបំពេញការងារក្នុងវិស័យអប់រំផ្សេងៗគ្នា គឺបើគិតចន្លោះពី០១-០៥ឆ្នាំ មានចំនួនសរុប០៣នាក់ ស្រី០២នាក់ ស្មើនឹង១៥%។ ចន្លោះពី០៦-១០ឆ្នាំ មានចំនួនសរុប០៤នាក់ ស្រី០១នាក់ ត្រូវជា ២០%។ ចំណែកចន្លោះពី១១-១៥ឆ្នាំ មានចំនួន០៥នាក់ ស្រី ០៤នាក់ គិតជាភាគរយស្មើនឹង ២៥%។ ចំពោះរយៈពេលចន្លោះពី១៦-២០ឆ្នាំ មានចំនួន០៣នាក់ ស្រី ០១នាក់ គិតជាភាគរយ ១៥% ហើយរយៈពេលពី២១-២៥ឆ្នាំ មានចំនួន០៣នាក់ ស្រី០១នាក់ គិតជាភាគរយស្មើនឹង ១៥%។ រីឯរយៈពេលពី២៦-៣០ គឺគ្មាន គិតជាភាគរយគឺ ០% និងអ្នកដែលមានអតីតភាពការងារលើសពី៣០ឆ្នាំ មានចំនួន ០២នាក់ ស្រី ០១នាក់ គិតជាភាគរយស្មើនឹង ១០%។ ដូចនេះតាមរយៈការពិនិត្យលើអតីតភាពការងាររបស់ប្រធានក្រុមបច្ចេកទេសទាំង២០រូប ឃើញថាអ្នកដែលមានអតីតភាពការងារចន្លោះពី១១-១៥ឆ្នាំ មានចំនួនច្រើនជាងគេ មានន័យថាគឺជារយៈពេល ដែលស្ថិតក្នុងកម្រិតមធ្យមនៅក្នុងការបំពេញក្របខណ្ឌ នៃវិស័យអប់រំ។ ចំណែកឯអ្នកដែលមានអតីតភាពការងារលើសពី៣០ឆ្នាំ គឺមានចំនួន ០២នាក់ ក្នុងនោះស្រី ០១នាក់ ជារយៈពេលមួយដ៏វែង ដែលពួកគាត់បានចំណាយពេលវេលាក្នុងការជួយអភិវឌ្ឍនូវវិស័យអប់រំរបស់យើង ហើយបើតាមរយៈពេលនេះគឺគាត់អាចដាក់ពាក្យចូលនិវត្តន៍មុនអាយុកាលចូលនិវត្តន៍បាន។

### តារាងទី១៤៖ បង្ហាញពីរយៈពេលបំពេញតួនាទីជាប្រធានក្រុមបច្ចេកទេស

| ល.រ | រយៈពេលបំពេញតួនាទី | ប្រុស | ស្រី | សរុប | ភាគរយ |
|---|---|---|---|---|---|
| ១ | ១-៥ឆ្នាំ | ០៧នាក់ | ០៦នាក់ | ១៣នាក់ | ៦៥% |
| ២ | ៦-១០ឆ្នាំ | ០២នាក់ | ០២នាក់ | ០៤នាក់ | ២០% |
| ៣ | ១១-១៥ឆ្នាំ | ០០នាក់ | ០០នាក់ | ០០នាក់ | ០% |
| ៤ | ១៦-២០ឆ្នាំ | ០១នាក់ | ០០នាក់ | ០១នាក់ | ៥% |
| ៥ | លើស២០ឆ្នាំ | ០០នាក់ | ០២នាក់ | ០២នាក់ | ១០% |

| សរុប | ១០នាក់ | ១០នាក់ | ២០នាក់ | 100% |
|---|---|---|---|---|

តាមរយៈតារាងទី១៤ បង្ហាញថាប្រធានក្រុមបច្ចេកទេសទាំង២០រូប មានបទពិសោធជាប្រធានក្រុម មានរយៈពេលខុសៗគ្នា ទៅតាមអតីតភាពការងារ ឬស្ថានភាពនៃសាលារៀនរបស់ខ្លួន ក្នុងនោះដែរ អ្នកដែលមានរយៈពេលក្នុងការបំពេញតួនាទីពី០១-០៥ឆ្នាំ មានចំនួនច្រើនជាងគេ គឺមានចំនួន១៣នាក់ ស្រី០៦នាក់ ស្មើនឹង ៦៥% ហើយរយៈពេលពី០៦-១០ឆ្នាំ មានចំនួន០៤នាក់ ស្រី២ ស្មើនឹង២០%។ រយៈពេលពី១១-១៥ឆ្នាំ គ្មាន ស្មើនឹង0% និងពី១៦-២០ឆ្នាំ មានចំនួន០១នាក់ ស្រី0 ស្មើនឹង៥%។ ចំពោះអ្នកដែលបានកាន់ការងារជាប្រធានក្រុមបច្ចេកទេសមានរយៈពេលលើសពី២០ឆ្នាំ មានចំនួន ០២ នាក់ ស្រី០២នាក់ គិតជាភាគរយ ស្មើនឹង១០%។

## ផ្នែកទី២៖ ការងារបង្រៀន និងរៀន




ក្រាបទី២៣៖ បង្ហាញពីការចុះធ្វើអធិការកិច្ចថ្នាក់រៀនរបស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស

តាមរយៈក្រាបទី២៣ បង្ហាញឱ្យឃើញពីសកម្មភាពនៃការចុះអធិការកិច្ចថ្នាក់រៀនរបស់ប្រធានក្រុមបច្ចេកទេស។ ក្នុងចំណោមប្រធានក្រុមបច្ចេកទេស២០នាក់ ដែលតំណាងឱ្យសាលាសំណាកទាំង ២០ មានចំនួន១៦នាក់ បានអនុវត្ត ស្មើនឹង៨០% និងមានចំនួន៤នាក់ មិនបានអនុវត្ត ស្មើនឹង២០%។ ចំពោះអ្នកមិនបានចុះធ្វើអធិការកិច្ចថ្នាក់រៀន បានផ្តល់មូលហេតុថា ដោយសារពួកគាត់ទើបតែទទួលបាន

តួនាទីជាប្រធានក្រុមបច្ចេកទេស ដូច្នេះពួកគាត់មិនទាន់យល់ច្បាស់ពីការងារចុះអធិការកិច្ចថ្នាក់រៀននៅឡើយ និងបញ្ហាធំចម្បងគឺជំងឺកូវីដ-១៩។

ជាការសួរសំណួរបន្ថែមចំពោះអ្នកបានចុះអធិការកិច្ចថ្នាក់រៀន ថាតើបានឃើញពីចំណុចល្អ និងចំណុចគួរកែលម្អអ្វីខ្លះ របស់លោកគ្រូអ្នកគ្រូក្នុងការបង្រៀនរបស់ពួកគាត់ ជាលទ្ធផលទទួលបានទិន្នន័យដូចខាងក្រោម៖

### ក. ចំណុចល្អ៖

- មានកិច្ចតែងការបង្រៀន
- បង្រៀនតាមលំនាំនៃកិច្ចតែងការបានត្រឹមត្រូវ និងគ្រប់សកម្មភាព
- មានការវាយតម្លៃសិស្សនៅជំហាន៤
- មានការលើទឹកចិត្តសិស្ស
- ផ្ដោតលើសិស្សរៀនយឺត
- មានកិច្ចតែងបង្រៀន មានសម្ភារៈគ្រប់គ្រាន់និងបង្រៀនបានគ្រប់ជំហានទាំងប្រាំ
- មានរបៀបរៀបរយល្អក្នុងការបង្រៀន
- ការបង្រៀនរៀនសិស្សបានល្អសិស្សមានការចូលរួមច្រើន
- គ្រូមានសំឡេងច្បាស់ល្អ
- ចេះលើកទឹកចិត្តសិស្ស យកចិត្តទុកដាក់ចំពោះសិស្សរៀនយឺត ចេះរើសយកល្បែងសិក្សាមកលេង ដើម្បីកុំឱ្យសិស្សមានអារម្មណ៍ធុញថប់ក្នុងការសិស្សា
- បង្រៀនសិស្សទទួលបានលទ្ធផលល្អបង្គួរ ថ្នាក់រៀនមានសកម្មភាពរស់រវើក សិស្សមានភាពក្លាហាន លទ្ធផលទទួលបានសម្រេចតាមវត្ថុបំណង៧៥%

### ខ. ចំណុចគួរកែលម្អ៖

- មិនទាន់មានសម្ភារៈគ្រប់គ្រាន់

- ពេលខ្លះបង្រៀនមិនទាន់ពេល តាមចំណុចនីមួយៗ

- ពេលបង្រៀនមិនបានមើលម៉ោង(លើសម៉ោង ដល់ម៉ោងមិនទាន់គ្រប់សកម្មភាព)

- ពេលសិស្សអានគួរឱ្យសិស្សយកម្រាមដៃចង្អុលតាម

- សម្ភារៈបង្រៀន និងរៀនពុំសូវសម្បូរបែប

- គួរកសាងវិញ្ញាសាតេស្តឲ្យបានគ្រប់ខែ

- កិច្ចតែងការមិនបានគ្រប់មេរៀន

- ការងាររដ្ឋបាលនៅខ្វះខាត

- ការគ្រប់គ្រងសិស្សនៅមានកម្រិត

- រូបភាពគួរពង្រីកឲ្យបានធំ ឲ្យសិស្សធ្វើសកម្មភាពឱ្យបានគ្រប់គ្នា និយាយឲ្យច្បាស់ ការងារក្រុមគួរឲ្យសិស្សឡើងរាយការណ៍លើក្ដារខៀន

- គួរផ្ទៀងផ្ទាត់ពេលសិស្សសរសេររួច

- ឱ្យសិស្សអនុវត្តការអានជាបុគ្គលនៅមានកម្រិត (បានតិចពេក)។

- ពុំសូវចាំសកម្មភាពបង្រៀន

- គួរយកល្បែងសិក្សាមកលេងនៅពេលសិស្សមានអារម្មណ៍ធុញថប់ក្នុងការសិក្សា គួរឲ្យសិស្សអានបន្ទាក់គ្នាឲ្យបានច្រើន និងធ្វើអក្ខរវិញ្ញាស(ការញែកព្យាង្គ)ឲ្យបានច្រើន ។

- សំឡេងមិនសូវឮ និងមិនសូវហៅសិស្សរៀនយឺត

ដូចនេះតាមការបង្ហាញខាងលើឃើញថា ចំណុចល្អ និងចំណុចគួរកែលម្អគឺ នៅលាយឡំគ្នាដោយសារភាពប៉ិនប្រសប់ក្នុងការអនុវត្តរបស់គ្រូនៅតាមសាលាផ្សេងៗគ្នា។




**ក្រាបទី២៤៖ បង្ហាញពីការតែងកិច្ចរបស់គ្រូនៅតាមសាលាសំណាកទាំង២០ តាមការផ្តល់ទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស**

តាមរយៈក្រាបទី២៤ បង្ហាញពីការតែងកិច្ចបង្រៀនរបស់គ្រូថ្នាក់ទី២ នៅសាលាសំណាកទាំង២០ ដែលមើលឃើញថា មានសាលាចំនួន១១ មានកិច្ចតែងការគ្រប់មេរៀន ស្មើនឹង៥៥% ចំណែក៩សាលាទៀតមានខ្លះ(មិនគ្រប់មេរៀន)ស្មើនឹង៤៥%។ ចំពោះការសួរសំណួរបន្ថែមថា ហេតុអ្វីបានជាមិនមានកិច្ចតែងការគ្រប់មេរៀន ពួកគាត់បានបញ្ជាក់ហេតុផលខ្លះៗដូចខាងក្រោម៖

- ពេលខ្លី ត្រូវបង្រៀនពីពេល ខ្លះទៀតមានតួនាទីជានាយក
- ដោយសារគ្រូបន្ទុកថ្នាក់មានការផ្លាស់ប្តូរកម្រិតថ្នាក់រៀនគ្នា កម្មវិធីថ្មី
- កិច្ចតែងការចាស់ៗត្រូវបានផ្លាស់ប្តូរ កិច្ចតែងការថ្មីកំពុងរៀបចំ ជាបណ្តើរៗ
- ដោយសារមិនបានបង្រៀន(កូវីដ-១៩)មិនបានតែងបន្ត។

ដូចនេះ ទោះបីជាយ៉ាងណាក៏នៅតែឃើញថា សាលាដែលបានអនុវត្តការតែងកិច្ចបង្រៀន ហើយបានគ្រប់មេរៀន គឺមានចំនួនច្រើនជាងសាលាដែលអនុវត្តការតែងកិច្ចបង្រៀនដែរ តែមិនគ្រប់មេរៀន។




**ក្រាបទី២៥៖ បង្ហាញពីការប្រជុំក្រុមបច្ចេកទេសនៅតាមសាលានីមួយៗ តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស**

យោងតាមក្រាបទី២៥ បង្ហាញថា គ្រប់សាលាសំណាកទាំង២០ ដែលបានផ្តល់ទិន្នន័យ សុទ្ធតែបានប្រជុំក្រុមបច្ចេកទេសគ្រប់សាលាទាំងអស់ គឺស្មើនឹង១០០%។ ជាការសាកសួរសំណួរបន្ថែម «ថាតើការប្រជុំក្រុមបច្ចេកទេសនៅតាមសាលាកន្លងទៅ បានលើកយកប្រធានបទអ្វីខ្លះមកធ្វើការប្រជុំពិភាក្សាគ្នា?» ជាលទ្ធផលលោកគ្រូ អ្នកគ្រូជាប្រធានក្រុមបច្ចេកទេស បានបង្ហាញដូចខាងក្រោម៖

- វិធីសាស្ត្របង្រៀនអំណាន សរសេរ និងគណិតវិទ្យា
- ប្រជុំធ្វើវិញ្ញាសាឆមាសលើកទី១
- ធ្វើថ្នាក់និទ្ទស្សន៍និងផ្សព្វផ្សាយព័ត៌មានផ្សេងៗរបស់ប្រធានកម្រង
- សរុបលទ្ធផលប្រចាំខែនិងធ្វើផែនការបន្ត
- ពង្រឹងលើលំនាំបង្រៀន និងផលិតសម្ភារៈ
- វិធីសាស្ត្របង្រៀន (បង្រៀនពាក្យប្រកប)
- ផលិតសម្ភារៈបង្រៀនតាមកម្រិតថ្នាក់
- វិធីសាស្ត្រជួយសិស្សរៀនយឺត
- វិធីសាស្ត្របង្រៀនក្នុងបរិបទកូវីដ-១៩
- បង្ហាញពីបញ្ហាប្រឈមនៃការរៀន និងបង្រៀនរបស់គ្រូ-សិស្ស

- បញ្ហាសិស្សខ្សោយអំណាននិងការផលិតសម្ភារឧបទេសសម្រាប់ជួយសិស្សខ្សោយ
- ការអនុវត្តកញ្ចប់អំណាន (ចំណុចល្អៗ បញ្ហាប្រឈម ដំណោះស្រាយ)។




**ក្រាបទី២៦៖ បង្ហាញពីរយៈពេលនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងនៅសាលាសំណាកទាំង២០ តាមការផ្តល់ទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស**

តាមរយៈក្រាបទី២៦ បង្ហាញថា សាលាដែលបានអនុវត្តកម្មវិធីកញ្ចប់អំណានរយៈពេល២ឆ្នាំ មានចំនួន៤សាលា ត្រូវជា ២០% និងសាលាដែលបានអនុវត្តរយៈពេល៣ឆ្នាំ មានចំនួន១៦សាលា ស្មើនឹង៨០%។ ដូចនេះបង្ហាញថា សាលាដែលបានអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងបានរយៈពេល៣ឆ្នាំ មានចំនួនច្រើនជាងសាលាដែលបានអនុវត្តមានរយៈពេល២ឆ្នាំ។ ប៉ុន្តែចំពោះសាលាដែលអនុវត្តបាន២ឆ្នាំ មានន័យថាសាលារបស់គាត់ក៏បានអនុវត្តដល់កម្រិតថ្នាក់ទី២ហើយ។



## ក្រាបទី២៧៖ បង្ហាញពីការចូលរួមសិក្ខាសាលាកម្មវិធីកញ្ចប់អំណានរបស់ប្រធានក្រុមបច្ចេកទេស តាមការផ្តល់ទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស

តាមរយៈក្រាបទី២៧ បង្ហាញថា ក្នុងចំណោមប្រធានក្រុមបច្ចេកទេស នៃសាលាសំណាកទាំង ២០ គឺធ្លាប់បានចូលរួមកម្មវិធីសិក្ខាសាលាចំនួន១៧នាក់ ស្មើនឹង១៧សាលា គិតជាភាគរយស្មើនឹង ៨៥% និងមិនធ្លាប់បានចូលរួមសិក្ខាសាលាចំនួន៣នាក់ ស្មើនឹង៣សាលា គិតជាភាគរយស្មើនឹង១៥% តាមរយៈការសាកសួរសំណួរបន្ថែមចំពោះអ្នកមិនធ្លាប់បានចូលរួមសិក្ខាសាលា ពួកគាត់បានប្រាប់ពីហេតុផលថាដោយសារកម្មវិធីកញ្ចប់អំណានមានសម្រាប់តែថ្នាក់ទី១ ទី២ និងទី៣តែពួកគាត់ជាគ្រូបន្ទុកថ្នាក់កម្រិតផ្សេងពីនេះ។

ដូចនេះយើងមើលឃើញថា ប្រធានក្រុមបច្ចេកទេសភាគច្រើនបានចូលរួមសិក្ខាសាលាស្ទើរតែទាំងអស់គ្នា មានន័យថាពួកគាត់ សុទ្ធតែបង្រៀននៅថ្នាក់ទី២ផងដែរ។




## ក្រាបទី២៨៖ បង្ហាញពីថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់សាលារៀនសំណាកទាំង២០ តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស

តាមរយៈក្រាបទី២៨ បង្ហាញថាក្នុងចំណោមសាលាសំណាកទាំង២០ ដែលបានផ្តល់ទិន្នន័យដោយប្រធានក្រុមបច្ចេកទេស គឺសាលាដែលមានថវិកាដំណើរការកម្មវិធីកញ្ចប់អំណាន មានចំនួន១២សាលា ស្មើនឹង៦០% ចំណែកសាលាដែលមិនមានថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណាន មាន

ចំនួន៨សាលា ដែលស្មើនឹង៤០%។ ចំពោះសាលាដែលមិនមានថវិកាសម្រាប់កម្មវិធីកញ្ចប់អំណាន បានផ្តល់មូលហេតុថា ដោយសារតែសាលារបស់គាត់មិនបានគ្រោងថវិកាក្នុងផែនការប្រតិបត្តិរបស់សាលារៀន។ រីឯសាលាដែលមានថវិកាសម្រាប់គាំទ្រកម្មវិធីកញ្ចប់អំណាន ដោយសារសាលាបានគ្រោងថវិកាដំណើរការសាលារៀនមួយផ្នែក សម្រាប់អនុវត្តកម្មវិធីកញ្ចប់អំណាននេះនៅសាលារៀន។

ក្នុងនោះដែរ អ្នកសិក្សាស្រាវជ្រាវ ក៏បានសួរសំណួរបន្ថែមចំពោះសាលាដែលមានថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណានថា «ហេតុអ្វីបានដឹងថា មានថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណាន?» ពួកគាត់បានប្រាប់ហេតុផលដូចខាងក្រោម៖

- មានការជួយឧបត្ថម្ភពីគម្រោង EQUAL នៃអង្គការ Save the Children មួយផ្នែកធំ
- ព្រោះទទួលបានការផ្សព្វផ្សាយពីនាយក/ នាយករងនៅក្នុងសាលា
- បានធ្វើផែនការ និងអនុវត្តគម្រោង
- ចូលរួមប្រជុំធ្វើផែនការអភិវឌ្ឍ

ជាមួយគ្នានេះដែរ ខ្ញុំបាទក៏បានសួរសំណួរបន្ថែមចំពោះសាលាដែលថាគ្មានថវិកាសម្រាប់ ដំណើរការកម្មវិធីកញ្ចប់អំណានថា «តើកម្មវិធីកញ្ចប់អំណាននៅសាលារៀនរបស់លោក លោកស្រីដែលបានដំណើរទៅនោះបានថវិកាពីណា?»។ ពួកគាត់បានឆ្លើយថា បានមកពីការជួយឧបត្ថម្ភរបស់គម្រោង EQUAL នៃអង្គការ Save the Children។

ដូចនេះតាមការផ្តល់ទិន្នន័យ ក៏ដូចជាការសាកសួរបន្ថែម បានបង្ហាញឱ្យឃើញថាសាលាសំណាកទាំង២០ អាចដំណើរការកម្មវិធីកញ្ចប់អំណានទៅបាន អាស្រ័យដោយកត្តាពីរគឺ ទី១សាលាខ្លះចេះលៃលកថវិកាដំណើរការសាលារៀន ផ្សំជាមួយនឹងការជួយឧបត្ថម្ភពីគម្រោង និងសាលាមួយចំនួនមិនបានគ្រោងថវិកាសាលារៀនទេ តែបានពឹងផ្អែកលើខាងគម្រោងជួយឧបត្ថម្ភប៉ុណ្ណោះ។




ក្រាបទី២៩៖ បង្ហាញគំនិតយល់ឃើញពីសារៈប្រយោជន៍ នៃកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស

តាមរយៈក្រាបទី២៩ ជាទស្សនៈយល់ឃើញរបស់ប្រធានក្រុមបច្ចេកទេសទាំង២០សាលា ដែលបង្ហាញថា កម្មវិធីកញ្ចប់អំណានពិតជាមានសារៈសំខាន់ គឺស្មើនឹង ១០០%។ ចំពោះទស្សនៈយល់ឃើញដែលបង្ហាញថា កម្មវិធីកញ្ចប់អំណានមានសារៈប្រយោជន៍ ប្រធានក្រុមបច្ចេកទេសនៃសាលាសំណាកទាំង២០ បានផ្តល់ហេតុផលជារួមមកដូចខាងក្រោម៖

- ដឹងពីវិធីបង្រៀនសិស្សរៀនខ្សោយនិងកម្មវិធីក្នុងសៀវភៅកញ្ចប់អំណានប្លែកដើម្បីយកមកបង្រៀនដល់សិស្ស

- សិស្សទទួលបានលទ្ធផលល្អ

- ជួយសិស្សឲ្យចេះអាននិងចេះសរសេរបានច្រើន

- ធ្វើឲ្យការសិក្សារបស់សិស្សមានភាពរស់រវើក

- ធ្វើឱ្យសិស្សងាយយល់ខ្លឹមសារមេរៀន

- អាចឲ្យសិស្សស្គាល់តួអក្សរ ព្យញ្ជនៈ ស្រៈបានច្បាស់ ជួយសិស្សថ្នាក់ដំបូងឲ្យស្គាល់សូរ ស្គាល់តួអក្សរ និងសូរ អានស្ទាត់...

- ផ្តល់នូវចំណេះដឹងនិងជំនាញថ្មីៗដល់លោកគ្រូ អ្នកគ្រូ

- ទាក់ទាញការសិក្សារបស់ក្មេងៗ ព្រោះសិស្សចូលចិត្តនូវអ្វីដែលថ្មីៗប្លែកៗសម្រាប់ពួកគេ

- ជាបទពិសោធន៍ដ៏ល្អមួយសម្រាប់គ្រូនិងសិស្ស ក្នុងការយល់ដឹងពីបរិបទនៃការបង្រៀននិងរៀនតាមបែបថ្មីនឹងមានគុណភាព

- សាលាបានជួបប្រជុំជាមួយអង្គការញឹកញាប់

- ងាយស្រួលក្នុងការបង្រៀនធ្វើឱ្យសិស្សឆាប់ចេះនិងយល់យល់មេរៀនបានច្បាស់

- មានប្រយោជន៍ខ្លាំងណាស់ព្រោះសិស្សចេះបានច្រើន(បង្រៀនតាមសៀវភៅណែនាំ)

- គ្រូមានវិធីសាស្រ្តបង្រៀនប្លែកៗ និងងាយៗសម្រាប់សិស្សរៀន ឯសិស្សមានភាពសប្បាយរីករាយនិងចូលចិត្តការរៀន តាមវិធីសាស្រ្តបង្រៀនកញ្ចប់អំណានថ្មីដែលគ្រូបានផ្តល់ឱ្យ។

- កញ្ចប់អំណាននេះល្អមែនទែន

ទាំងនេះសុទ្ធតែជាទស្សនៈផ្ទាល់ខ្លួនរបស់ប្រធានក្រុមបច្ចេកទេសទាំងអស់ ដែលបានចូលរួមផ្តល់ទិន្នន័យ អំពីសារៈប្រយោជន៍នៃកម្មវិធីកញ្ចប់អំណានដំបូង។

ជាការសាកសួរសំណួរបន្ថែម ដើម្បីចង់ដឹងថា«តើសាលារៀនរបស់លោកគ្រូ អ្នកគ្រូ ក្រោយពីបានអនុវត្តកម្មវិធីកញ្ចប់អំណានហើយ តើសិស្សទទួលបានលទ្ធផលយ៉ាងដូចម្តេច?»។ ជាការឆ្លើយតបសំណួរប្រធានក្រុមបច្ចេកទេសនៃសាលាសំណាកទាំង២០ បានផ្តល់ជាចម្លើយជារួមមកដូចខាងក្រោម៖

-មុនពេលអនុវត្តកញ្ចប់អំណានសិស្សទទួលបានលទ្ធផលទាប ពេលអនុវត្តកញ្ចប់អំណានសិស្សទទួលបានលទ្ធផលខ្ពស់ ប្រសើរជាងមុន

- សិស្សមានចេះអាននិងសរសេរច្រើនជាងមុន សិស្សស្គាល់ព្យញ្ជនៈ ស្រៈបានច្បាស់

- លទ្ធផលសិក្សារបស់សិស្សថ្នាក់ទី២ទៅលើផ្នែកអំណានឃើញថាសិស្សអានបានល្អច្រើន សិស្សមានភាពក្លាហាន សិស្សមានការចូលរួមបានច្រើននិងសិស្សទទួលបាននូវអ្វីដែលថ្មីៗពីលោកគ្រូ អ្នកគ្រូ

- កាលពីមិនទាន់បានអនុវត្តកញ្ចប់អំណានសិស្សអានពុំសូវបានល្អ មិនដឹងពីការប្រកួតអំណាន មិនមានភាពក្លាហាននិងពុំសូវមានសម្ភារៈរៀនសម្បូរបែបឡើយ.

- មុនពេលកម្មវិធីកញ្ចប់ចាប់អនុវត្តយើងឃើញលទ្ធផលរបស់សិស្សជាប់មានកម្រិតទាប តែគម្រោងកញ្ចប់អំណានមកដល់លទ្ធផលជាប់ខ្ពស់ជាងមុន

- កម្មវិធីកញ្ចប់អំណានដំបូងនេះល្អណាស់មានអត្ថប្រយោជន៍ចំពោះលទ្ធផលនៃការសិក្សារបស់សិស្សថ្នាក់ទី២លើផ្នែកអំណានការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ដើម្បីឱ្យសិស្សឆាប់យល់មេរៀន សិស្សមានសមត្ថភាពអានសរសេរបានត្រឹមត្រូវ សិស្សចេះអានច្រើនប្រសើរជាងមុន។

- មុនពេលអនុវត្តកញ្ចប់អំណានសិស្សមិនសូវចេះប្រកបចេះអាន ពេលចាប់ផ្តើមអនុវត្តកញ្ចប់អំណាន សិស្សចេះអាន ចេះប្រកប ចេះសរសេរ

- មុនពេលអនុវត្តកញ្ចប់អំណានះដំណើរការមេរៀនមានភាពលំបាក ការអនុវត្តលើការអានព្យាង្គ ពាក្យ តិចពេក សិស្សមិនបានហ្វឹកហាត់ការអានអត្ថបទខ្លី ធ្វើអោយលទ្ធផលនៃការសិក្សានៅមានកម្រិតទាបសិស្សមិនសូវចេះអានបានច្រើន។

- ចាប់ផ្តើមអនុវត្តកញ្ចប់អំណាន ដំណើរការបង្រៀនតាមលំនាំនីមួយៗច្បាស់លាស់តាមការណែនាំក្នុងសៀវភៅណែនាំគ្រូ សៀវភៅជំនួយសិស្សមានភាពទាក់ទាញនិងច្បាស់ ជាផ្នែកមួយទាក់ទាញអារម្មណ៍សិស្ស ដូចជាតារាងការអានព្យាង្គ ពាក្យ តួអក្សរធំៗច្បាស់ៗជាដើម លទ្ធផលនៃការសិក្សា ទទួលបានគុណភាពខ្ពស់ជាងមុន សិស្សចេះអាន និង ចូលចិត្តការអានច្រើន។

ជាមួយគ្នានេះដែរ តាមរយៈកម្រងសំណួរក៏បានសាកសួរបន្ថែមលើលោកគ្រូ អ្នកគ្រូជាប្រធានក្រុមបច្ចេកទេសថា«តើក្រៅពីការងារជាប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូបានជួយការងារអ្វីបន្ថែមទៀតដល់សាលាដែរឬទេ ដើម្បីឱ្យសាលារៀនមានភាពរីកចម្រើន និងទទួលបានលទ្ធផលសិក្សារបស់សិស្សល្អ?» ជាការឆ្លើយតប លោកគ្រូ អ្នកគ្រូជាប្រធានក្រុមទាំងអស់បានផ្តល់ទិន្នន័យបន្ថែមថា ក្រៅពីមានតួនាទីជាប្រធានក្រុមបច្ចេកទេស ពួកគាត់ខ្លះជានាយកផង បង្រៀនផង ដោយសារតែខ្វះបុគ្គលិក ខ្លះជួយ

សាលាដោយកាន់ជាហេរញ្ញិក ជួយរៀបចំបរិស្ថានសាលាក្នុងថ្នាក់និងក្រៅថ្នាក់ ការងារសុខភាពអនាម័យ ការងារស្បៀង ការងារក្រុមប្រឹក្សាកុមារ ទទួលបន្ទុកកីឡា ជាប្រធានក្រុមបច្ចេកទេសក្នុងសាលាផង ជាប្រធានក្រុមបច្ចេកទេសគណិតវិទ្យាប្រចាំកម្រងផង កាន់ខាងសួនបំណិនជីវិត ការងាររដ្ឋបាលសាលា លេខាធិការ នាយឃ្លាំងជាដើម។

**ផ្នែកទី៣៖ សំណូមពរ និងចំណាប់អារម្មណ៍របស់ប្រធានក្រុមបច្ចេកទេស ចំពោះកម្មវិធីកញ្ចប់អំណានដំបូង៖**

- ស្នើសុំសៀវភៅកញ្ចប់អំណានសម្រាប់គ្រូ និងសិស្ស
- កម្មវិធីកញ្ចប់អំណាននេះល្អមែនទែន
- សូមឱ្យមានវគ្គសិក្ខាសាលាចាប់ពីថ្នាក់ទី១រហូតដល់ទី៦
- បើកវគ្គសិក្ខាសាលាដើម្បីរំឭកពីលំនាំបង្រៀននិងជួយឧបត្ថម្ភសម្ភារៈបង្រៀនបន្ថែម
- សូមឲ្យមានវគ្គបណ្តុះបណ្តាលកញ្ចប់អំណានសម្រាប់គ្រូល្អ សូមឲ្យបន្តកញ្ចប់អំណានថ្នាក់ទី៣បន្តទៀត
- កម្មវិធីកញ្ចប់អំណានដំបូងនេះល្អណាស់ មានអត្ថប្រយោជន៍ទៅលើការបង្រៀនរបស់លោកគ្រូអ្នកគ្រូដើម្បីឱ្យសិស្សឆាប់យល់មេរៀន សិស្សមានសមត្ថភាពអាន សរសេរបានត្រឹមត្រូវ
- មុនពេលអនុវត្តសិស្សនិងគ្រូពិបាកស្វែងយល់លើខ្លឹមសារមេរៀន ពេលបានអនុវត្ត សិស្សនិងគ្រូបានស្វែងយល់ពីមេរៀនបានច្បាស់ល្អ ងាយស្រួលក្នុងការរៀននិងបង្រៀន ពិតជាសប្បាយចិត្តចំពោះកញ្ចប់អំណាននេះណាស់
- បានយល់ដឹងពីវិធីសាស្ត្រថ្មី យល់ពីលំហូរបង្រៀនភាសាខ្មែរ
- កម្មវិធីកញ្ចប់អំណានដំបូងល្អ គឺសិស្សមានការចូលរួមរៀន ព្រោះនៅលំហូមួយៗមានល្បែងសិក្សា មានសកម្មភាពគ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើ
- មានលំដាប់លំដោយសកម្មភាពបង្រៀន ងាយស្រួលដល់ការបង្រៀន

- សិស្សចេះច្រើនជាងមុន សកម្មភាពបង្រៀនច្រើន

- សុំឱ្យមានវគ្គសិក្ខាសាលាពីការផលិតសម្ភារឧបទេសឱ្យបានច្រើន

- ក្រោយចាប់ផ្តើមអនុវត្តកញ្ចប់អំណានមកសិស្សទទួលបានលទ្ធផលល្អច្រើន ងាយចងចាំ ឆាប់ចេះប្រកប អានមានឃ្លា មានល្បះបានត្រឹមត្រូវ ងាយស្រួលក្នុងការបង្រៀន

- ពេញចិត្តខ្លាំងណាស់ជាមួយនឹងកម្មវិធីកញ្ចប់អំណានភាសាខ្មែរនេះ ព្រោះផ្តល់ភាពងាយស្រួលដល់ការបង្រៀន ថែមទាំងផ្តល់ភាពទាក់ទាញឱ្យសិស្សចូលចិត្ត ចាប់អារម្មណ៍ជាមួយនឹងការរៀន ធ្វើឱ្យលទ្ធផលការសិក្សារបស់សិស្សកើនឡើងផងដែរ។

### ៤.៣.៥. ការវិភាគទិន្នន័យលើកម្រងសំណួរសម្រាប់គ្រូបង្រៀនថ្នាក់ទី២

### ផ្នែកទី១៖ ព័ត៌មានទូទៅ




ក្រាបទី៣០៖ បង្ហាញពីភេទរបស់លោកគ្រូ អ្នកគ្រូសាលាសំណាកទាំង២០ តាមទិន្នន័យរបស់គ្រូបង្រៀន

តាមរយៈក្រាបទី៣០ បង្ហាញថា លោកគ្រូ អ្នកគ្រូសាលាសំណាកទាំង២០ ដែលបានជួយបំពេញកម្រងសំណួរទាំងអស់មានចំនួន៣០រូប។ ទាក់ទងទៅនឹងភេទលោកគ្រូ អ្នកគ្រូ ឃើញថាក្នុងចំណោមគ្រូបង្រៀនទាំងអស់មានភេទប្រុស មានចំនួន០៨នាក់ ស្មើនឹង២៧% ចំណែកភេទស្រីមានចំនួន២២នាក់ ស្មើនឹង៧៣%។ ដូចនេះតាមរយៈរូបភាពខាងលើ យើងឃើញថា អ្នកគ្រូមានចំនួនច្រើនជាងលោកគ្រូ។

**តារាងទី១៥៖ បង្ហាញពីអាយុរបស់គ្រូបង្រៀនថ្នាក់ទី២ តាមទិន្នន័យរបស់គ្រូបន្ទុកថ្នាក់ទី២**

| ល.រ | កម្រិតអាយុ | ប្រុស | ភាគរយ | ស្រី | ភាគរយ | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|
| ១ | 20-25 | 0 | 0% | ៤ | 13.33% | ៤ | **13.33%** |
| ២ | 26-30 | ៣ | 10% | ៥ | 16.66% | ៨ | **26.66%** |
| ៣ | 31-35 | ៣ | 10% | ៦ | 20% | ៩ | **30%** |
| ៤ | 36-40 | ១ | 3.33% | ៣ | 10% | ៤ | **13.33%** |
| ៥ | 41-45 | ១ | 3.33% | 0 | 0% | ១ | **3.33%** |
| ៦ | 46-50 | 0 | 0% | ១ | 3.33% | ១ | **3.33%** |
| ៧ | 51-55 | 0 | 0% | ២ | 6.66% | ២ | **6.66%** |
| ៨ | លើសពី55 | 0 | 0% | ១ | 3.33% | ១ | **3.33%** |
| សរុប | | **08** | **26.66%** | **22** | **73.33%** | **30** | **100%** |

តាមរយៈតារាងទី១៥ បង្ហាញថា ក្នុងចំណោមអាយុគ្រូបង្រៀនថ្នាក់ទី២ទាំង៣០នាក់ ដែលបានបំពេញកម្រងសំណួរ មានកម្រិតអាយុផ្សេងៗគ្នា។ គ្រូបង្រៀនដែលមានអាយុចន្លោះពី២០ទៅ២៥ឆ្នាំ មានចំនួន៤នាក់ គឺប្រុសគ្មាន ស្មើនឹង០% ស្រី៤នាក់ ស្មើនឹង១៣.៣៣% ភាគរយរួមគឺ១៣.៣៣%។ អាយុចន្លោះពី២៦ទៅ៣០ឆ្នាំ មានចំនួន០៨នាក់ ប្រុស៣នាក់ ត្រូវជា១០% និងស្រី០៥នាក់ ត្រូវជា ១៦.៦៦% ជារួមស្មើនឹង ២៦.៦៦%។ ចន្លោះអាយុចាប់ពី៣១-៣៥ មានចំនួន០៩នាក់ ប្រុស០៣នាក់ ត្រូវជា១០% និងស្រី០៦នាក់ ស្មើនឹង២០% ជារួមត្រូវជា៣០%។ ចំពោះអ្នកមានចន្លោះអាយុ ៣៦-៤០ មានចំនួន ៤នាក់ ប្រុស០១នាក់ ស្មើនឹង៣.៣៣% និងស្រី០៣នាក់ស្មើនឹង១០% ជារួមត្រូវជា ១៣.៣៣%។ ចំណែកអ្នកមានអាយុចន្លោះពី៤១-៤៥ឆ្នាំ មានចំនួន០១នាក់ ក្នុងនោះប្រុសមានចំនួន

០១នាក់ ស្មើនឹង៣.៣៣% និងស្រីគ្មាន ស្មើនឹង០% ជារួមត្រូវជា៣.៣៣%។ រីឯចន្លោះអាយុពី៤៦-៥០ឆ្នាំ មានចំនួន០១នាក់ គឺប្រុសគ្មាន ស្មើនឹង០% និងស្រីមានចំនួន០១នាក់ ស្មើនឹង៣.៣៣% ជារួមគឺស្មើនឹង៣.៣៣%។ ចំពោះចន្លោះអាយុពី៥១-៥៥ឆ្នាំ មានចំនួន២នាក់ គឺប្រុសគ្មាន ស្មើនឹង០% និងស្រីមានចំនួន០២នាក់ ស្មើនឹង៦.៦៦% ជារួមស្មើនឹង៦.៦៦%។ ដោយឡែក អ្នកដែលមានអាយុលើសពី៥៥ឆ្នាំ មានចំនួន០១នាក់ គឺប្រុសគ្មាន ស្មើនឹង០% និងស្រីមានចំនួន០១នាក់ ស្មើនឹង៣.៣៣%។ ដូចនេះ តាមរយៈតារាងខាងលើ អាចនិយាយបានថា គ្រូបង្រៀនភាគច្រើនជាយុវជន យុវនារី ជាបុគ្គលពេញកម្លាំងដែលមានអាយុចន្លោះពី២០ទៅ៤០ឆ្នាំ មានរហូតដល់ទៅ២៥នាក់ទៅហើយ ក្នុងចំណោម៣០នាក់ គឺមានន័យថា ជាវ័យដែលមានសក្ដានុពលល្អសម្រាប់ចូលរួមធ្វើការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអប់រំ។

**តារាងទី១៦៖ បង្ហាញពីកម្រិតវប្បធម៌របស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យរបស់ប្រធានក្រុមបច្ចេកទេស**

| ល.រ | កម្រិតវប្បធម៌ | ប្រុស | ភាគរយ | ស្រី | ភាគរយ | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|
| ១ | ស.បរិញ្ញាបត្រ | 2 | 6.66% | 6 | 20% | 8 | **26.66%** |
| ២ | ស.មធ្យមសិក្សាទុតិយភូមិ | 6 | 20% | 13 | 43.33% | 19 | **63.33%** |
| ៣ | ស.ក្រោមបាក់ឌុប | 0 | 0% | 3 | 10% | 3 | **10%** |
| សរុប | | **08** | **26.66%** | **22** | **73.33%** | **30** | **100%** |

យោងតាមតារាងទី១៦បង្ហាញថា ក្នុងចំណោមគ្រូបង្រៀនទាំង៣០រូប ដែលបានបំពេញកម្រងសំណួរទាំងអស់ ខ្ញុំបាទបានបែងចែកជា៣កម្រិតផ្សេងៗគ្នា។ លោកគ្រូ អ្នកគ្រូដែលមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រមានភេទប្រុស០២នាក់ ត្រូវជា៦.៦៦% និងស្រី០៦នាក់ ស្មើនឹង ២០% ជារួមស្មើនឹង២៦.៦៦%។ ចំណែកឯ គ្រូបង្រៀនមានកម្រិតវប្បធម៌ជាប់មធ្យមសិក្សាទុតិយភូមិ(បាក់ឌុប) ប្រុសមានចំនួន ០៦នាក់ ស្មើនឹង២០% និងស្រីមានចំនួន១៣នាក់ ស្មើ៤៣.៣៣% ជារួមមានចំនួន១៩នាក់ គឺស្មើ

នឹង៦៣.៣៣% និងសញ្ញាបត្រក្រោមបាក់ឌុប មានចំនួន០៣នាក់ ប្រុសគ្មាន ស្មើនឹង០% គឺស្រីទាំង០៣នាក់ ស្មើនឹង១០%។ ដូចនេះ យើងឃើញថា លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ភាគច្រើន មានកម្រិតសញ្ញាបត្រជាប់មធ្យមសិក្សាទុតិយភូមិ ដែលមានចំនួនច្រើនជាងគេ។

**តារាងទី១៧៖ បង្ហាញពីកម្រិតវិជ្ជាជីវៈរបស់លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ តាមទិន្នន័យរបស់លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២**

| ល.រ | កម្រិតវិជ្ជាជីវៈ | ប្រុស | ភាគរយ | ស្រី | ភាគរយ | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|
| ១ | គ្រូកម្រិតឧត្តម | 00នាក់ | 0% | 00នាក់ | 0% | 0% | 0% |
| ២ | គ្រូកម្រិតមូលដ្ឋាន | 01នាក់ | 3.33% | 01នាក់ | 3.33% | 02នាក់ | 6.66% |
| ៣ | គ្រូបឋមសិក្សា | 07នាក់ | 23.33% | 21នាក់ | 70% | 28នាក់ | 93.33% |
| សរុប | | **08នាក់** | **26.66%** | **22នាក់** | **73.33%** | **30នាក់** | **100%** |

យោងតាមរយៈតារាងទី១៧ បង្ហាញថាគ្រូបង្រៀនថ្នាក់ទី២ដែលមានកម្រិតវិជ្ជាជីវៈជាគ្រូកម្រិតឧត្តមគឺគ្មាន ស្មើនឹង០%។ ចំពោះលោកគ្រូ អ្នកគ្រូដែលមានកម្រិតវិជ្ជាជីវៈជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ភេទប្រុស មានចំនួន ០១នាក់ ត្រូវជា ៣.៣៣% ភេទស្រីមានចំនួន ០១នាក់ ត្រូវជា ៣.៣៣%ដែរ ជារួមមានចំនួន ០២នាក់ ត្រូវជា ៦.៦៦%។ ចំពោះគ្រូបង្រៀនដែលមានកម្រិតវិជ្ជាជីវៈជាគ្រូបង្រៀនកម្រិតបឋមសិក្សា ភេទប្រុសមានចំនួន ០៧នាក់ ស្មើនឹង ២៣.៣៣% ភេទស្រីមានចំនួន ២១នាក់ ស្មើនឹង ៧០% ជារួមមានចំនួន២៨នាក់ ស្មើនឹង៩៣.៣៣%។ ដូចនេះឃើញថាគ្រូបង្រៀនថ្នាក់ទី២ទាំង៣០រូប មានកម្រិតវិជ្ជាជីវៈតែពីរកម្រិតប៉ុណ្ណោះ គឺជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងជាគ្រូបង្រៀនកម្រិតបឋម ហើយស្ទើរតែទាំងអស់គឺជាគ្រូបង្រៀនកម្រិតបឋមដែលមានរហូតដល់៩៣.៣៣%។

**តារាងទី១៨៖ បង្ហាញពីរយៈពេលបំពេញការងារក្នុងវិស័យអប់រំ របស់លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ តាមទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២**

| ល.រ | រយៈពេលបំពេញការងារ | ប្រុស | ស្រី | សរុប | ភាគរយ |
|---|---|---|---|---|---|

| | | | | | |
|---|---|---|---|---|---|
| ១ | ០១-០៥ឆ្នាំ | ០២នាក់ | ០៤នាក់ | ០៦នាក់ | 20% |
| ២ | ០៦-១០ឆ្នាំ | ០២នាក់ | ០៩នាក់ | ១១នាក់ | 36.66% |
| ៣ | ១១-១៥ឆ្នាំ | ០២នាក់ | ០៣នាក់ | ០៥នាក់ | 16.66% |
| ៤ | ១៦-២០ឆ្នាំ | ០១នាក់ | ០២នាក់ | ០៣នាក់ | 10% |
| ៥ | ២១-២៥ឆ្នាំ | ០១នាក់ | ០០នាក់ | ០១នាក់ | 3.33% |
| ៦ | ២៦-៣០ឆ្នាំ | ០០នាក់ | ០០នាក់ | ០០នាក់ | 0% |
| ៧ | លើស៣០ឆ្នាំ | ០០នាក់ | ០៤នាក់ | ០៤នាក់ | 13.33% |
| **សរុប** | | **០៨នាក់** | **២២នាក់** | **៣០នាក់** | **100%** |

តាមរយៈតារាងទី១៨ បង្ហាញថា គ្រូបង្រៀនទាំង៣០រូប មានរយៈពេលក្នុងការបំពេញការងារក្នុងវិស័យអប់រំផ្សេងៗគ្នា គឺបើគិតចន្លោះពី០១-០៥ឆ្នាំ មានចំនួនសរុប០៦នាក់ ស្រី០៤នាក់ ភាគរយរួមស្មើនឹង២០%។ ចន្លោះពី០៦-១០ឆ្នាំ មានចំនួនសរុប១១នាក់ ស្រី០៩នាក់ ភាគរយរួម ត្រូវជា ៣៦.៦៦%។ ចំណែកចន្លោះពី១១-១៥ឆ្នាំ មានចំនួន០៥នាក់ ស្រី ០៣នាក់ គិតជាភាគរយរួមស្មើនឹង ១៦.៦៦%។ ចំពោះរយៈពេលចន្លោះពី១៦-២០ឆ្នាំ មានចំនួន០៣នាក់ ស្រី ០២នាក់ គិតជាភាគរយរួមគឺ ១០% ហើយរយៈពេលពី២១-២៥ឆ្នាំ មានចំនួន០១នាក់ ស្រីគ្មាន គិតជាភាគរយស្មើនឹង ៣.៣៣%។ រីឯរយៈពេលពី ២៦-៣០ គឺគ្មាន គិតជាភាគរយគឺ ០% និងអ្នកដែលមានអតីតភាពការងារលើសពី៣០ឆ្នាំ មានចំនួន ០៤នាក់ ស្រី ០៤នាក់ គិតជាភាគរយស្មើនឹង ១៣.៣៣%។ ដូចនេះតាមរយៈការពិនិត្យលើអតីតភាពការងាររបស់លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ទាំង៣០រូប ឃើញថាអ្នកដែលមានអតីតភាពការងារចន្លោះពី០៦-១០ឆ្នាំ មានចំនួនច្រើនជាងគេ មានន័យថាគឺជារយៈពេល ដែលស្ថិតក្នុងកម្រិតទីពីរនៅក្នុងការបំពេញក្របខណ្ឌ នៃវិស័យអប់រំ។ ចំណែកឯអ្នកដែលមានអតីតភាពការងារលើសពី៣០ឆ្នាំ គឺមានចំនួន ០៤នាក់ ក្នុងនោះស្រីទាំង ០៤នាក់ ជារយៈពេលមួយដ៏វែង ដែលពួកគាត់បានចំណាយពេលវេលាក្នុងការជួយអភិវឌ្ឍ

នូវវិស័យអប់រំរបស់យើង ហើយបើតាមរយៈពេលនេះគឺគាត់អាចដាក់ពាក្យចូលនិវត្តន៍មុនអាយុកាលកំណត់នៃការចូលនិវត្តន៍បាន។

ជាការសាកសួរនូវសំណួរបន្ថែមថា«ក្រៅពីការងារបង្រៀន តើលោកគ្រូ អ្នកគ្រូ មានកាន់តួនាទី ឬជួយការងារអ្វីខ្លះទៀតដល់សាលារៀន?» ជាការឆ្លើយតប លោកគ្រូ អ្នកគ្រូ បានផ្តល់ចម្លើយជារួមគឺខ្លះជានាយក ជានាយករង ជាប្រធានក្រុមបច្ចេកទេសថ្នាក់ទី២ ការងារបរិស្ថានសាលារៀន ទំនាក់ទំនងជាមួយមាតាបិតាសិស្ស អាជ្ញាធរ និងអង្គការដៃគូ ផលិតសម្ភារៈបង្រៀននិងរៀន កាន់ផ្នែកគណនេយ្យ ក្រុមប្រឹក្សាភិបាល កាន់ខាងសួនបំណិនជីវិត អនាម័យសិស្ស(លាងស្អាតដៃ កាត់ក្រចកដៃ...)ដឹកនាំសិស្សសម្អាតបរិស្ថានសាលារៀន(ក្នុងថ្នាក់និងក្រៅថ្នាក់)ជួយការងារក្រុមប្រឹក្សាកុមារ ជួយថតនិងកាត់តវីឌីអូផ្សេងៗលេខាធិការ នាយឃ្លាំង គ្រប់គ្រងផេក(Facebook Page) របស់សាលាជាដើម។ ទាំងនេះបង្ហាញពីការចូលរួមរបស់លោកគ្រូ អ្នកគ្រូ ក្រៅពីការបង្រៀនហើយ ឆ្លៀតជួយកិច្ចការផ្សេងៗនៅក្នុងសាលា ដើម្បីជាការរួមចំណែកក្នុងការអភិវឌ្ឍសាលារៀនផងដែរ។

### ផ្នែកទី២៖ ការងារបង្រៀន និងរៀន




ក្រាបទី៣១៖ បង្ហាញពីការចុះធ្វើអធិការកិច្ចថ្នាក់រៀនរបស់នាយក/នាយិកា តាមទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២

តាមរយៈក្រាបទី៣១ បង្ហាញឱ្យឃើញពីសកម្មភាពនៃការចុះអធិការកិច្ចថ្នាក់រៀនរបស់នាយក/នាយិកាចំពោះគ្រូដែលបង្រៀនថ្នាក់ទី២។ ក្នុងចំណោមគ្រូបង្រៀនថ្នាក់ទី២ចំនួន៣០នាក់ ដែលបង្រៀននៅ

សាលាសំណាកទាំង២០ មានចំនួន២៧នាក់ បានទទួលការចុះអធិការកិច្ចពីនាយក/នាយិកា ស្មើនឹង ៩០% និងមានចំនួន៣នាក់ មិនបានទទួលការចុះអធិការកិច្ចពីនាយក/នាយិកា ស្មើនឹង១០%។ ចំពោះអ្នកមិនបានចុះធ្វើអធិការកិច្ចថ្នាក់រៀន បានបញ្ជាក់ថា នាយក/នាយិកា បានចុះតែថ្នាក់ផ្សេង តែមិនបានចុះដល់ថ្នាក់របស់គាត់ រហូតមានបញ្ហាកូវីដកើតឡើង។

ជាការសួរសំណួរបន្ថែម ចំពោះអ្នកបានទទួលចុះអធិការកិច្ចថ្នាក់រៀនពីនាយក/នាយិកាថា «តើនាយក/នាយិកាបានបង្ហាញឱ្យឃើញពីចំណុចល្អ និងចំណុចគួរកែលម្អអ្វីខ្លះ របស់លោកគ្រូអ្នកគ្រូក្នុងការបង្រៀន? ហើយថាតើនាយក/នាយិកាផ្តល់ព័ត៌មានត្រឡប់មកភ្លាមៗក្រោយអធិការកិច្ចចប់ ឬពេលក្រោយមកបានប្រាប់?» ជាលទ្ធផលទទួលបានទិន្នន័យដូចខាងក្រោម៖

### ក. ចំណុចល្អ៖

- ពេលបង្រៀនសិស្ស សិស្សយកចិត្តទុកដាក់ក្នុងការរៀនសូត្រ
- មានកិច្ចតែងការបង្រៀន មានសម្ភារបង្រៀនច្រើន ការងាររដ្ឋបាលបានល្អត្រឹមត្រូវនិងទៀងទាត់ សំឡេងសមល្មមសម្រាប់សិស្ស មានសីលធម៌ល្អ
- មានការយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្រៀនសិស្ស
- បង្រៀនតាមលំនាំមេរៀនកញ្ចប់អំណានទី២បានល្អ
- បានប្រើប្រាស់វិធី I do , We do ,You do( គ្រូធ្វើ, គ្រូនិងសិស្សធ្វើ, សិស្សធ្វើ )
- បានធ្វើការវាយតម្លៃសមត្ថភាពសិស្ស
- មានការដាក់កិច្ចការផ្ទះ តាមសមត្ថភាពសិស្ស
- ផ្តោតលើការជួយ និងតាមដានសិស្សរៀនយឺត
- មានការលើកទឹកចិត្តសិស្ស និងមានការសម្របសម្រួលសិស្សតាមក្រុម បុគ្គល
- មានភាពរស់រវើក សកម្ម សិស្សចូលរួម
- ទៀងពេលវេលា បង្រៀនមានវិធីសាស្ត្រគ្រប់គ្រាន់

- គ្រប់គ្រងសិស្សបានល្អ បង្រៀនបានល្អ សិស្សមានរបៀប

- មានសម្លៀកបំពាក់សមរម្យ គោរពពេលវេលា

- តុបតែងថ្នាក់បានស្អាត សិស្សមានរបៀបល្អ

ខ. ចំណុចគួរកែលម្អ៖

- សង្កេតការរៀនរបស់សិស្សមិនបានជិតដល់ ជាពិសេសសិស្សនៅក្រោយ (ដោយសារចំនួនសិស្សច្រើន(ជាង៥០នាក់)

- ត្រូវបង្រៀនឱ្យទាន់ម៉ោងគ្រប់ជំហាន កំណត់ពេលវេលាឱ្យច្បាស់លាស់

- បង្កើនការប្រើសម្ភារឧបទេស សម្ភារបង្រៀនមិនទាន់គ្រប់គ្រាន់

- ផ្តោតលើសិស្សខ្សោយឱ្យបានច្រើន

- រៀបចំកិច្ចតែងការបង្រៀនឲ្យគ្រប់មេរៀន

- ផ្លាស់ប្តូររូបភាពនៅតាមជញ្ជាំងតាមខែនីមួយៗ ធ្វើការងាររដ្ឋបាលថ្នាក់រៀនឲ្យបានគ្រប់ចំណុច

- ពង្រឹងវិន័យសិស្សបន្ថែម

- បង្រៀនមិនទាន់កម្មវិធីសិក្សា

- សំឡេងមិនសូវឮ និយាយជាមួយសិស្សប្រើពាក្យមិនសមរម្យ

ចំពោះការផ្តល់ព័ត៌មានត្រឡប់របស់នាយក/នាយិកា តាមការបញ្ជាក់របស់លោកគ្រូ អ្នកគ្រូ គឺសុទ្ធតែផ្តល់មកដោយផ្ទាល់មាត់ក្រោយពេលអធិការកិច្ចថ្នាក់ហើយភ្លាមៗ ពុំបានចេញជារបាយការណ៍ ឬលិខិតរដ្ឋបាលអ្វីឡើយ។




**ក្រាបទី៣២៖ បង្ហាញពីការចុះធ្វើអធិការកិច្ចថ្នាក់រៀនរបស់ប្រធានក្រុមបច្ចេកទេស តាមទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២**

តាមរយៈក្រាបទី៣២ បង្ហាញឱ្យឃើញពីសកម្មភាពនៃការចុះអធិការកិច្ចថ្នាក់រៀនរបស់ប្រធានក្រុមបច្ចេកទេសចំពោះគ្រូដែលបង្រៀនថ្នាក់ទី២។ ក្នុងចំណោមគ្រូបង្រៀនថ្នាក់ទី២ចំនួន៣០នាក់ ដែលបង្រៀននៅសាលាសំណាកទាំង២០ មានចំនួន១៤នាក់ បានទទួលការចុះអធិការកិច្ចពីប្រធានក្រុមបច្ចេកទេស ដែលស្មើនឹង៤៧% និងមានចំនួន១៦នាក់ មិនបានទទួលការចុះអធិការកិច្ចពីប្រធានក្រុមបច្ចេកទេសនោះទេ គឺស្មើនឹង៥៣%។

ដូចនេះមានន័យថា អ្នកដែលមិនបានចុះធ្វើអធិការកិច្ចថ្នាក់រៀន មានចំនួនច្រើនជាងអ្នកដែលបានចុះអធិការកិច្ចថ្នាក់រៀនពីសំណាក់ប្រធានក្រុមបច្ចេកទេស។

ជាការសួរសំណួរបន្ថែម ចំពោះអ្នកបានទទួលចុះអធិការកិច្ចថ្នាក់រៀនពីប្រធានក្រុមបច្ចេកទេសថា «តើបានបង្ហាញឱ្យឃើញពីចំណុចល្អ និងចំណុចគួរកែលម្អអ្វីខ្លះ របស់លោកគ្រូអ្នកគ្រូក្នុងការបង្រៀន? ហើយថាតើប្រធានក្រុមផ្តល់ព័ត៌មានត្រឡប់មកភ្លាមៗក្រោយអធិការកិច្ចចប់ ឬពេលក្រោយមកបានប្រាប់?» ជាលទ្ធផលទទួលបានទិន្នន័យដូច ឬប្រហាក់ប្រហែលទៅនឹងការចុះអធិការកិច្ចរបស់នាយក/នាយិកាសាលារៀនដែរ។




**ក្រាបទី៣៣៖ បង្ហាញពីការតែងកិច្ចរបស់គ្រូនៅតាមសាលាសំណាកទាំង២០ តាមការផ្តល់ទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២ផ្ទាល់**

តាមរយៈក្រាបទី៣៣ បង្ហាញពីការតែងកិច្ចបង្រៀនរបស់គ្រូថ្នាក់ទី២ នៅសាលាសំណាកទាំង២០ ដែលមើលឃើញថា មានគ្រូបង្រៀនចំនួន០៩នាក់ មានកិច្ចតែងការគ្រប់មេរៀន ស្មើនឹង៣០% ចំណែកគ្រូបង្រៀនចំនួន២១រូបទៀត មានខ្លះ(មិនគ្រប់មេរៀន)ស្មើនឹង៧០%។

យោងតាមទិន្នន័យ ដែលផ្តល់ជូនដោយគ្រូបង្រៀន គឺមានភាពផ្ទុយគ្នាពីការផ្តល់ទិន្នន័យដោយប្រធានក្រុមបច្ចេកទេស មានន័យថាការផ្តល់ទិន្នន័យដោយគ្រូបង្រៀន គឺអ្នកដែលមានកិច្ចតែងការមិនគ្រប់មេរៀន មានចំនួនច្រើនជាងអ្នកមានកិច្ចតែងការគ្រប់មេរៀន ប៉ុន្តែអ្នកគ្មានកិច្ចតែងការគឺមិនមានដូចគ្នា។

ចំពោះការសួរសំណួរបន្ថែមថា ហេតុអ្វីបានជាមិនមានកិច្ចតែងការគ្រប់មេរៀន ពួកគាត់បានបញ្ជាក់ហេតុផលខ្លះៗដូចខាងក្រោម៖

- ការងារច្រើនពេក ជាប់រវល់(តែនឹងព្យាយាមធ្វើឱ្យបានច្រើនជាងនេះ)
- បង្រៀន២ពេល ដូច្នេះមិនសូវមានពេលគ្រប់គ្រាន់ តែងមិនទាន់
- ថ្នាក់ដួររហូត និងរវល់ផលិតសម្ភារៈ
- ទើបតែបង្រៀនថ្នាក់ទី២ ឆ្នាំសិក្សា ២០២០-២០២១

- មិនបានធ្វើបច្ចុប្បន្នភាព ដោយសារជំងឺកូវីដ-19
- បង្រៀន២ពេល ដូច្នេះមិនសូវមានពេលគ្រប់គ្រាន់
- មានកូនតូច កម្មវិធីថ្មី
- សាលារៀនមានការផ្លាស់គ្រូទៅតាមកម្រិតថ្នាក់រៀន និងមានការតែងឡើងវិញជាថ្មីតាមលំដាប់លំដោយនៃមេរៀនទៅតាមមុខវិជ្ជា

ប៉ុន្តែទោះបីជាយ៉ាងណាក៏នៅតែឃើញថា លោកគ្រូ អ្នកគ្រូ បានអនុវត្តការតែងកិច្ចបង្រៀន គ្រាន់តែមិនបានគ្រប់មេរៀន ដោយផ្តោតលើហេតុផលផ្សេងៗដូចបានរៀបរាប់ខាងលើ។




**ក្រាបទី៣៤៖ បង្ហាញពីការប្រជុំក្រុមបច្ចេកទេសនៅតាមសាលានីមួយៗ តាមទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២**

យោងតាមក្រាបទី៣៤ បង្ហាញថា ក្នុងចំណោមលោកគ្រូ អ្នកគ្រូចំនួន៣០នាក់ ដែលតំណាងឱ្យសាលាសំណាកទាំង២០ ហើយបានផ្តល់ទិន្នន័យ គឺបានប្រជុំបច្ចេកទេសចំនួន២៩នាក់ ស្មើនឹង៩៧% ហើយមានចំនួន០១នាក់ ដែលថាមិនបានប្រជុំ គឺស្មើនឹង៣%។ ជាការសាកសួរសំណួរបន្ថែម «ថាតើការប្រជុំក្រុមបច្ចេកទេសនៅតាមសាលាកន្លងទៅ បានលើកយកប្រធានបទអ្វីខ្លះមកធ្វើការប្រជុំពិភាក្សាគ្នា?» ជាលទ្ធផលលោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ទាំងអស់ បានបង្ហាញដូចខាងក្រោម៖

- ការធ្វើថ្នាក់និទស្សន៍ ការបូកសរុបបនៃការធ្វើថ្នាក់និទស្សន៍ ការដោះស្រាយបញ្ហាប្រឈមក្នុងការបង្រៀន ការចែករំលែកវិធីសាស្ត្រថ្មីៗដើម្បីបង្រៀនសិស្សងាយយល់ ផលិតសម្ភារៈឧបទេស និងធ្វើផែនការបន្ត

- អំណាន សំណេរ និងគណិតវិទ្យា

- ការជួយសិស្សរៀនយឺត

- ការត្រៀមប្រឡងឆមាសលើកទីមួយ ពិនិត្យការងាររដ្ឋបាលគ្រូ

- រៀបកាលវិភាគបង្រៀនតាមបណ្តុំ តាមភូមិ

- រកបញ្ហាប្រឈម និងដំណោះស្រាយ

- ចែករំលែកវិធីសាស្ត្របង្រៀន




**ក្រាបទី៣៥៖ បង្ហាញពីរយៈពេលនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងនៅសាលាសំណាកទាំង២០ តាមការផ្តល់ទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២**

តាមរយៈក្រាបទី៣៥ បង្ហាញថា លោកគ្រូ អ្នកគ្រូដែលឆ្លើយថាកម្មវិធីកញ្ចប់អំណានបានអនុវត្ត ហើយរយៈពេល២ឆ្នាំ មានចំនួន៣នាក់ ត្រូវជា១០% និងលោកគ្រូ អ្នកគ្រូដែលបានឆ្លើយថាកម្មវិធីកញ្ចប់

អំណានបានអនុវត្តរយៈពេល៣ឆ្នាំហើយ មានចំនួន២៧នាក់ ស្មើនឹង៩០%។ ដូចនេះបង្ហាញថា សាលាដែលបានអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងបានរយៈពេល៣ឆ្នាំ មានចំនួនច្រើនជាងសាលាដែលបានអនុវត្តមានរយៈពេល២ឆ្នាំ។ ប៉ុន្តែចំពោះសាលាដែលអនុវត្តបាន២ឆ្នាំ មានន័យថាសាលារបស់គាត់ក៏បានអនុវត្តដល់កម្រិតថ្នាក់ទី២ហើយដែរ។




### ក្រាបទី៣៦៖ បង្ហាញពីការចូលរួមសិក្ខាសាលាកម្មវិធីកញ្ចប់អំណានរបស់លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ តាមការផ្តល់ទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២

តាមរយៈក្រាបទី៣៦ បង្ហាញថា ក្នុងចំណោមលោកគ្រូ អ្នកគ្រូ៣០នាក់ នៃសាលាសំណាកទាំង២០ គឺធ្លាប់បានចូលរួមកម្មវិធីសិក្ខាសាលាចំនួន២៥នាក់ គិតជាភាគរយស្មើនឹង៨៣% និងមិនធ្លាប់បានចូលរួមសិក្ខាសាលាចំនួន០៥នាក់ គិតជាភាគរយស្មើនឹង១៧%។ ជាការសួរសំណួរបន្ថែមចំពោះអ្នកបានចូលរួមសិក្ខាសាលា តើធ្វើឡើងតាមរយៈអ្វី? លោកគ្រូ អ្នកគ្រូទាំង២៥រូបសុទ្ធតែបានឆ្លើយថា តាមរយៈគម្រោង EQUAL របស់អង្គការ Save the Children ហើយតាមរយៈការសាកសួរសំណួរបន្ថែមចំពោះអ្នកមិនធ្លាប់បានចូលរួមសិក្ខាសាលាវិញ ពួកគាត់បានប្រាប់ពីហេតុផលថា ពេលសិក្ខាសាលារៀបចំឡើងពួកគាត់ពុំបានបង្រៀនថ្នាក់ទី២ទេ ជាប់បង្រៀនកម្រិតថ្នាក់ផ្សេង។

ដូចនេះយើងមើលឃើញថា គ្រូបង្រៀនថ្នាក់ទី២ភាគច្រើនធ្លាប់បានចូលរួមសិក្ខាសាលា ដោយមានរហូតដល់៨៣%។




**ក្រាបទី៣៧៖ បង្ហាញពីថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងរបស់សាលារៀនសំណាកទាំង ២០ តាមទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២**

តាមរយៈក្រាបទី៣៧ បង្ហាញថាក្នុងចំណោមសាលាសំណាកទាំង២០ ដែលបានផ្តល់ទិន្នន័យដោយគ្រូបង្រៀនថ្នាក់ទី២ទាំង៣០នាក់ គឺមានចំនួន១៨នាក់ ឆ្លើយថាមានថវិកាសម្រាប់ដំណើរការកម្មវិធីស្មើនឹង៦០% ចំណែកអ្នកដែលឆ្លើយថាមិនមានថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណាន មានចំនួន១២នាក់ ដែលស្មើនឹង៤០%។ ចំពោះសាលាដែលមិនមានថវិកាសម្រាប់កម្មវិធីកញ្ចប់អំណានបានផ្តល់មូលហេតុថា ដោយសារតែសាលារបស់គាត់មិនបានគ្រោងថវិកាក្នុងផែនការប្រតិបត្តិរបស់សាលារៀន។ រីឯសាលាដែលមានថវិកាសម្រាប់គាំទ្រកម្មវិធីកញ្ចប់អំណាន ដោយសារសាលាបានគ្រោងថវិកាដំណើរការសាលារៀនមួយផ្នែកសម្រាប់អនុវត្តកម្មវិធីកញ្ចប់អំណាននេះនៅសាលារៀន។

ក្នុងនោះដែរ ខ្ញុំបាទក៏បានសួរសំណួរបន្ថែមចំពោះសាលាដែលមានថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណានថា «ហេតុអ្វីបានដឹងថាមានថវិកាសម្រាប់ដំណើរការកម្មវិធីកញ្ចប់អំណាន?» ពួកគាត់បានប្រាប់ហេតុផលដូចខាងក្រោម៖

- មានការជួយឧបត្ថម្ភពីគម្រោង EQUAL នៃអង្គការ  Save the Children មួយផ្នែកធំ

- ព្រោះទទួលបានការផ្សព្វផ្សាយពីនាយក/ នាយករងនៅក្នុងសាលា

ជាមួយគ្នានេះដែរ ខ្ញុំបាទក៏បានសួរសំណួរបន្ថែមចំពោះសាលាដែលថាគ្មានថវិកាសម្រាប់ ដំណើរការកម្មវិធីកញ្ចប់អំណានថា «តើកម្មវិធីកញ្ចប់អំណាននៅសាលារៀនរបស់លោក លោកស្រីដែលបានដំណើរទៅនោះបានថវិកាពីណា?»។ ពួកគាត់បានឆ្លើយថា បានមកពីការជួយឧបត្ថម្ភរបស់គម្រោង EQUAL នៃអង្គការ  Save the Children។

ដូចនេះតាមការផ្តល់ទិន្នន័យ ក៏ដូចជាការសាកសួរបន្ថែម បានបង្ហាញឱ្យឃើញថាសាលាសំណាកទាំង២០ អាចដំណើរការកម្មវិធីកញ្ចប់អំណានទៅបាន អាស្រ័យដោយកត្តាពីរគឺ ទី១សាលាខ្លះចេះលៃលកថវិកាដំណើរការសាលារៀន ផ្សំជាមួយនឹងការជួយឧបត្ថម្ភពីគម្រោង និងសាលាមួយចំនួនមិនបានគ្រោងថវិកាសាលារៀនទេ តែបានពឹងផ្អែកលើខាងគម្រោងជួយឧបត្ថម្ភប៉ុណ្ណោះ។




## ក្រាបទី៣៨៖ បង្ហាញពីការអនុវត្តលំនាំបង្រៀនក្នុងកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង តាមទិន្នន័យរបស់គ្រូបង្រៀនថ្នាក់ទី២

តាមរយៈក្រាបទី៣៨ បង្ហាញថា ក្នុងចំណោមលោកគ្រូ អ្នកគ្រូ៣០នាក់ នៅសាលាសំណាកដែលបានអនុវត្តតាមលំនាំនៃការបង្រៀនកម្មវិធីកញ្ចប់អំណានមានចំនួន២៨នាក់ ត្រូវជា៩៣.៣៣% សម្រាប់

លោកគ្រូ អ្នកគ្រូ ដែលអនុវត្តបានខ្លះមានចំនួន ២នាក់ ស្មើនឹង៦.៦៦% និងលោកគ្រូ អ្នកគ្រូដែលមិនបាន អនុវត្តសោះ គឺមិនមានឡើយ។ សម្រាប់ហេតុផល លោកគ្រូ អ្នកគ្រូដែលអនុវត្តបានខ្លះ បានលើកឡើងថា ដោយសារតែកត្តាពេលវេលា និងទំហំមេរៀន។

ដូចនេះឃើញថា លោកគ្រូ អ្នកគ្រូ បង្រៀននៅថ្នាក់ទី២ទាំងអស់ នៃសាលាសំណាកសុទ្ធតែបាន អនុវត្តតាមលំនាំនៃការបង្រៀនកម្មវិធីកញ្ចប់អំណានទាំងអស់គ្នា ពោលគឺអនុវត្តតាមសកម្មភាពគោលទាំង ៧ សមាសភាគទាំង៥ និងប្រើគោលវិធី៣សំខាន់ៗគឺ គ្រូធ្វើ គ្រូ និងសិស្សធ្វើ សិស្សធ្វើ ដោយសារតែលោក គ្រូ អ្នកគ្រូទាំងនោះបានទទួលវគ្គបណ្តុះបណ្តាលពីគម្រោងការអប់រំប្រកបដោយគុណភាព និងបរិយាបន្ន (EQUAL) នៃអង្គការ Save the Children។




**ក្រាបទី៣៩៖ បង្ហាញគំនិតយល់ឃើញពីសារៈប្រយោជន៍ នៃកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង តាមទិន្នន័យរបស់ គ្រូបង្រៀនថ្នាក់ទី២**

តាមរយៈក្រាបទី៣៩ ជាទស្សនៈយល់ឃើញរបស់គ្រូបង្រៀនទាំង៣០នាក់ ដែលតំណាងឱ្យ សាលាសំណាកទាំង២០សាលា បានបង្ហាញថា កម្មវិធីកញ្ចប់អំណានពិតជាមានសារៈសំខាន់ គឺស្មើនឹង ១០០%។ ចំពោះទស្សនៈយល់ឃើញ ដែលបង្ហាញថា កម្មវិធីកញ្ចប់អំណានមានសារៈប្រយោជន៍ គ្រូ បង្រៀនថ្នាក់ទី២ដែលបានផ្តល់ទិន្នន័យទាំងអស់ បានផ្តល់ហេតុផលជារួមមកដូចខាងក្រោម៖

- នៅពេលសិស្សរៀនតាមកញ្ចប់អំណាន មុនដំបូងគឺមានការពិបាកក្នុងការសិក្សា តែយូរៗទៅសិស្សមានការយល់ដឹងច្រើន និងចូលចិត្តរៀនសូត្រ (តែគ្រូបង្រៀនគឺហត់ខ្លាំងក្នុងការបង្រៀន ហើយដោយសារសិស្សមានចំនួនច្រើនផង)

- ងាយធ្វើកិច្ចតែងការបង្រៀន ងាយស្រួលក្នុងការបង្រៀន មានលំនាំច្បាស់លាស់ សិស្សងាយយល់ ការសិក្សារបស់សិស្សរីកចម្រើន

សិស្សស្គាល់សូរ ស្គាល់តួអក្សរច្បាស់ ឆាប់ចេះអាន និងចេះសរសេរ សិស្សឆាប់ចាប់បានមេរៀនចងចាំបានយូរ

- ដឹងពីវិធីសាស្ត្របង្រៀន និងវិធីជួយសិស្សខ្សោយ

- មានលំដាប់លំដោយសកម្មភាពបង្រៀន ងាយស្រួលដល់ការបង្រៀន

- ដោយសារតែសកម្មភាពភាពនីមួយៗច្បាស់ ហើយសិស្សមានសកម្មភាពច្រើន សិស្សចេះអានសិស្សមានសុជីវធម៌ សិស្សមានសកម្មភាពរស់រវើក

- សិស្សស្គាល់ស្រៈ និងព្យញ្ជនៈបានច្បាស់លាស់

- សិស្សមានភាពក្លាហាន សិស្សមានសកម្មភាពច្រើនក្នុងការរៀន បង្កើតការគិតរបស់សិស្សសិស្សបានហ្វឹកហាត់អាន សិស្សគ្រូបានធ្វើសកម្មភាពរួមគ្នា សិស្សមានពេលវេលាច្រើនក្នុងការហ្វឹកហាត់អានសរសេរ មានសៀវភៅជំនួយងាយបង្រៀន និងរៀនសម្រាប់សិស្ស-គ្រូ មានលំនាំបង្រៀនលម្អិតគ្រប់សកម្មភាពសម្រាប់គ្រូ-សិស្ស

- មានការប្រើកាយវិការ ឬប័ណ្ណរូបភាពជំនួយការចងចាំសិស្ស មានការហ្វឹកហាត់ការងារដៃគូបុគ្គល ក្រុមជាមួយកុមារដើម្បីផ្លាស់ប្តូរចំណេះដឹងគ្នា

- សៀវភៅសិក្សាមានពណ៌ច្បាស់ល្អ មានបំណិនក្នុងការអាន និយាយ

- ឲ្យគ្រូមានបទពិសោធន៍ថ្មី ចំណេះដឹងថ្មី ដែលធ្វើឲ្យសិស្សឆាប់យល់ ឆាប់ចេះអានជាងមុន

- សិស្សសប្បាយរីករាយក្នុងការរៀនសូត្រ សិស្សមានសកម្មភាពច្រើន

- បានយល់ដឹងពីវិធីសាស្ត្រថ្មី យល់ពីលំហូរបង្រៀនភាសាខ្មែរ

- ជាវិធីសាស្ត្រថ្មីបង្រៀនមានការទាក់ទាញអារម្មណ៍សិស្ស

- កម្មវិធីកញ្ចប់អំណានដំបូងនេះបានធ្វើឱ្យគ្រូយល់កាន់តែច្បាស់ពីវិធីសាស្ត្រ និងបានពង្រឹងសមត្ថភាពរបស់ខ្លួនមួយផ្នែកបន្ថែមទៀត ដើម្បីយកទៅអនុវត្តជាមួយសិស្សឱ្យកាន់តែប្រសើរ។

- បង្រៀនតាមលំដាប់លំដោយធ្វើឲ្យសិស្សឆាប់យល់ ឆាប់ចាំ និងចងចាំបានច្រើន ធ្វើសិស្សចេះប្រកប ចេះអាន យល់ន័យនៃពាក្យ និងយល់ន័យនៃអត្ថបទ

- សិស្សងាយយល់ ងាយចងចាំ និងសម្រាប់គ្រូក៏ងាយក្នុងការបង្រៀនដែរ សម្ភារសម្ភារច្រើន សិស្សឆាប់យល់មេរៀន។

ជាការសាកសួរសំណួរបន្ថែម ដើម្បីចង់ដឹងថា«តើសាលារៀនរបស់លោកគ្រូ អ្នកគ្រូ មុនពេលបានអនុវត្តកម្មវិធីកញ្ចប់អំណាន តើសិស្សទទួលបានលទ្ធផលយ៉ាងដូចម្ដេច? និងក្រោយពេលបានអនុវត្តកញ្ចប់អំណានទទួលបានលទ្ធផលដូចម្ដេច?»។ ជាការឆ្លើយតបសំណួរ លោកគ្រូ អ្នកគ្រូថ្នាក់ទី២ទាំង ៣០នាក់ នៃសាលាសំណាកទាំង២០បានផ្ដល់ចម្លើយជារួមមកដូចខាងក្រោម៖

**ក.លទ្ធផលមុនការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង៖**

- សិស្សមានការច្រឡំសូរ ច្រឡំតួអក្សរ ការអានមិនសូវបានល្អឡើយ។

- សិស្សចេះអានមានចំនួនតិចតួច លទ្ធផលទាប

- សិស្សរៀនចាប់មិនសូវបាន មិនសូវមានការចូលរួម ចងចាំមិនបានយូរ

- សិស្សមិនទាន់ស្គាល់ច្បាស់ពីសមាសភាគទាំង៥នៃអំណាន

- សិស្សពុំមានបំណិនក្នុងការអាន

- សិស្សនិងគ្រូពិបាកស្វែងយល់លើខ្លឹមសារមេរៀន

- សិស្សមិនងាយយល់ ខ្លឹមសារវែង

- សិស្សគ្មានភាពក្លាហាន មិសូវចេះអាន មិនសូវចង់មករៀន

- មិនដឹងពីការប្រកួតអំណាន មិនមានភាពក្លាហាននិងពុំសូវមានសម្ភារៈរៀនសម្បូរបែប

- ដំណើរការមេរៀនមានភាពលំបាក ការអនុវត្តលើការអានព្យាង្គ ពាក្យ តិចពេក សិស្សមិនបានហ្វឹកហាត់ការអានអត្ថបទខ្លី ធ្វើឱ្យលទ្ធផលនៃការសិក្សានៅមានកម្រិតទាប។

**ខ.លទ្ធផលក្រោយពីបានអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង៖**

- សិស្សស្គាល់សូរ ស្គាល់តួអក្សរ ចេះវាក្យស័ព្ទ អាចអានស្ទាត់ និងយល់ន័យបានល្អប្រសើរជាងមុនលទ្ធផលខ្ពស់ជាងមុន

- សិស្សមានការចូលរួមច្រើន មានសកម្មភាពជាងមុន ចងចាំមេរៀនបានយូរ ឆាប់ចេះ

- សិស្សស្គាល់ច្បាស់ពីសមាសភាគទាំង៥នៃអំណាន( ការស្គាល់សូរអក្សរថ្មី ការស្គាល់តួអក្សរថ្មី វាក្យសព្ទ ការអានស្ទាត់ ការអានយល់ន័យ)

- សិស្សមានការប្រែប្រួលទាក់ទងនិងការអានដូចជាចេះអានព្យាង្គ អានពាក្យ ល្បះ និងអត្ថបទងាយៗ ចេះប្រកបពាក្យ ល្បះ អាចសរសេរព្យាង្គ ពាក្យ ល្បះងាយៗបានសមស្រប

- មានភាពក្លាហានក្នុងការធ្វើសកម្មភាពរៀន

- សិស្សនិងគ្រូបានស្វែងយល់ពីមេរៀនបានច្បាស់ល្អងាយស្រួលក្នុងការរៀន និងបង្រៀន

- ការបង្រៀនមានការងាយស្រួលជាងមុន សិស្សចេះច្រើនឆាប់ចាប់បាន សិស្សសប្បាយរីករាយព្រោះមានរូបភាពស្អាតសកម្មភាពរស់រវើក ការនិយាយបានល្អជាងមុន ចូលចិត្តមករៀន

- គ្រូងាយស្រួលក្នុងការបង្រៀនព្រោះមានលំនាំបង្រៀនច្បាស់លាស់ សិស្សងាយយល់មេរៀន លទ្ធផលមានការកើនឡើងរហូតដល់ជាប់៨០%

- ដំណើរការបង្រៀនតាមលំនាំនីមួយៗច្បាស់លាស់តាមការណែនាំក្នុងសៀវភៅណែនាំគ្រូ សៀវភៅជំនួយសិស្សមានភាពទាក់ទាញនិងច្បាស់ ជាផ្នែកមួយទាក់ទាញអារម្មណ៍សិស្ស ដូចជាតារាងការអានព្យាង្គ ពាក្យ តួអក្សរធំៗច្បាស់ៗជាដើម លទ្ធផលនៃការសិក្សា ទទួលបានគុណភាពខ្ពស់ជាងមុន សិស្សចេះអាន និង ចូលចិត្តការអានច្រើន។

**ផ្នែកទី៣៖ សំណូមពរ និងចំណាប់អារម្មណ៍របស់គ្រូបង្រៀនថ្នាក់ទី២ ចំពោះកម្មវិធីកញ្ចប់អំណានដំបូង៖**

- សូមជួយបង្កើតឱ្យមានកម្មវិធីសិក្ខាសាលាស្តីពីកញ្ចប់អំណាននេះពីថ្នាក់ទី1ដល់ទី6

- សំណូមពរផ្តល់ជាសម្ភារៈបន្ថែមដើម្បីប្រើប្រាស់ក្នុងការរៀននិងបង្រៀនសិស្ស

- ផ្តល់វគ្គបំប៉នផ្នែកអំណានថ្នាក់ដំបូងដល់លោកគ្រូ អ្នកគ្រូនៅសាលាដទៃដើម្បីឱ្យពួកគាត់មានសមត្ថភាពជួយសិស្សបានល្អប្រសើរជាងមុន។

- លោកគ្រូ អ្នកគ្រូមានអារម្មណ៍រីករាយឥតគណនា ដោយបានចូលរួមវគ្គបំប៉នផ្នែកអំណានថ្នាក់ដំបូងនេះ ព្រោះអាចឱ្យពួកគាត់ជួយសិស្ស និងកូនៗរបស់ពួកគាត់បានល្អប្រសើរជាងមុន

- សូមជួយផ្តល់សៀវភៅកញ្ចប់អំណានសម្រាប់សិស្ស និងគ្រូឱ្យបានគ្រប់គ្រាន់

- សូមជួយពង្រឹងបន្ថែមទៀតលើវិធីសាស្ត្របង្រៀនដើម្បីឱ្យកាន់តែច្បាស់

- សំណូមពរឲ្យមានវគ្គសិក្ខាសាលាញឹកញាប់ និងគ្រប់កម្រិតថ្នាក់

- សូមកាត់បន្ថយកិច្ចតែងការបង្រៀនខ្លះ(សកម្មភាពវែងពេក)

- សកម្មភាពបង្រៀនច្រើន ម៉ោងសិក្សាខ្លី

- កម្មវិធីកញ្ចប់អំណានដំបូងពិតជាល្អសម្រាប់គ្រូនិងសិស្សខ្លាំងណាស់

- បន្តវគ្គកញ្ចប់អំណានទៅដល់លោកគ្រូ អ្នកគ្រូថ្មី

- កំណត់ឈ្មោះគ្រូត្រូវរៀនកញ្ចប់អំណានឲ្យបានជាប់គ្រប់វគ្គ

- ចុះតាមដានការបង្រៀនសម្រាប់លោកគ្រូ អ្នកគ្រូបានទទួលវគ្គកញ្ចប់អំណានឲ្យបានជាប់

- ពេញចិត្តកម្មវិធីកញ្ចប់អំណាននេះណាស់ បើបើកសាលាវិញសំណូមពរឱ្យបើកវគ្គបណ្តុះបណ្តាលកញ្ចប់អំណាន

- កញ្ចប់អំណាន ពិតជាល្អធ្វើឲ្យសិស្ស ចូលចិត្តអាន និងអានបានល្អ

- មានអារម្មណ៍សប្បាយរីករាយដែលមានជំនួយរបស់អង្គការដៃគូជួយធ្វើឲ្យថ្នាក់រៀនសាលាមានការអភិវឌ្ឍ

- កម្មវិធីកញ្ចប់អំណានដំបូងល្អគឺសិស្សមានការចូលរួមរៀន ព្រោះមានលំហូរមួយៗមានល្បែងសិក្សា មានសកម្មភាពគ្រូធ្វើ គ្រូនិងសិស្សធ្វើ សិស្សធ្វើ

- ពង្រីកកម្មវិធីកញ្ចប់អំណានឱ្យបានគ្រប់សាលារៀនទូទាំងប្រទេស

- សូមឱ្យមានកម្មវិធីបណ្តុះបណ្តាលកម្មវិធីកញ្ចប់អំណាននេះបន្ថែមទៀត ព្រោះក្នុងការបង្រៀនកម្មវិធីកញ្ចប់អំណានថ្នាក់ទី២នេះ មិនទាន់យល់ច្បាស់ល្អនៅឡើយ។

- កម្មវិធីកញ្ចប់អំណានដំបូងពិតជាមានសារៈសំខាន់ណាស់ ព្រោះបានធ្វើឱ្យគ្រូយល់កាន់តែច្បាស់ពីវិធីសាស្ត្របង្រៀនកញ្ចប់អំណានដើម្បីយកទៅអនុវត្តជាមួយសិស្សានុសិស្ស ឱ្យកាន់តែមានភាពល្អប្រសើរ

- ចំពោះសិស្សគឺគាត់ចូលចិត្តរៀនសូត្រ និងចាប់អារម្មណ៍ច្រើន

- សូមអរគុណទៅដល់គម្រោងដែលបានចងក្រងមេរៀនជាកញ្ចប់អំណាន ដែលធ្វើងាយស្រួលក្នុងការបង្រៀន និងរៀនដល់គ្រូនិងសិស្ស។

សរុបសេចក្តីមក តាមលទ្ធផលស្រាវជ្រាវខាងលើ អំពីស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងនៅក្នុងខេត្តកំពង់ឆ្នាំង អាចនិយាយបានថាក្នុងចំណោមសាលាសំណាកទាំង២០ ដែលបានអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងតាំងពីថ្នាក់ទី១ រហូតដល់ថ្នាក់ទី២មានលក្ខណៈល្អគួរឱ្យយកជាគំរូបានសម្រាប់សាលាផ្សេងៗទៀតនៅក្នុងខេត្តកំពង់ឆ្នាំងទាំងមូល ដែលមានសាលាបឋមសិក្សារហូតដល់២៧៩ សាលា ដើម្បីអនុវត្តតាមកម្មវិធីនេះ ហើយក៏អាចធ្វើជាទីតាំងសិក្សាសម្រាប់សាលាផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជាយើងដែលពុំទាន់បានអនុវត្តកម្មវិធីនេះ ក្នុងការចុះមកធ្វើទស្សនកិច្ចសិក្សា ក្នុងការដកស្រង់បទពិសោធន៍ ដោយមើលអំពីដំណើរការបង្រៀន និងរៀនកម្មវិធីកញ្ចប់អំណាននេះផងដែរ។

## ៤.៤ ការពិភាក្សា

ដូចដែលបានបង្ហាញ និងបកស្រាយខាងលើមកហើយថា កម្មវិធីកញ្ចប់អំណាននេះជាកម្មវិធីថ្មី ដូច្នេះដើម្បីអាចដំណើរការកម្មវិធីនេះទៅបាន ទាល់តែគ្រូធ្លាប់បានឆ្លងកាត់ការចូលរួមសិក្ខាសាលាអំពីវិធីសាស្ត្របង្រៀន និងរៀននៃកម្មវិធីនេះ សាលាត្រូវមានថវិកាសម្រាប់ដំណើរកម្មវិធី ដោយសារត្រូវការសម្ភារបង្រៀនច្រើន គួបផ្សំនឹងការកែច្នៃរបស់គ្រូបន្ថែម គ្រូត្រូវតែតែងកិច្ចបង្រៀនដើម្បីដើរឱ្យត្រូវតាមលំនាំនៃការបង្រៀនកញ្ចប់អំណាន មានការប្រជុំបច្ចេកទេសជាទៀងទាត់ដើម្បីពិភាក្សា និងផ្លាស់ប្តូរបទពិសោធគ្នាទៅវិញទៅមកជាដើម។ តែជាភ័ព្វសំណាងរបស់សាលាទាំង២០ ក៏ដូចជាភ័ព្វសំណាងរបស់កុមារដែលបានរៀននៅសាលាទាំង២០នេះ ដោយសារពួកគេបានរៀនជាមួយកម្មវិធីកញ្ចប់អំណាននេះធ្វើឱ្យពួកគេឆាប់ស្គាល់សូរ ស្គាល់តួ ឆាប់ចេះអានព្យាង្គ ពាក្យ អត្ថបទខ្លី អានយល់ន័យជាដើម។ ចំណែកគ្រូវិញក៏មានភ័ព្វសំណាងល្អផងដែរ ដោយបានចូលរួមសិក្ខាសាលាបានសិក្សាពីវិធីសាស្ត្របង្រៀនកម្មវិធីកញ្ចប់អំណាននេះ ហើយបានទាំងចំណេះ ទាំងប្រាក់ឧបត្ថម្ភលើកទឹកចិត្តពីគម្រោងទៀតផង តាមរយៈគម្រោងរបស់អង្គការ Save the Children បានមកចាប់យកសាលាទាំង២០នេះក្នុងការជួយឧបត្ថម្ភគាំទ្រ ព្រមទាំងសម្ភារៈសិក្សា សៀវភៅសិក្សា បណ្ណាល័យ ជួយកែលម្អផ្នែកបរិស្ថានសាលា និងរៀបចំថ្នាក់បរិយាបន្នជាដើម។

ប៉ុន្តែជឿជាក់ថាសាលាផ្សេងៗទៀតក៏អាចអនុវត្តបាន ប្រសិនបើគណៈគ្រប់គ្រងនៃសាលារៀននោះមានឆន្ទៈមោះមុតក្នុងការអនុវត្តកម្មវិធីនេះ នៅសាលារបស់ខ្លួន ដោយធ្វើផែនការប្រតិបត្តិដោយរៀបចំគ្រោងជាថវិកាសម្រាប់ដំណើរកម្មវិធី គ្រូខិតខំសិក្សាស្រាវជ្រាវដកស្រង់បទពិសោធពីសាលាដែលធ្លាប់បានអនុវត្ត គណៈគ្រប់គ្រងមានទំនាក់ទំនងល្អជាមួយអង្គការដៃគូ ឬក្រសួងដើម្បីសុំជំនួយជាសៀវភៅសិក្សានៃកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង។

លោកគ្រូ អ្នកគ្រូភាគច្រើនអាចមានសមត្ថភាពបង្រៀនកញ្ចប់អំណានថ្នាក់ដំបូងបាន ដោយ សារតែពួកគាត់ធ្លាប់បានដឹង និងបានចូលរួមវគ្គសិក្ខាសាលាបំប៉នផ្សេងៗ និងមានបទពិសោធបង្រៀនយូរឆ្នាំ

ដូចបានបង្ហាញជូនក្នុងលទ្ធផលខាងលើ។ ចំណែកឯគ្រូបង្រៀនមួយចំនួនទៀតដែលមិនធ្លាប់បានចូលរួមសិក្ខាសាលា ក៏អាចបង្រៀនបានដោយសារនៅតាមសាលាមានការប្រជុំក្រុមបច្ចេកទេសទៀងទាត់ ដើម្បីពិភាក្សា ចែករំលែកបទពិសោធគ្នា ជួយផលិតជាសម្ភារៈឧបទេសគ្នាទៅវិញទៅមកផងដែរ។

ដូចនេះឆ្លងតាមរយៈការសិក្សាស្រាវជ្រាវស្តីពី «ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង ក្នុងខេត្តកំពង់ឆ្នាំង» ឃើញថាក៏មានលក្ខណៈល្អ ទទួលបានលទ្ធផលល្អប្រហាក់ប្រហែលគ្នា ឬសាលាខ្លះក៏មានលទ្ធផលការសិក្សារបស់សិស្សខ្ពស់ជាង បើធៀបទៅនឹងការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងសាកល្បង ក្នុងខេត្តសៀមរាបផ្នែកអំណាននេះទៀតផង។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

ក្នុងជំពូកនេះអ្នកសិក្សានឹងលើកឡើងពីសេចក្តីសន្និដ្ឋាន និងសំណូមពរ ព្រមទាំងលើកឡើងពីអនុសាសន៍មួយចំនួន ពាក់ព័ន្ធទៅនឹង «ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង ក្នុងខេត្តកំពង់ឆ្នាំង»។

## ៥.១. សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវនេះ យើងយល់ឃើញថា ការអនុវត្តអំណានដំបូងនៅតាមសាលាបឋមសិក្សាពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការជួយឱ្យកុមារឆាប់ស្គាល់សូរ ស្គាល់តួ ចេះអានព្យាង្គ ពាក្យ អត្ថបទខ្លី អានយល់ន័យ និងចេះសរសេរបានលឿនជាងមុន។ មួយវិញទៀតកម្មវិធីជួយឱ្យមានភាពងាយស្រួលដល់លោកគ្រូ អ្នកគ្រូក្នុងការបង្រៀនសិស្ស ដោយសារសម្បូរវិធីសាស្ត្រថ្មីៗជាច្រើនជាហេតុធ្វើឱ្យសិស្សសប្បាយចិត្តក្នុងការសិក្សា ចូលរួមជាមួយគ្រូក្នុងការធ្វើសកម្មភាពរៀនសូត្រ ព្រោះសម្បូរបែបទៅដោយល្បែងសិក្សា គ្រូចេះផលិតសម្ភារឧបទេស ក្រោយពីគ្រូបង្រៀនបានទទួលវគ្គបណ្តុះបណ្តាលនូវកម្មវិធីកញ្ចប់អំណានដំបូង។ កម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង ជាកម្មវិធីដែលសម្បូរទៅដោយគន្លឹះ វិធីសាស្ត្របង្រៀនអំណានដល់សិស្ស ដើម្បីជួយអភិវឌ្ឍសមត្ថភាពអានរបស់សិស្សក៏ដូចជាការជួយអភិវឌ្ឍគុណភាពអប់រំផងដែរ។ ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងតាមរយៈប្រធានការិយាល័យអប់រំ នៃរដ្ឋបាលស្រុកចំនួន០៣ តែចូលរួមផ្តល់ទិន្នន័យបានពីរនាក់ នាយក/នាយិកាចំនួន២០នាក់តែបានផ្តល់ទិន្នន័យត្រឡប់បានចំនួន១៦នាក់ ប្រធានក្រុមបច្ចេកទេសចំនួន២០នាក់(គ្រប់ចំនួន) គ្រូបង្រៀនថ្នាក់ទី២ចំនួន៣១នាក់(បានផ្តល់ទិន្នន័យ៣០នាក់) នៃសាលារៀនចំនួន២០ ជាកម្រិតបឋមសិក្សា នៅក្នុងខេត្តកំពង់ឆ្នាំង។

ការសិក្សាស្រាវជ្រាវនេះផ្តោតលើចំណុចសំខាន់ៗមួយចំនួន ដើម្បីឱ្យការអនុវត្តអំណានដំបូងនៅកម្រិតបឋមសិក្សាអាចដំណើរការទៅបាន និងការបង្រៀនមានប្រសិទ្ធភាពរួមមាន៖

- ថ្នាក់ដឹកនាំការិយាល័យនៃរដ្ឋបាលស្រុក គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនស្ទើរតែទាំងអស់ សុទ្ធតែធ្លាប់បានចូលរួមសិក្ខាសាលាកម្មវិធីកញ្ចប់អំណានដំបូងនេះ ស្ទើតែគ្រប់គ្នា តាមរយៈគម្រោងនៃអង្គការដៃគូពាក់ព័ន្ធក្នុងការជួយឧបត្ថម្ភ។

- ដោយមើលឃើញពីសារៈសំខាន់នៃកម្មវិធីកញ្ចប់អំណាន និងចង់ឱ្យសិស្សានុសិស្សនៅក្នុងសាលារៀនរបស់ខ្លួន មានលទ្ធផលខ្ពស់ផ្នែកអំណាន ដោយចាប់ចេះអាន ចេះសរសេរ ក៏មានសាលាចំនួន៦០% បានច្នៃថវិកានៃដំណើរការសាលារៀនរបស់ខ្លួន បន្ថែមលើការជួយឧបត្ថម្ភរបស់គម្រោង ក្នុងការគាំទ្រការបង្រៀន និងរៀនរបស់គ្រូនៅសាលារៀនរបស់ខ្លួន។

- លោកគ្រូ អ្នកគ្រូមួយភាគតូចដែលមិនធ្លាប់បានចូលរួមសិក្ខាសាលាអំពីកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងក៏មានពិតមែន ដោយសារពេលបើកវគ្គសិក្ខាសាលាគាត់បង្រៀននៅកម្រិតថ្នាក់ផ្សេង ប៉ុន្តែពួកគាត់អាចបង្រៀនបានដោយសារការប្រជុំបច្ចេកទេសផ្លាស់ប្តូរ និងចែករំលែកបទពិសោធគ្នាបានទៀងទាត់។

- ក៏មានសាលាមួយចំនួនពុំបានគ្រោងខ្ទង់ថវិកាចំណាយលើកម្មវិធីអំណានដំបូងនេះទេ ដោយពឹងផ្អែកលើអង្គការដៃគូទាំងស្រុង។

ដូច្នេះ តាមលទ្ធផលនៃការស្រាវជ្រាវខាងលើ អំពីស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងនៅក្នុងខេត្តកំពង់ឆ្នាំង អាចនិយាយបានថាក្នុងចំណោមសាលាសំណាកទាំង២០ ដែលបានអនុវត្តកម្មវិធីកញ្ចប់អំណានដំបូងតាំងពីថ្នាក់ទី១ រហូតដល់ថ្នាក់ទី២មានលក្ខណៈល្អគួរឱ្យយកជាគំរូបានសម្រាប់សាលាផ្សេងៗទៀតនៅក្នុងខេត្តកំពង់ឆ្នាំងទាំងមូល ដែលមានសាលាបឋមសិក្សារហូតដល់២៧៩សាលា ដើម្បីអនុវត្តតាមកម្មវិធីនេះ ហើយក៏អាចធ្វើជាទីតាំងសិក្សាសម្រាប់សាលាផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជាយើងដែលពុំទាន់បានអនុវត្តកម្មវិធីនេះ ក្នុងការចុះមកធ្វើទស្សនកិច្ចសិក្សាក្នុងការដកស្រង់បទពិសោធន៍ដោយមើលអំពីដំណើរការបង្រៀន និងរៀនកម្មវិធីកញ្ចប់អំណាននេះផងដែរ។

## ៥.២. សំណូមពរ

ខាងក្រោមនេះជាសំណូមពររបស់ប្រធានការិយាល័យអប់រំ នៃរដ្ឋបាលស្រុក នាយក/នាយិកាសាលា លោកគ្រូ អ្នកគ្រូជាប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី២ ជូនចំពោះថ្នាក់ដឹកនាំក្រសួងអប់រំ៖

- ផ្តល់កញ្ចប់សម្ភារៈអំណានដំបូង ឯកសារគាំទ្រផ្សេងៗ និងសិក្ខាសាលាបំប៉នគ្រូបង្គោល ដើម្បីបំប៉នបន្តតាមសាលាទូទាំងខេត្ត ស្រុកផ្សេងៗក្នុងខេត្ត ក៏ដូចជាក្នុងប្រទេសឱ្យបានគ្រប់សាលា

-ស្នើសុំកញ្ចប់ថវិកាបន្ថែមលើពីកម្មវិធីអំណានដំបូង និងត្រួតពិនិត្យតាមដាន។

- ស្នើសុំឲ្យក្រសួងមានកម្មវិធីច្បាស់លាស់ និងដាក់បញ្ចូលកម្មវិធីនេះទៅក្នុងកម្មវិធីសិក្សាឱ្យបានគ្រប់សាលាទូទាំងប្រទេស ដើម្បីកុមារឆាប់ចេះអាន ចេះសរសេរ។

## ៥.៣. អនុសាសន៍សម្រាប់អ្នកសិក្សាបន្ត

ការស្រាវជ្រាវនេះធ្វើបានតែចំនួន២០សាលាប៉ុណ្ណោះក្នុងខេត្តកំពង់ឆ្នាំង អ្នកចង់សិក្សាស្រាវជ្រាវបន្ត អាចពង្រីកទំហំនៃការសិក្សាបន្ថែម ព្រោះគម្រោង PEER របស់អង្គការ Save the Children បានពង្រីកសាលាគោលដៅរហូតដល់៣២សាលា ក្នុងការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូងនេះក្នុងខេត្តកំពង់ឆ្នាំង៕

# ឯកសារយោង


១.ពុទ្ធសាសនបណ្ឌិត្យ (១៩៦៨) «វចនានុក្រមខ្មែរភាគ១-ភាគ២សម្ដេចព្រះសង្ឃរាជជួន ណាត» ភ្នំពេញ ពុទ្ធសាសនបណ្ឌិត្យ

២.ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) «សៀវភៅជំនួយភាសាខ្មែរថ្នាក់ទី២ ភាគ១- ភាគ២ សម្រាប់សិស្សអាន និងសរសេរ» ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា

៣. ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) «សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២ ភាគ១ ស្ដីអំពីសម្ភារៈជំនួយបន្ថែមលើសៀវភៅសិក្សាគោលភាសាខ្មែរ អាន និងសរសេរ(កញ្ចប់សម្ភារៈអំណានដំបូង) » ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា

៤. ក្រសួងអប់រំ យុវជន និងកីឡា (២០២០) «សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី២ ភាគ២ ស្ដីអំពីសម្ភារៈជំនួយបន្ថែមលើសៀវភៅសិក្សាគោលភាសាខ្មែរ អាន និងសរសេរ(កញ្ចប់សម្ភារៈអំណានដំបូង) » ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា

៥.ក្រសួងអប់រំ យុវជន និងកីឡា(២០១៩)«ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣» ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា

៦.វិទ្យាស្ថានជាតិអប់រំ (២០១៩) «និក្ខេបបទគំរូរបស់លោក ឃិន សម្បត្តិ និស្សិតបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំជំនាន់ទី៦ ឆ្នាំសិក្សា ២០១៧-២០១៩» ភ្នំពេញ វិទ្យាស្ថានជាតិអប់រំ

៧. ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) «លទ្ធផល តេស្ត អឺហ្គ្រា ឆ្នាំ២០១៧-២០១៨» ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា

៨.https://hellokrupet.com

៩. http://cambodian.cri.cn/i

១០.https://www.coj.gov.kh/wpcontent/uploads

១១.https://web.facebook.com

១២. https://thmeythmey.com/?page

១៣. https://archive.monoroom.info/news/post/67#1PlEG5vMUufoiDU4.99

១៤.https://khmer-lfrd.com/wpcontent/uploads

១៥.https://www.usaid.gov/node

១៦.http://freshnewsasia.com/index.php/en/localnews

១៧.https://www.information.gov.kh/articles

១៨.https://l.facebook. com/l.php?u=http%3A%2F%2Fsmaradeykhmer.org

១៩.គល់រាំង - ភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ៖ មនោរម្យព័ងអាំងហ្វូ

Crédit photo : Lori-Ga!/flickr.com

# ឧបសម្ព័ន្ធ

## លិខិតឧទ្ទេសនាម និងឯកសារពាក់ព័ន្ធ

### ឧបសម្ព័ន្ធទី១៖ លិខិតអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យរបស់ក្រសួងអប់រំ យុវជន និងកីឡា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ២៤០៩ **អយក.** ឧទន

ថ្ងៃព្រហស្បតិ៍ ៧កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១

**ជម្រាបមក**
**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨។

**យោង៖** -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។
-លិខិតលេខ១៤៣៥ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក លោកស្រី ប្រធាន** ជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ចំនួន៣១នាក់ ត្រូវបានអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យនៅតាមរាជធានី-ខេត្តនានាតាមប្រព័ន្ធអនឡាញ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចាប់ពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រី ប្រធាន** ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម **លោក លោកស្រី ប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ឧបសម្ព័ន្ធទី២៖ លិខិតឧទ្ទេសនាមគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងសម្រាប់និស្សិត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ១៤៣៤ អយក.ឧទន

## លិខិតឧទ្ទេសនាម

យោង ៖ - លិខិតលេខ៣៣៦២ អយក.វជអ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩។

- បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ឆ្នាំសិក្សា២០១៩-២០២១ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | គ្រូដឹកនាំបង្គោល | គ្រូដឹកនាំរង | ប្រធានបទនិក្ខេបបទស្រាវជ្រាវ | និស្សិត |
|---|---|---|---|---|
| ១ | លោក<br>សៀង វាសនា | លោកបណ្ឌិត<br>អាន រ៉ូប្រាវ | ទស្សនៈរបស់បុគ្គលិកអប់រំចំពោះការអនុវត្តកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សនៅមធ្យមសិក្សាទុតិយភូមិ ឆ្លើយតបទៅនឹងគោលនយោបាយអប់រំ ២០១៨-២០២៣ នៅក្នុងរាជធានីភ្នំពេញ | ល.ស គីម ដាវី |
| ២ | លោកបណ្ឌិត<br>ម៉ម ចាន់សៀន | លោកស្រី<br>ប៊ុន សុផានី | ប្រសិទ្ធភាពនៃការចូលរួមរបស់សហគមន៍ទៅលើការពង្រឹងការអនុវត្តការគ្រប់គ្រងសាលារៀនអនុវិទ្យាល័យ(ករណីសិក្សាស្រុកទ្រាំង ខេត្តតាកែវ) | ល. ជី ចាន់ |
| ៣ | ឯកឧត្តមបណ្ឌិត<br>ម៉ុក សារ៉ុម | លោក<br>ម៉ន មុនិន្ទ | ទស្សនៈរបស់គ្រូបង្រៀនលើការអនុវត្តភាពជាអ្នកដឹកនាំរបស់នាយកសាលាកម្រិតវិទ្យាល័យក្នុងខេត្តរតនគិរី | ល. ឈុន សុគន្ធា |
| ៤ | លោកបណ្ឌិត<br>នី រដ្ឋា | លោក<br>លឹម វ៉ាន់ | ស្ថានភាពនៃការបង្រៀន និងរៀនលើមុខវិជ្ជា ICT នៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តព្រៃវែង | ល. ប៉ាវ សេងហួ |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | | | |
|---|---|---|---|---|
| ៥ | លោកបណ្ឌិត<br>នី វង្សា | លោក<br>ឌី បុណ្ណា | ផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ ឡើងទី៧ លើមុខវិជ្ជាជាភាសាខ្មែរ និងគណិតវិទ្យារបស់គម្រោងកែលម្អគុណភាពអប់រំហៅថា (SEIP) ករណីសិក្សាខេត្តព្រះសីហនុ | ល. ឈូក ដន |
| ៦ | ឯកឧត្តមបណ្ឌិត<br>សៀង សុវណ្ណា | លោក<br>ថៃ ហេង | យុទ្ធសាស្ត្រនៃការដោះស្រាយបញ្ហាខ្វះគ្រូ និងលើសគ្រូ ក្នុងខេត្តកំពង់ធំ | ល. នេត សីមា |
| ៧ | ឯកឧត្តមបណ្ឌិត<br>សៀង សុវណ្ណា | លោក<br>ឡុច ចាន់ថន | យុទ្ធសាស្ត្រជំរុញគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ | ល. ប៊ិន តុលា |
| ៨ | លោកស្រី<br>នូ ចន្ទី | លោកបណ្ឌិត<br>អាន រ៉ូប្រាវ | ទស្សនៈគ្រូឧទ្ទេសលើការដឹកនាំ និងគ្រប់គ្រងការបង្រៀន និងរៀននៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ | ល. បែន ដាលី |
| ៩ | ឯកឧត្តម<br>នៀ សុផន | លោកបណ្ឌិត<br>កាង ស៊ីងឆាង | ស្ថានភាពនៃការបែងចែកផែនការក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ ប្រចាំឆ្នាំ២០១៩ ករណីសិក្សាខេត្តកណ្តាល | ល. ផាន់ សារ៉ាវុឌ្ឍ |
| ១០ | លោកបណ្ឌិត<br>ឈាង សង្វាត | លោក<br>ថៃ ហេង | ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី | ល.ព្រិញ ចាន់ហួរ |
| ១១ | ឯកឧត្តមបណ្ឌិត<br>ជ័យ សារិន | លោក<br>ម៉ន មុនិន្ទ | ស្ថានភាពនៃការអនុវត្តប្រព័ន្ធអធិការកិច្ចផ្ទៃក្នុង ក្នុងការធ្វើស្វ័យវាយតម្លៃសាលារៀន «ករណីសិក្សា ស្រុករំដួលខេត្តស្វាយរៀង» | ល. ព្រំ រចនា |
| ១២ | លោកស្រី<br>ខែក សំណាង | ឯកឧត្តមបណ្ឌិត<br>សៀង សុវណ្ណា | ការសិក្សាសៀវភៅសិក្សាគោលមុខវិជ្ជាអក្សរសាស្ត្រខ្មែរនៅកម្រិតមធ្យមសិក្សាទុតិយភូមិ«ករណីសិក្សាក្នុងខេត្តព្រៃវែង» | ល. ភ័ណ សុភា |
| ១៣ | លោក<br>ចាប រតនា | លោកបណ្ឌិត<br>ឈាង សង្វាត | ការបំពេញការងាររបស់នាយកសាលាមធ្យមសិក្សាធនធាននិងសាលាបណ្តាញក្នុងខេត្តកំពង់ស្ពឺធៀបនឹងគោលនយោបាយសាលាមធ្យមសិក្សាធនធាន | ល. មុន សុខកែវ |

| | | | | |
|---|---|---|---|---|
| ១៤ | លោកបណ្ឌិត<br>អាន រ៉ូប្រាវ | លោកស្រី<br>នូ ចន្នី | ទស្សនរបស់គ្រូបង្រៀន និងនាយកសាលាលើការអនុវត្តផែនការសកម្មភាពនៃគោលនយោបាយស្តីគ្រូបង្រៀននៅមធ្យមសិក្សាទុតិភូមិក្នុងរាជធានីភ្នំពេញ | ល. យ៉ាង ច័ន្ទរស្មី |
| ១៥ | លោកបណ្ឌិត<br>សំអោ អង្គារតន៍ | លោកស្រី<br>សុខ វណ្ណា | ទស្សនៈគ្រូបង្រៀនទៅលើប្រសិទ្ធភាពនៃការបង្រៀននិងរៀនតាមប្រព័ន្ធអេឡិចត្រូនិក និងការបង្រៀននិងរៀននៅក្នុងថ្នាក់ផ្ទាល់ នៅកម្រិតមធ្យមសិក្សា | ល. យឹម រស្មី |
| ១៦ | លោក<br>ម៉ន មុនិន្ទ | លោកបណ្ឌិត<br>នូវ វីរ៉ា | ទស្សនៈយល់ឃើញរបស់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ លើការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសដើម្បីបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញនៅខេត្តឧត្តរមានជ័យ | ល. រស់ សុភាន់ |
| ១៧ | លោក<br>ម៉ៅ សារឿន | ឯកឧត្តមបណ្ឌិត<br>ម៉ុក សារ៉ុម | ស្ថានភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងការគ្រប់គ្រង និងការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តរតនគិរី | ល. លាស់ សាឡួន |
| ១៨ | លោក<br>ថៃ ហេង | លោកបណ្ឌិត<br>ម៉ម ចាន់សៀន | ការសិក្សាស្វែងយល់អំពីផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី-ខេត្ត | ល. ស៊ន់ កុសល |
| ១៩ | លោក<br>លឹម វ៉ាន់ | លោកបណ្ឌិត<br>នូវ វីរ៉ា | ការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញករណីសិក្សានៅខេត្តតាកែវ | ល. ស៊ុំ សុខឿន |
| ២០ | លោកបណ្ឌិត<br>នូវ វីរ៉ា | លោក<br>ចាប រតនា | ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង ក្នុងខេត្តកំពង់ឆ្នាំង | ល. អ៊ុង សុផល |

**ឯកឧត្តម លោក លោកស្រី** ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ៧ ១០ ៧ ៩ ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- -អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី " ដើម្បីជ្រាបជាព័ត៌មាន"
- -គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ " ដើម្បីជ្រាបជាព័ត៌មាន"
- -សាមីខ្លួន " ដើម្បីអនុវត្ត"
- -កាលប្បវត្តិ
- -ឯកសារ រដអ

## ឧបសម្ព័ន្ធទី៣៖ លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៣៧២០៧ **អយក.** ១០៤

**(ការសម្ងាត់)**

### លិខិតឧទ្ទេសនាម

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។
-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ ទី៨ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ម៊ុនរឿន** | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម **យត់ ឌុំយ** | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម **លាង សេងហាក់** | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត **ឌី ខាំបូលី** | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ពុធ ៦កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២១
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ រដអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# ឧបសម្ព័ន្ធទី៤៖ លិខិតឧទ្ទេសនាមគណៈកម្មការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៣២០៥ **អយក.** [illegible]

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
